អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization · a Cambodian Urban NGO

# សុវត្ថិភាពដីធ្លី នៃសហគមន៍ក្រីក្រនៅទីក្រុង

## បញ្ហាប្រឈម និងដំណោះស្រាយ



២០២៤

# តារាងមាតិកា

**សេចក្តីសង្ខេប**..........................................................................................១

**សាវតា**.......................................................................................................៣

**គោលបំណងស្រាវជ្រាវ**..............................................................................១០

គោលបំណង..........................................................................................១០

ចំណោទបញ្ហា........................................................................................១០

**វិធីសាស្ត្រស្រាវជ្រាវ**......................................................................................១១

ទីតាំងស្រាវជ្រាវ.....................................................................................១១

វិធីសាស្ត្រ............................................................................................១២

**លទ្ធផលស្រាវជ្រាវ**..........................................................................................១៥

ការពិនិត្យឯកសារដែលមានស្រាប់..........................................................១៥

ករណីសិក្សាអន្តរជាតិ.............................................................................២៧

លទ្ធផលពីការពិភាក្សាជាក្រុមស្នូល..........................................................៣០

លទ្ធផលពីការស្ទង់មតិគ្រួសារ...................................................................៣៩

**សេចក្តីសន្និដ្ឋាន**..............................................................................................៥០

**អនុសាសន៍**.....................................................................................................៥៨

# សេចក្តីសង្ខេប



*រូបភាពទី១៖ លំនៅឋានក្នុងសហគមន៍សំរោងត្បូង*

ការស្រាវជ្រាវនេះមានគោលបំណងធ្វើការសិក្សាយ៉ាងទូលំទូលាយលើបញ្ហាដីធ្លី ដែលប្រជាពលរដ្ឋនៅសហគមន៍ក្រីក្រចំនួន១១ ក្នុងរាជធានីភ្នំពេញជួបប្រទះ។ ការស្រាវជ្រាវគឺដើម្បីស្វែងរកឫសគល់នៃបញ្ហាទាំងនេះ និងការអនុវត្តលិខិតតូបករណ៍ជាតិ និងអន្តរជាតិ ដែលមានស្រាប់ដើម្បីផ្តល់ដំណោះស្រាយសមស្របក្នុងការលើកកម្ពស់សិទ្ធិដីធ្លី និងលំនៅឋាននៅក្នុងសហគមន៍ទាំងនេះ។

បញ្ហាជាក់លាក់ ដែលសហគមន៍នីមួយៗកំពុងប្រឈមត្រូវបានសង្ខេបដូចខាងក្រោម៖

- សហគមន៍អណ្តូងតាអៀង៖ប្រជាសហគមន៍ត្រូវបាន ផាត់ចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ សហគមន៍នេះ បានត្រៀមឯកសារគ្រប់គ្រាន់ និងជជែកពីភាក្សាក្នុងចំណោមសហគមន៍ ដើម្បីស្វែងរកកិច្ចអន្តរាគមន៍ជុំវិញបញ្ហាដីធ្លី និងធ្វើផែនការកែលម្អសហគមន៍។
- សហគមន៍បឹងឈូកមានជ័យថ្មី២៖ ប្រជាសហគមន៍បានដាក់ពាក្យសុំចុះបញ្ជីដីធ្លីជាប្រព័ន្ធ ប៉ុន្តែពួកគេមិនបានទទួលដំណឹងពីអាជ្ញាធរមូលដ្ឋានទេ។ ប្រជាសហគមន៍ប្រើប្រាស់ការតស៊ូមតិដោយអហិង្សា និងបើកចំហក្នុងការជជែកជាមួយរាជរដ្ឋាភិបាល ដើម្បីទទួលបានដីធ្លី។
- សហគមន៍ថ្នាអើត៖ សហគមន៍ត្រូវបានផាត់ចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ ប្រជាពលរដ្ឋ

បានដាក់លិខិតទៅអាជ្ញាធរដើម្បីទទួលបានព័ត៌មានផ្លូវការអំពីស្ថានភាពរបស់ពួកគេ។

- សហគមន៍កៅពីរ៖ ប្រជាសហគមន៍មានទំនាស់ដីធ្លីជាមួយក្រុមហ៊ុនឯកជន។ សហគមន៍កំពុងតស៊ូមតិទាមទារសិទ្ធិកាន់កាប់ដីធ្លី ហើយបានដាក់លិខិតប្តឹងទៅអាជ្ញាធរសង្កាត់និងខណ្ឌ ប៉ុន្តែមិនមានការឆ្លើយតបជាវិជ្ជមានទេមកទល់ពេលនេះ។
- សហគមន៍ពង្រសែនជ័យ៖ សហគមន៍មិនដឹងពីស្ថានភាពដីរបស់ពួកគេ និងមិនមានសំណើរកដំណោះស្រាយបែបណាឡើយ ដោយសារមានគម្រោងមិនច្បាស់លាស់មួយអំពីការអភិវឌ្ឍផ្លូវនៅក្នុងតំបន់របស់ពួកគេ។
- សហគមន៍រស្មីសាមគ្គី៖ ប្រជាសហគមន៍ប្រឈមនឹងការបណ្តេញចេញ ឬផ្លាស់ប្តូរទីលំនៅ ដោយសារគម្រោងដែលផ្តល់មូលនិធិដោយ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន។ ពួកគេចង់ធ្វើការស្ទង់មតិតាមផ្ទះ និងការគូសផែនទី ដើម្បីធ្វើផែនការអភិវឌ្ឍន៍នៅនឹងកន្លែង ឬផ្លាស់ប្តូរទីតាំងថ្មី។
- សហគមន៍សំរោងត្បូង៖ ប្រជាសហគមន៍បានទទួលការប្រឹក្សាយោបល់ពីអាជ្ញាធរទាក់ទងនឹងស្ថានភាពរបស់ពួកគេ។ ប្រជាសហគមន៍មានអារម្មណ៍ថាងាយរងគ្រោះ ដោយសារពួកគេមិនមានផែនការច្បាស់លាស់។
- សហគមន៍ស្ត្រីក្លាហាន៖ ប្រជាសហគមន៍ភ័យខ្លាចថា ពួកគេអាចប្រឈមនឹងការបណ្តេញចេញ តែពួកគេចង់បានការអភិវឌ្ឍនៅនឹងកន្លែង។ ពួកគេបើកចិត្តសម្រាប់ការផ្លាស់ប្តូរទីតាំងជាមួយនឹងសំណងសមរម្យ។
- សហគមន៍ស្ទឹងកំបុត៖ ប្រជាសហគមន៍បានដាក់លិខិតទៅអាជ្ញាធរមូលដ្ឋាន ដើម្បីទទួលបានការអភិវឌ្ឍនៅនឹងកន្លែង ស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លី និងឬលក់ដីក្នុងតម្លៃទីផ្សារ ប៉ុន្តែអាជ្ញាធរមិនទាន់បានផ្តល់ការឆ្លើយតបនៅឡើយទេ។
- សហគមន៍ទំនប់តាថ្លាង៖ ដីប្រជាសហគមន៍ត្រូវបានចុះវាស់វែងតាមរយៈ គម្រោងចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងបានប្រគល់បង្កាន់ដៃជូនប្រជាសហគមន៍ក្នុងឆ្នាំ២០១៩ ប៉ុន្តែមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅឡើយទេ។ សហគមន៍ចង់តស៊ូមតិដើម្បីអភិវឌ្ឍន៍នៅនឹងកន្លែង។
- សហគមន៍សាមគ្គីរុងរឿង៖ សាលារាជធានីភ្នំពេញ និងមន្ទីរសុរិយោដីបានធ្វើការអង្កេតវាស់វែងដីរបស់ប្រជាសហគមន៍។ សហគមន៍ចង់បានគំរូអភិវឌ្ឍន៍ដូចគម្រោងប្រឡាយស្ទឹងមានជ័យ ដែលប្រជាពលរដ្ឋត្រូវបានអភិវឌ្ឍន៍លំនៅឋាននៅនឹងកន្លែង តាមរយៈសារាចរលេខ០៣។

ផ្អែកលើលទ្ធផលនៃការសិក្សា របាយការណ៍នេះផ្តល់នូវអនុសាសន៍ចំពោះអង្គការមិនមែនរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល និងទីភ្នាក់ងារអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាដីធ្លី និងសិទ្ធិលំនៅឋាននៅក្នុងសហគមន៍ទាំងនេះ។ លិខិតតូបករណ៍ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិត្រូវបានកំណត់ក្នុងគោលបំណងដើម្បីការអនុវត្ត និងការតស៊ូមតិ។

# សាវតា



*រូបភាពទី២៖ សហគមន៍សាមគ្គីរុងរឿង*

ភ្នំពេញ គឺជារាជធានីដែលមាននគរូបនីយកម្មយ៉ាងឆាប់រហ័ស ហើយដូចនៅក្នុងទីក្រុងជាច្រើនផ្សេងទៀត នៅប្រទេសកំពុងអភិវឌ្ឍន៍នគរូបនីយកម្មបាននាំមកនូវបញ្ហាប្រឈមដល់សហគមន៍ក្រីក្រក្នុងទីក្រុង ដែលទទួលរងនូវការចំណាយលើការអភិវឌ្ឍអចលនទ្រព្យដែលមានការគ្រប់គ្រង និងមិនមានការគ្រប់គ្រងដោយវិស័យឯកជន និងដោយរាជរដ្ឋាភិបាលតាមរយៈការបណ្តេញចេញដោយបង្ខំ និងដោយកង្វះសុវត្ថិភាពលំនៅឋាន និងដីធ្លី។ ការប៉ាន់ប្រមាណពីការសិក្សាពីមុនៗដែលធ្វើឡើងដោយអង្គការសមាគមធាងត្នោត ២៩ ៣៥៨គ្រួសារ (១៤៦ ៧៩០ នាក់) ត្រូវបានបណ្តេញចេញ នៅក្នុងទីក្រុងភ្នំពេញចន្លោះឆ្នាំ១៩៩០ និង២០១១ និងជាង១២ ០០០ គ្រួសារស្ថិតនៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញក្នុងឆ្នាំ២០១៤[1] និងទីតាំងបណ្តេញចេញចំនួន ៧៧ ទីតាំងត្រូវបានរកឃើញនៅក្នុងឆ្នាំ២០១៦[2]។ លើសពីនេះ មានការតាំងទីលំនៅចំនួន១២ទីតាំង នៅរាជធានីភ្នំពេញ កណ្តាល និងតាកែវត្រូវបានបណ្តេញចេញពីចន្លោះឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ១៩។ ទោះបីជា អាជ្ញាធរស្នើឱ្យប្រជាសហគមន៍ស្នាក់នៅផ្ទះក៏ដោយ។[3] គំរូនៃការរំលោភសិទ្ធិដូចៗគ្នានេះត្រូវបានគេសង្កេតឃើញទាក់ទងនឹងការបណ្តេញចេញ

១ អង្គការសមាគមធាងត្នោត, *តួលេខ និងការពិត# ២៤៖សហគមន៍ក្នុងរាជធានីភ្នំពេញស្ថិតនៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញ*, ឆ្នាំ២០១៤, អាចរកបាននៅ៖ https://teangtnaut.org/wp-content/uploads/2023/09/STT_Phnom-Penh-Survey_2023_KH_Final.pdf

២ អង្គការសមាគមធាងត្នោត, *របាយការណ៍សន្យាខ្យល់ ការសិក្សាលើការអភិវឌ្ឍទីតាំងបណ្តេញចេញចំនួន៧៧ ទីតាំងនៅរាជធានីភ្នំពេញ*, ២០១៦, អាចរកបាននៅ៖ https://teangtnaut.org/wp-content/uploads/2016/12/PK-Khmer-Final-formattingFINAL1-1-1.pdf

៣ អង្គការសមាគមធាងត្នោត, *ការបណ្តេញចេញ សំណង និងបំណុល ឆ្នាំ២០២៣*, អាចរកបាននៅ៖ https://teangtnaut.org/wp-content/ ploads/2023/12/Fact-and-Figure-49-50-51-KHMER-Digital-Media.pdf

ដោយបង្ខំនៃសហគមន៍ក្រីក្រនៅក្នុងទីក្រុងភ្នំពេញ និងនៅក្នុងប្រទេសកម្ពុជាជាទូទៅ រួមទាំងកង្វះដំណើរការដ៏ត្រឹមត្រូវជាលក្ខណៈប្រព័ន្ធ និងការការពារតាមនីតិវិធី សំណងមិនគ្រប់គ្រាន់ កង្វះមធ្យោបាយដោះស្រាយបណ្តឹងរបស់សហគមន៍ប្រកបដោយប្រសិទ្ធភាពសម្រាប់សហគមន៍ដែលកំពុងប្រឈមនឹងការបណ្តេញចេញ និងការប្រើប្រាស់កម្លាំងដ៏ច្រើនលើសលុប ការឃាយី ការបំភិតបំភ័យ និងឧក្រិដ្ឋកម្ម[៤]។

សហគមន៍ក្រីក្រនៅទីក្រុងនៅក្នុងរបាយការណ៍នេះ ត្រូវបានកំណត់នៅក្រោម អង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ (UN-HABITAT) ឆ្នាំ២០០៣ គឺជាការតាំងទីលំនៅ ដែលខ្វះខាតលក្ខខណ្ឌទាំងអស់ ឬមួយចំនួនដូចខាងក្រោម៖

- លំនៅឋានជាប់លាប់ និងជាអចិន្ត្រៃយ៍ដែលការពារពីលក្ខខណ្ឌអាកាសធាតុធ្ងន់ធ្ងរ។
- ទីកន្លែងរស់នៅគ្រប់គ្រាន់មានន័យថា មិនត្រូវលើសពីបីនាក់ដែលរស់នៅរួមគ្នាក្នុងបន្ទប់តែមួយ។
- ងាយស្រួលក្នុងការទទួលបានទឹកប្រើប្រាស់ដែលមានសុវត្ថិភាពក្នុងបរិមាណគ្រប់គ្រាន់ និងតម្លៃសមរម្យ។
- ការទទួលបានអនាម័យគ្រប់គ្រាន់ក្នុងទម្រង់ជាបង្គន់សាធារណៈ ឬឯកជនដោយមានចំនួនមនុស្សសមរម្យប្រើប្រាស់។
- សុវត្ថិភាពនៃការកាន់កាប់ទីលំនៅដែលការពារពួកគេពីការបណ្តេញចេញដោយបង្ខំ។

ភាពងាយរងគ្រោះ នៃការបណ្តេញចេញដោយបង្ខំ ដែលជួបប្រទះដោយសហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញមានការពាក់ព័ន្ធជាប្រវត្តិសាស្ត្រជាមួយនឹងសិទ្ធិក្នុងការទទួលបានដីធ្លី។នៅពេលដែលគ្មានកំណត់ត្រាដីធ្លី ក្រោយរបបខ្មែរក្រហម ការទាមទារតាមផ្លូវច្បាប់នានាលើអចលនវត្ថុត្រូវបានប្រកាសថា គ្មានសុពលភាពដោយរាជរដ្ឋាភិបាល ហើយដី និងផ្ទះទាំងអស់បានក្លាយជាកម្មសិទ្ធិរបស់រដ្ឋ។ទោះជាយ៉ាងណាក៏ដោយ ម្ចាស់អចលនទ្រព្យភាគច្រើន នៅក្នុងរាជធានីភ្នំពេញត្រូវបានសម្លាប់ ឬស្លាប់នៅចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ ដោយបន្សល់ទុកដី និងអគារនៅទំនេរនៅក្នុងទីក្រុង។ ពលរដ្ឋដែលត្រឡប់មកភ្នំពេញវិញបានកាន់កាប់ដី និងអគារទទេដោយឈរលើមូលដ្ឋាន "មកមុនបានមុន"។ រហូតមកដល់ឆ្នាំ ១៩៨៩ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យប្រជាជនមានសិទ្ធិកាន់កាប់អចលនទ្រព្យ និងមានសិទ្ធិលក់ និងទិញតាមតម្លៃទីផ្សារដីធ្លី និងលំនៅឋានជាក់ស្តែង។ ជាមួយនឹងការវិលត្រឡប់របស់ជនភៀសខ្លួន និងប្រជាជនដែលរស់នៅជុំវិញនៅជនបទ ការរៀបចំការរស់នៅមិនស្របច្បាប់ផ្សេងៗបានពង្រីកយ៉ាងឆាប់រហ័សនៅក្នុងទីក្រុង។[៥] ទាំងនេះត្រូវបានកំណត់ដោយទីផ្សារក្រៅផ្លូវការយ៉ាងសកម្មជាមួយនឹងការលក់ចេញទិញចូលយ៉ាងឆាប់រហ័សរួមទាំង

៤ អង្គការសហប្រជាជាតិ, Rolnik, R, *ការបណ្តេញចេញដោយបង្ខំនៅកម្ពុជាធ្វើឱ្យមនុស្សរាប់ពាន់នាក់គ្មានផ្ទះសម្បែងឆ្នាំ២០០៨ ទំព័រ ៩៨(៣)*, ឆ្នាំ២០០០, អាចរកបាននៅ៖ *https://www.ohchr.org/en/statements/2009/10/forced-evictions-cambodia-make-thousands-people-homeless-un-expert*

៥ GOV.UK, Boonyabancha , S. Homeless International. ឆ្នាំ២០០០៖ *កម្ពុជា៖ ករណីសិក្សាអំពីមូលនិធិអភិវឌ្ឍន៍សហគមន៍ក្រីក្រទីក្រុង*, អាចរកបាននៅ៖ https://assets.publishing.service.gov.uk/media/57a08d82e5274a31e00018d0/R7394paperACHR_CambodiaFINAL__June00.pdf អាចរកបាននៅ៖ https://assets.publishing.service.gov.uk/media/៥៧a០៨d៨២e៥២៧៤a៣១e០០០១៨d០/R៧៣៩៤paperACHR_CambodiaFINAL__June០០.pdf

ការអភិវឌ្ឍនូវជម្រើសលំនៅឋានចម្រុះរួមមាន លំនៅឋាននៅលើដីជួល លំនៅឋាននៅលើដីដែលកាន់កាប់ដោយម្ចាស់ លំនៅឋានសម្រាប់អាជីវកម្ម អាផាតមិន ឬផ្ទះទោលជាលក្ខណៈគ្រួសារផ្សេងទៀត ផ្ទះទម្រង់ជាបន្ទប់នៅខាងក្នុងអគារច្រើនជាន់នៅក្នុងទីក្រុង ការកាន់កាប់ផ្ទះល្វែង និងអាផាតមិនចាស់ៗ ការតាំងទីលំនៅនៅលើដំបូល ការតាំងទីលំនៅនៅជាយក្រុង និងបន្ទប់ជួល។[៦] ប្រភេទនៃការរៀបចំក្រៅផ្លូវការទាំងនេះគឺមានជាទូទៅនៅក្នុងទីក្រុងនានា នៅប្រទេសកំពុងអភិវឌ្ឍន៍ដែលបង្ហាញថាការចូលប្រើប្រាស់ដីធ្លី និងលំនៅឋានមិនស្របច្បាប់ទាំងនេះ គឺជាបទដ្ឋានជាជាងករណីលើកលែង។

ការស្ទង់មតិនៅរាជធានីភ្នំពេញបានបង្ហាញពីការថយចុះនៃចំនួនសហគមន៍ក្រីក្រនៅក្នុងទីក្រុង[៧]។ ការស្ទង់មតិនៅរាជធានីភ្នំពេញឆ្នាំ២០១៧ បានរកឃើញមានការតាំងទីលំនៅរបស់សហគមន៍ក្រីក្រក្នុងទីក្រុងចំនួន២៧៧ទីតាំងនៅរាជធានីភ្នំពេញ។ទោះយ៉ាងណាក៏ដោយនៅឆ្នាំ២០២៣[៨]ការស្ទង់មតិនៅរាជធានីភ្នំពេញ បានកំណត់ឃើញមានការតាំងទីលំនៅរបស់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញចំនួន ១៩១ទីតាំង ដែលចំនួននេះបង្ហាញថាវាបន្តនិន្នាការធ្លាក់ចុះនៅក្នុងការតាំងទីលំនៅឋានរបស់សហគមន៍ក្រីក្រក្នុងរាជធានី។ ហេតុផលនៃការធ្លាក់ចុះនេះរួមមាន ការតាំងទីលំនៅដែលកំពុងធ្វើការកែលម្អសំខាន់ៗឬការទទួលបានសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់ដែលដកពួកគេចេញ ពីចំណាត់ថ្នាក់នៃ"សហគមន៍ក្រីក្រក្នុងទីក្រុង"។ ដូចគ្នានេះផងដែរ សហគមន៍ក្រីក្រនៅតាមទីក្រុងជាច្រើន "មិនដឹងទៅរស់នៅទីកន្លែងណា" ដោយសារតែត្រូវបានបណ្តេញចេញ ហើយអ្នកខ្លះក៏បានផ្លាស់ទីទៅកន្លែងផ្សេងទៀតនៅក្នុងទីក្រុង។ដូច្នេះហើយទោះបីជាចំនួនផ្លូវការនៃ"សហគមន៍ក្រីក្រនៅទីក្រុង"មានការថយចុះក៏ដោយ ក៏នៅតែមានសហគមន៍ ក្រីក្រមួយចំនួននៅទីក្រុង ដែលកំពុងប្រឈមមុខនឹងភាពងាយរងគ្រោះ ដោយសារកង្វះសុវត្ថិភាពកាន់កាប់ដីធ្លី។

កម្រិតនៃភាពងាយរងគ្រោះដែលទាក់ទងនឹងសុវត្ថិភាពកាន់កាប់ដីធ្លីប្រែប្រួលនៅទូទាំងសហគមន៍ក្រីក្រក្នុងទីក្រុង និងអ្នករស់នៅក្នុងសហគមន៍ទាំងនេះ។ នេះអាស្រ័យលើព័ត៌មានលម្អិតនៃការកាន់កាប់របស់ពួកគេ ក៏ដូចជាឯកសារដែលពួកគេមានដើម្បីបញ្ជាក់ពីកម្មសិទ្ធិកាន់កាប់ដីធ្លី។ នៅក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ សិទ្ធិដែលមានសុវត្ថិភាពបំផុតគឺ "កម្មសិទ្ធិ" ផ្តល់សិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រងប្រើប្រាស់ និងប្រគល់ដីធ្លី និងអ្វីៗដែលជាប់ទាក់ទងនឹងដីធ្លីនោះ។យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ កម្មសិទ្ធិអាចត្រូវបានទាមទារដោយរដ្ឋ (ជាដីសាធារណៈរបស់រដ្ឋ ឬឯកជនរបស់រដ្ឋ) ដោយក្រុមហ៊ុនឯកជន ឬបុគ្គលជាដីឯកជន និងឬសហគមន៍ជនជាតិដើមភាគតិច និងវត្តអារាមជាដីសមូហភាព។[៩] សិទ្ធិទីពីរគឺ "កម្មសិទ្ធិស្របច្បាប់" ទទួលស្គាល់ជនណាម្នាក់ដែលបានកាន់កាប់ដីរបស់ពួកគេមុនពេលច្បាប់ត្រូវបានអនុម័តក្នុងខែសីហា ឆ្នាំ២០០១។ ប្រសិនបើនរណាម្នាក់ចាប់ផ្តើមកាន់កាប់ដីរបស់ពួកគេក្រោយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ប៉ុន្តែអាចបញ្ជាក់ថាពួកគេបានទិញដីពីភោគីដើមស្របច្បាប់ ការទាមទាររបស់ពួកគេក៏ស្របច្បាប់ដែរ។ ទោះជាយ៉ាងនេះក្តីច្បាប់បានចែងថាការកាន់កាប់ដីសាធារណៈរបស់រដ្ឋមិនស្របច្បាប់នោះទេ ទោះបីជាវាចាប់ផ្តើម

---

៦ អង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ Fallavier, P. *ករណីទីក្រុងភ្នំពេញ ប្រទេសកម្ពុជា៖ បញ្ហាប្រឈមនៃតំបន់អនាធិបតេយ្យឆ្នាំ២០០៣*, អាចរកបាននៅ៖ https://unhabitat.org/sites/default/files/download-manager-files/The%20Challenge%20of%20Slums%20-%20Global%20Report%20on%20Human%20Settlements%202003.pdf

៧ អង្គការសមាគមធាងត្នោត, *ការស្ទង់មតិនៅរាជធានីភ្នំពេញ៖ ការសិក្សាស្តីពីការតាំងទីលំនៅក្រីក្រនៅទីក្រុងភ្នំពេញឆ្នាំ២០១៨*, អាចរកបាននៅ៖ https://drive.google.com/file/d/1JHhuqcXJbhSfOLwZnZvtpwHTwpr1EqG6/view

៨ អង្គការសមាគមធាងត្នោត, *ការបណ្តេញចេញ សំណង និងបំណុល ឆ្នាំ២០២៣*, អាចរកបាននៅ៖https://teangtnaut.org/wp-content/uploads/2023/12/Fact-and-Figure-49-50-51-KHMER-Digital-Media.pdf

៩ ច្បាប់ភូមិបាលឆ្នាំ ២០០១

នៅពេលណាក៏ដោយ។ យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ប្រជាពលរដ្ឋដែលមិនមានសិទ្ធិជាម្ចាស់ ឬកម្មសិទ្ធិករ និងកាន់កាប់ដីសាធារណៈរបស់រដ្ឋត្រូវបានចាត់ទុកថាខុសច្បាប់ និងមិនអាចទាមទារសិទ្ធិដីធ្លីបានឡើយ។[១០] ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ គឺជាដីដែលកាន់កាប់ដោយរដ្ឋដែលសាធារណជនប្រើប្រាស់ ជាទូទៅទទួលផលប្រយោជន៍ ឬសម្រាប់ផ្តល់សេវាសាធារណៈ។ នេះរួមបញ្ចូលទាំងផ្លូវថ្នល់ សួនច្បារសាធារណៈ សាលារៀន មន្ទីរពេទ្យ និងអគាររដ្ឋបាល។ វាក៏រួមបញ្ចូលផងដែរនូវដីដែលមានប្រភពដើមពីធម្មជាតិដូចជាទន្លេ បឹង និងឆ្នេរសមុទ្រ និងតំបន់ដែលមានតម្លៃខាងបុរាណវត្ថុ ឬបេតិកភណ្ឌ។ ទាំងប្រាំងទន្លេ និងដីបម្រុងជាប់ផ្លូវត្រូវបានចាត់ទុកជាសម្បត្តិសាធារណៈរបស់រដ្ឋ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចយកជារបស់ខ្លួន ឬកាន់កាប់ដោយបុគ្គលឯកជនបានទេ ហើយការទន្ទ្រានយកដីសាធារណៈរបស់រដ្ឋ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ឬជាប់ពន្ធនាគារ។ យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ដីឯកជនរបស់រដ្ឋគឺជាដីទាំងអស់ ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ ឬជារបស់ឯកជន ឬជារបស់រួមស្របច្បាប់។ កម្មសិទ្ធិឯកជនរបស់រដ្ឋអាចជាកម្មវត្ថុនៃការលក់ ដោះដូរ ការចែកឱ្យ ឬការផ្ទេរសិទ្ធិទៅឱ្យបុគ្គលឯកជន ឬក្រុមហ៊ុនឯកជនដែលចាត់ទុកថាវាស្របតាមច្បាប់[១១]។

ដ្យាក្រាមពន្យល់ពីការចាត់ថ្នាក់ដីធ្លីនៅកម្ពុជាត្រូវបានបង្ហាញនៅខាងក្រោម។

*ក្រាហ្វិកទី១៖ ការចាត់ថ្នាក់ដីធ្លីនៅកម្ពុជាក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ (ហ្វ្លៅវើ និង ហ្គ្រីមឌីច (Flower & Grimsditch) ឆ្នាំ ២០១៤)។*




១០ ដូចខាងលើ

១១ People In Need, Flower, B and Grimsditch , M. *ការវិភាគផ្លូវច្បាប់នៃការកាន់កាប់ដីធ្លីនៅក្នុងសហគមន៍ក្រីក្រនៅទីក្រុងភ្នំពេញ សង្កាត់ ប្រាំងចំរេះ ១ ខណ្ឌឬស្សីកែវឆ្នាំ២០១៤*, អាចរកបាននៅ៖ https://www.peopleinneed.net/media/publications/562/file/1461667582-hrbsp-interactive-2.pdf

ហ្លៅវើ និង ហ្គ្រីមឌីច ( Flower and Grims ditch ) ឆ្នាំ ២០១៤ ពន្យល់ថា ក្នុងករណីជាច្រើន ប្រជាពលរដ្ឋក្រីក្រនៅទីក្រុងប្រហែលជាមិនដឹងថាការកាន់កាប់របស់ពួកគេខុសច្បាប់ ហើយប្រហែលជាបានរស់នៅលើដីរបស់ពួកគេដោយមានការដឹងឮយ៉ាងពេញទំហឹងពីអាជ្ញាធរមូលដ្ឋានដោយមិនមានបញ្ហាណាមួយឬក៏ត្រូវបានគេប្រាប់ថាពួកគេជាអ្នកកាន់កាប់ខុសច្បាប់ឡើយ។ ក្នុងករណីខ្លះ ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុងអាចមានឯកសារកាន់កាប់ដីឬកិច្ចសន្យាលក់ដីដែលមានសាក្សីជាមេភូមិ ឬមន្ត្រីឃុំ ប៉ុន្តែប្រសិនបើការកាន់កាប់របស់ពួកគេមិនស្របតាមលក្ខខណ្ឌដែលបានកំណត់ខាងលើ ពួកគេទំនងជាចាត់ទុកថាជាអ្នកកាន់កាប់ខុសច្បាប់នេះ បើយោងតាមច្បាប់។ អ្នកកាន់កាប់ខុសច្បាប់យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ អាចរួមមាន៖

- គ្រួសារដែលចាប់ផ្តើមកាន់កាប់ដីទំនេរ បន្ទាប់ពីច្បាប់ភូមិបាលត្រូវបានអនុម័ត។
- គ្រួសារដែលចាប់ផ្តើមកាន់កាប់ដីមុនពេលច្បាប់ភូមិបាលត្រូវបានអនុម័ត ប៉ុន្តែមិនបានបំពេញលក្ខខណ្ឌទាំងប្រាំនៃការកាន់កាប់ស្របច្បាប់។
- គ្រួសារដែលកំពុងកាន់កាប់ដីដែលជាកម្មសិទ្ធិស្របច្បាប់របស់អ្នកដទៃ ឬគ្រួសារដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនថានៅពេលណាដែលពួកគេចាប់ផ្តើមកាន់កាប់នោះទេ។

យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ អ្នកកាន់កាប់ខុសច្បាប់ទទួលបានការការពារមានកម្រិត ហើយថែមទាំងអាចត្រូវពិន័យ ឬដាក់ពន្ធធនាគារផងដែរ ប្រសិនបើពួកគេត្រូវបានគេរកឃើញថាបានកាន់កាប់ដីសាធារណៈរបស់រដ្ឋដោយខុសច្បាប់។ ច្បាប់ចែងថា ប្រជាពលរដ្ឋដែលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋត្រូវតែចាកចេញជាបន្ទាន់ ហើយគ្មានសិទ្ធិទទួលបានសំណងសម្រាប់ដី ឬអគារ ឬការកែលម្អណាមួយដែលបានធ្វើឡើងនៅលើដីនោះៗទេ[១២]។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ រដ្ឋមានទំនួលខុសត្រូវក្នុងការធានាសុខុមាលភាពរបស់ប្រជាពលរដ្ឋទាំងអស់ រួមទាំងប្រជាពលរដ្ឋក្រីក្រនៅរាជធានីភ្នំពេញ។ ក្នុងបរិបទនៃសហគមន៍ក្រីក្រនៅទីក្រុង ស្ថាប័នថ្នាក់ជាតិ និងក្រោមជាតិ ជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលជាស្ថាប័នទទួលបន្ទុក គ្រប់គ្រង និងអនុវត្តន៍ច្បាប់ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋក្រីក្រ ដូចជាសារាចរលេខ០៣ និងគោលនយោបាយជាតិលំនៅឋានត្រូវបានពិភាក្សាក្នុងការសិក្សានេះ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក៏ទទួលបន្ទុកលើការចុះបញ្ជីដីធ្លីក្រោមកម្មវិធីគ្រប់គ្រងដីធ្លី និងការបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចដំណាក់កាលទី១ ទី២ និងទី៣។

នៅឆ្នាំ២០១៣ ការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធបានចុះបញ្ជីក្បាលដីជាង២.២ លានក្បាលក្នុងប្រទេស ( ភាគច្រើននៅតំបន់ជនបទ ) ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋជាង ២លាននាក់ និងដោះស្រាយវិវាទដីធ្លីចំនួន១១,០០០ករណី[១៣]។ កម្មវិធីនេះក៏បានពង្រឹងយន្តការដោះស្រាយវិវាទ និងការបង្កើនសមត្ថភាពបច្ចេកទេស និងស្ថាប័នសម្រាប់រាជរដ្ឋាភិបាលកម្ពុជា[១៤]។ ទោះបីជាទទួលបានលទ្ធផលខ្លះៗក៏ដោយ ក៏ការសិក្សារបស់ ប៊ីកាល់ស្គី និងប្រ៊ែឌ ( Bugalski and Pred ) បានកំណត់កត្តាសំខាន់ពីរនៅក្នុងការរៀបចំ និងការអនុវត្តការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ ដែលមិនបាន

១២ ដូចខាងលើ

១៣ កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់, *មេរៀនដែលបានរៀនសូត្រស្តីពីការដោះស្រាយវិវាទដីធ្លីក្នុងកម្មវិធីអង្គការ GTZ នៅកម្ពុជា ឆ្នាំ១៩៩៩-២០១៦*, អាចរកបាននៅ៖ https://www.giz.de/en/search/searchresult.aspx?query=.+Lessons+learned+on+land+dispute+resolution+during+GIZ+and+GIZ+programs+in+Cambodia+1999-2016.+&send_button_search=Search

១៤ ដូចខាងលើ

ធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពកាន់កាប់ដីធ្លីគឺការមិនដោះស្រាយបញ្ហាដីធ្លីដែលកំពុងមានវិវាទ និងកង្វះតម្លាភាពរបស់រាជរដ្ឋាភិបាលក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។ កត្តាទាំងនេះអាចធ្វើឱ្យប្រជាពលរដ្ឋងាយរងគ្រោះ តាមរយៈការអនុវត្តកម្មវិធីនេះ។ ការសិក្សាជាច្រើនបានអះអាងថា កំណែទម្រង់ដីធ្លី និងក្របខ័ណ្ឌដែលណែនាំដោយម្ចាស់ជំនួយបរទេសក្នុងប្រទេសកម្ពុជាមិនបានសម្រេចនូវសុវត្ថិភាពកាន់កាប់ដីធ្លីសម្រាប់ក្រុមជនងាយរងគ្រោះនោះទេ តែតាមពិតវាត្រូវបានបង្កើតឡើងក្នុងគោលបំណង ដកហូតសិទ្ធិទទួលបានដីធ្លីដ៏មានសុវត្ថិភាពរបស់ប្រជាពលរដ្ឋរស់នៅក្នុងកន្លែងតាំងទីលំនៅមិនស្របច្បាប់ទៅវិញ [១៥]។

ការលើកឡើងទាំងនេះចង្អុលបង្ហាញពីសារៈសំខាន់នៃការគិតគូរពិចារណាលើទិដ្ឋភាពនយោបាយ ប្រសិនបើគេចង់សម្រេចបានសុវត្ថិភាពកាន់កាប់ដីធ្លីសម្រាប់ប្រជាពលរដ្ឋក្រីក្រក្នុងរាជធានីភ្នំពេញមែននោះ។

ជាការកត់សម្គាល់ ទោះបីជាប្រជាសហគមន៍ក្រីក្រមួយចំនួនក្នុងរាជធានីភ្នំពេញទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីក៏ដោយ ក៏ពួកគេខ្លះនៅតែងាយរងគ្រោះ ដោយសារបំណុល ពីកម្ចីឯកជន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ជាឧទាហរណ៍ប្រជាពលរដ្ឋក្រីក្រនៅតាមទីក្រុងជាច្រើនបានប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ពួកគេជាវត្ថុបញ្ចាំ ដើម្បីខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយមានអត្រាការប្រាក់ខ្ពស់ ហើយប្រឈមនឹងការបាត់បង់ដីដោយសារតែមិនអាចសងបំណុលបាន។ ម្យ៉ាងវិញទៀត ដោយសារភាពក្រីក្រធ្វើឱ្យ ប្រជាពលរដ្ឋក្រីក្រនៅទីក្រុងជាច្រើនគ្មានជម្រើសអ្វីក្រៅពីលក់ដីរបស់ពួកគេឡើយ។

ការសិក្សានេះផ្តោតលើការស្រាវជ្រាវលម្អិត ឱ្យឃើញថា សហគមន៍ក្រីក្រចំនួន១១ទីតាំង ដែលកំពុងប្រឈមនឹងការគំរាមកំហែងនៃការបណ្តេញចេញនៅក្នុងរាជធានីភ្នំពេញ ដោយសារតែដីធ្លីរបស់ពួកគេត្រូវបានប្រកាសថា ជាដីសាធារណៈរបស់រដ្ឋ។ ការសិក្សានេះ ពិនិត្យមើលពីប្រវត្តិដ៏ជាក់លាក់នៃសហគមន៍ក្រីក្រទាំងនេះ ក្នុងការទទួលបានសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេដែលទទួលស្គាល់ដោយរដ្ឋ និងកង្វល់របស់សហគមន៍ទាក់ទងនឹងដំណើរការតស៊ូមតិ ការចងក្រងសហគមន៍និងការអនុវត្តលិខិតូបករណ៍ស្តីពីសិទ្ធិកាន់កាប់ដីធ្លីដែលមានសម្រាប់ពួកគេដើម្បីទទួលបានសិទ្ធិកាន់កាប់ដីធ្លី។ ការសិក្សានេះក៏បង្ហាញពីករណីសិក្សាជាសកល ដែលទទួលបានជោគជ័យក្នុងការធានាសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លីសម្រាប់សហគមន៍ក្រីក្រនៅក្នុងទីក្រុងដែលមានការរីកចម្រើនយ៉ាងរហ័សនៅអាស៊ី និងភាគខាងត្បូងនៃពិភពលោក ហើយក្នុងពេលតែមួយនេះ ការសិក្សានេះក៏ចូលរួមដោះស្រាយភាពងាយរងគ្រោះជាច្រើនរបស់សហគមន៍ក្រីក្រក្នុងទីក្រុងនៅពេលដែលពួកគេជួបប្រទះនៅក្នុងរាជធានីភ្នំពេញ។

---

១៥ Grimsditch , M., & Henderson, N and Jesuit, *ស្តីអំពីអសន្តិសុខ និងវិសមភាពនៃសិទ្ធិកាន់កាប់ដីធ្លីក្នុងវិស័យដីធ្លីនៅកម្ពុជាឆ្នាំ២០០៩, ភ្នំពេញ៖ ស្ថានឆ្លងព្រំដែន មជ្ឈមណ្ឌលសិទ្ធិលំនៅឋាន និងការបណ្តេញចេញ សេវាជនភៀសខ្លួន*, អាចរកបាននៅ, http://surl.li/tgghx
-Bugalski , N., & Pre. D, *ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា៖ ការបង្កើតឱ្យមានវិសមភាពឆ្នាំ២០១០*, LRAN Briefing Paper Series, អាចរកបាននៅ៖ https://www.inclusivedevelopment.net/wp-content/uploads/២០១២/០២/LRAN-៩_Formalizing_Inequality.pdf,
-Grimsditch , M., L, Kol., & Sherchan , D. *ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា៖ ការសិក្សាលើការចុះបញ្ជីដីធ្លីជាប្រព័ន្ធក្នុងខេត្តចំនួនបីក្នុងប្រទេសកម្ពុជា និងរាជធានីឆ្នាំ២០១២*, អាចរកបាននៅ៖ http://ngoforum.org.kh/files/7d93f5c543d70a6aaca86cdeb10c92ec-Report-of-National-Workshop-on-Land-Registration-V2-Eng.pdf



រូបភាពទី៣៖ បុរសម្នាក់រស់នៅសហគមន៍សំរោងត្បូង
យកត្រីទៅលក់ ឆ្នាំ២០២៤

# គោលបំណងស្រាវជ្រាវ

## គោលបំណង

គោលបំណងនៃការសិក្សានេះគឺដើម្បីស្វែងយល់ពីបញ្ហាដីធ្លីដែលប៉ះពាល់ដល់សហគមន៍ក្រីក្រចំនួន ១១សហគមន៍នៅក្នុងរាជធានីភ្នំពេញ និងពន្យល់អំពីច្បាប់ គោលនយោបាយ និងឯកសារច្បាប់ជាតិ និងអន្តរជាតិដែលមានស្រាប់ ដើម្បីទទួលបានដំណោះស្រាយដែលអាចធ្វើទៅបានទាក់ទងនឹងបញ្ហាដីធ្លី និងសិទ្ធិមានលំនៅឋានសមរម្យសម្រាប់សហគមន៍ទាំង១១នេះ។

គោលបំណងជាក់លាក់នៃការសិក្សានេះគឺ៖

- ដើម្បីវិភាគស្ថានភាពកាន់កាប់ដីធ្លីបច្ចុប្បន្នរបស់សហគមន៍ក្រីក្រចំនួន១១ ទីតាំងក្នុងរាជធានីភ្នំពេញ
- ដើម្បីស្វែងយល់ពីស្ថានភាពនាពេលបច្ចុប្បន្នអំពីសុវត្ថិភាពកាន់កាប់ដីធ្លីរបស់សហគមន៍ក្រីក្រចំនួន១១ទីតាំង ក្នុងរាជធានីភ្នំពេញ
- ផ្តល់អនុសាសន៍ដល់អាជ្ញាធរមូលដ្ឋាន និងរាជរដ្ឋាភិបាលថ្នាក់ជាតិ ស្តីពីរបៀបធានាសុវត្ថិភាពកាន់កាប់ដីធ្លីសម្រាប់សហគមន៍ក្រីក្រចំនួន១១ទីតាំង ក្នុងរាជធានីភ្នំពេញ។

## ចំណោទបញ្ហា

- តើសហគមន៍មានបញ្ហាអ្វីខ្លះទាក់ទងនឹងសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន?
- តើមានឯកសារច្បាប់ ឬការវិភាគផ្នែកច្បាប់ណាដែលគាំទ្រដល់ការកាន់កាប់ដីធ្លី និងលំនៅឋានរបស់សហគមន៍ទាំងនេះដែរឬទេ?
- តើសមាជិកសហគមន៍ចូលរួមក្នុងសកម្មភាពការពារដីធ្លី និងលំនៅឋានរបស់ពួកគេដែរឬទេ? ហេតុអ្វីចូលរួម ឬ ហេតុអ្វីមិនចូលរួម?
- តើមានបញ្ហាប្រឈមអ្វីខ្លះដែលសហគមន៍បានជួបប្រទះក្នុងដំណើរការនៃការចូលរួមសកម្មភាពតស៊ូមតិដើម្បីទាមទារដីធ្លីរបស់ពួកគេ?
- តើការចូលរួមរបស់សហគមន៍ក្នុងការតស៊ូមតិទាមទារសិទ្ធិដីធ្លី និងលំនៅឋានមានបញ្ហាប្រឈមអ្វីខ្លះ?
- តើមានអនុសាសន៍ជាក់លាក់អ្វីខ្លះដើម្បីដោះស្រាយបញ្ហាសិទ្ធិដីធ្លី និងលំនៅឋាននៅក្នុងសហគមន៍ទាំងនេះ?

# វិធីសាស្ត្រស្រាវជ្រាវ

## ទីតាំងស្រាវជ្រាវ

គម្រោងស្រាវជ្រាវបានកំណត់គោលដៅសហគមន៍ក្រីក្រចំនួន ១១ ទីតាំងក្នុងរាជធានីភ្នំពេញ ដែលកំពុងប្រឈមនឹងអសុវត្ថិភាពដីធ្លី។ ឈ្មោះ និងទីតាំងរបស់សហគមន៍ក្រីក្រទាំងនេះត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម។

*តារាងទី១៖ ឈ្មោះ និងទីតាំងរបស់សហគមន៍ក្រីក្រក្នុងទីក្រុងដែលជាផ្នែកមួយនៃការសិក្សានេះក្នុងរាជធានីភ្នំពេញ។*

| សហគមន៍ | ភូមិ | សង្កាត់ | ខណ្ឌ |
|---|---|---|---|
| សំរោងត្បូង | សំរោងត្បូង | សំរោង | ព្រែកព្នៅ |
| ស្ទឹងកំបុត | ឡកំបោរ | ស្វាយប៉ាក | ឫស្សីកែវ |
| បឹងឈូកមានជ័យថ្មីពីរ | បឹងឈូក | និរោធន៍ | ច្បារអំពៅ |
| សាមគ្គីរុងរឿង | ភូមិប្រាំ | ផ្សារដើមថ្កូវ | ចំការមន |
| ពង្រសែនជ័យ | ទួលពង្រ | ចោមចៅទីមួយ | ពោធិ៍សែនជ័យ |
| ស្មើសាមគ្គី | ឫស្សីទីមួយ និងឫស្សីទីពីរ | ស្ទឹងមានជ័យទីបី | មានជ័យ |
| ស្ត្រីក្លាហាន | ក្រោលគោ | គីឡូម៉ែត្រទីប្រាំមួយ | ឫស្សីកែវ |
| ផ្ទាអើត | ចំពុះក្អែក | ព្រែកថ្មី | ច្បារអំពៅ |
| អណ្ដូងតាអៀង | ព្រែកថ្មី | ព្រែកថ្មី | ច្បារអំពៅ |
| ទំនប់តាថ្លាង | ចំពុះក្អែក | ព្រែកថ្មី | ច្បារអំពៅ |
| កៅពីរ | ត្រពាំងស្វាយ | គោកឃ្លាង | សែនសុខ |

## វិធីសាស្ត្រ

ការស្រាវជ្រាវបានប្រើវិធីសាស្ត្រស្រាវជ្រាវជាច្រើន ដើម្បីទទួលបានព័ត៌មានពីសហគមន៍ក្រីក្រនៅទីក្រុង។ វិធីសាស្ត្រទាំងនេះរួមមាន៖

- ការពិនិត្យឯកសារគោលនយោបាយ
- ការប្រមូលករណីសិក្សាអន្តរជាតិ
- ការពិភាក្សាជាក្រុមស្នូល ជាមួយថ្នាក់ដឹកនាំសហគមន៍ក្រីក្រនៅទីក្រុង និងសមាជិក
- ការស្ទង់មតិគ្រួសារ នៅក្នុងសហគមន៍ក្រីក្រនីមួយៗដែលជាផ្នែកមួយនៃការសិក្សានេះ។

## ការត្រួតពិនិត្យឯកសារគោលនយោបាយ

ការពិនិត្យឡើងវិញនូវគោលនយោបាយ និងកម្មវិធីជាតិនានាដែលពាក់ព័ន្ធទាក់ទងនឹងសិទ្ធិដីធ្លី និងលំនៅឋានសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុងនៅកម្ពុជា ក៏ដូចជាច្បាប់សិទ្ធិមនុស្សអន្តរជាតិត្រូវបានធ្វើឡើងដោយអ្នកស្រាវជ្រាវ។ សេចក្តីសង្ខេបនៃឯកសារគោលនយោបាយដែលត្រូវបានពិនិត្យត្រូវបានបញ្ចូលនៅក្នុងតារាងខាងក្រោម។

*តារាងទី២៖ សេចក្តីសង្ខេបនៃឯកសារគោលនយោបាយជាតិ និងអន្តរជាតិដែលបានពិនិត្យនៅក្នុងការសិក្សានេះ។*

| ឯកសារគោលនយោបាយជាតិ | ឯកសារគោលនយោបាយអន្តរជាតិ |
|---|---|
| • ច្បាប់ភូមិបាលឆ្នាំ២០០១<br>• កម្មវិធីចាត់ចែង និងគ្រប់គ្រងដីធ្លី និងការបែងចែកដីធ្លីសម្រាប់អភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច<br>• ក្រមរដ្ឋប្បវេណីកម្ពុជា ២០០៧<br>• សារាចរលេខ០៣៖ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជនឆ្នាំ២០១០)<br>• គោលនយោបាយជាតិស្តីពីលំនៅឋានឆ្នាំ២០១៤<br>• គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់អភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យឆ្នាំ២០១៧<br>• ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២០ | • សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស<br>• កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌<br>• គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការផ្លាស់ទីលំនៅដោយផ្អែកលើការអភិវឌ្ឍ<br>• គោលការណ៍ណែនាំស្តីពីសុវត្ថិភាពនៃការកាន់កាប់ដីធ្លីសម្រាប់ជនក្រីក្រនៅក្នុងទីក្រុង<br>• គោលការណ៍ណែនាំសម្រាប់ ការអនុវត្តសិទ្ធិទទួលបានលំនៅឋានគ្រប់គ្រាន់<br>• របៀបវារៈឆ្នាំ២០២៣ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព |

ហេតុផលសម្រាប់ការពិនិត្យឡើងវិញទាំងច្បាប់ស្តីពីដីធ្លី និងលំនៅឋាន គឺដោយសារតែតម្រូវការរបស់សហគមន៍ក្រីក្រក្នុងទីក្រុងពាក់ព័ន្ធទាំងដីដែលមានសុវត្ថិភាព និងទាំងលំនៅឋានសមរម្យសម្រាប់រស់នៅ។ សុខុមាលភាពរបស់គ្រួសារក្រីក្រនៅទីក្រុងគឺអាស្រ័យទាំងលើសិទ្ធិដីធ្លី និងលំនៅឋាន ដូច្នេះហើយការអន្តរាគមន៍ ណាមួយរបស់រាជរដ្ឋាភិបាល ម្ចាស់ជំនួយអន្តរជាតិ និងសង្គមស៊ីវិលគួរតែពិចារណាលើការអនុវត្តសិទ្ធិទាំងនេះឱ្យបានគ្រប់ជ្រុងជ្រោយ។ ជាមួយគ្នានេះដែរ ជាអន្តរជាតិ សិទ្ធិដីធ្លីគឺជាផ្នែកមួយនៃ "សិទ្ធិលំនៅឋាន" ដែលត្រូវបានផ្តល់សច្ចាប័នក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍ណែនាំផ្សេងៗ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការពិចារណាលើសិទ្ធិដីធ្លី និងលំនៅឋានរួមគ្នាក្នុងការអនុវត្តគោលនយោបាយ ក៏ដូចជាសកម្មភាពតស៊ូមតិផ្សេងៗ។

## ការប្រមូលករណីសិក្សាអន្តរជាតិ

ករណីសិក្សាជាអន្តរជាតិចំនួនបីទាក់ទងនឹងកម្មសិទ្ធិដីធ្លី និងលំនៅឋានដែលទទួលបានជោគជ័យសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុងត្រូវបានជ្រើសរើស និងធ្វើការវិភាគ។ គោលបំណងនៃករណីសិក្សាទាំងនេះគឺដើម្បីបង្ហាញពីលក្ខណៈនៃគំរូដ៏ជោគជ័យដែលបានអនុវត្តន៍ល្អជាអន្តរជាតិដើម្បីធានាបាននូវសុវត្ថិភាពដីធ្លី និងលំនៅឋានសមរម្យសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុង ហើយប្រើប្រាស់ករណីសិក្សានេះដើម្បីផ្តល់ជាអនុសាសន៍នៅក្នុងបរិបទនៃរាជធានីភ្នំពេញ និងស្ថានភាពនៃសហគមន៍ទាំង ១១ដែលបង្កើតបានជាផ្នែកមួយនៃការសិក្សានេះ។ ករណីសិក្សារួមមាន៖

- ការទទួលបានដីដោយអ្នកតាំងទីលំនៅមិនរៀបរយក្រោមកម្មវិធី បាងម៉ុងគង់ (Baan Mankong) ក្នុងប្រទេសថៃ
- ការទទួលបានដីធ្លី និងលំនៅឋានដោយអ្នកតាំងទីលំនៅមិនរៀបរយក្រោមគម្រោង ឌឹ ម៉ាទីន ភេណា ឆានែល ខុមម្មូនីធី លេនត្រាស់ (The Martín Peña Channel Community Land Trust, CLT) នៅប្រទេសព័រតូរីកូ (Puerto Rico)
- ការកែលម្អការតាំងទីលំនៅឋានមិនរៀបរយប្រកបដោយបរិយាប័ន្ន ដែលគាំទ្រដោយលិខិតូបករណ៍ស្តីពីការធ្វើផែនការប្រើប្រាស់ដីធ្លីក្រោមលក្ខន្តិកៈទីក្រុងនៅក្នុងប្រទេសប្រេស៊ីល (ច្បាប់សហព័ន្ធលេខ ១០.២៥៧ នៃឆ្នាំ២០០១)។

## ការពិភាក្សាជាក្រុមស្នូល

ការពិភាក្សាជាក្រុម សម្រាប់សហគមន៍នីមួយៗ ត្រូវបានធ្វើឡើងនៅក្នុងសហគមន៍គោលដៅទាំង១១។ ទាំងបុរស និងស្ត្រីមកពីគណៈកម្មការសហគមន៍ និងសមាជិកសកម្ម ដែលត្រូវបានជ្រើសរើសឱ្យចូលរួមនៅក្នុងការពិភាក្សាទាំងនេះ។

## ការស្ទង់មតិតាមគ្រួសារ

ការស្ទង់មតិគ្រួសារត្រូវបានធ្វើឡើងនៅក្នុងសហគមន៍គោលដៅនីមួយៗនៃសហគមន៍ទាំង ១១។ អ្នកចូលរួមទាំងក្នុងការពិភាក្សាក្រុមស្នូល និងការស្ទង់មតិគ្រួសារ រួមមានមនុស្សផ្សេងៗគ្នាទាក់ទងនឹងស្ថានភាពសង្គម ភេទ ជាតិសាសន៍ អាយុជាដើម។

- តំណាងសហគមន៍
- សមាជិកជាស្ត្រី
- មនុស្សចាស់ និងជនងាយរងគ្រោះក្នុងសហគមន៍
- ជនមានពិការភាព។

វិធីសាស្ត្រជ្រើសរើសសំណាកដោយចៃដន្យត្រូវបាន ប្រើដើម្បីជ្រើសរើសគ្រួសារចូលរួមក្នុងការស្រាវជ្រាវនេះ។ ដោយសារសហគមន៍គោលដៅមានមិនស្មើគ្នាក្នុងទំហំប្រជាជន សំណាកត្រូវបានយកតាមវិធីសាស្ត្រប្រូបាប៊ីលីតេសមាមាត្រទៅនឹងទំហំ[16]។ នេះមានន័យថាសំណាកចៃដន្យពីប្រព័ន្ធទិន្នន័យនៅក្នុងសហគមន៍គោលដៅត្រូវបានជ្រើសរើសដោយយកទំហំសំណាក៣០% ពីគ្រួសារសរុបនៅក្នុងសហគមន៍នីមួយៗ។

តារាងខាងក្រោមបង្ហាញពីទំហំសំណាកផ្សេងៗគ្នានៅទូទាំង ១១ សហគមន៍។

*តារាងទី៣៖ យុទ្ធសាស្ត្រយកសំណាកនៅក្នុងសហគមន៍គោលដៅចំនួន ១១សហគមន៍*

| ឈ្មោះនៃទីតាំង | ភូមិ | សង្កាត់ | ខណ្ឌ | ចំនួនគ្រួសារ | ប្រជាពលរដ្ឋសរុប | ៣០% នៃទំហំសំណាក គ្រួសារ |
|---|---|---|---|---|---|---|
| កៅពីរ | ត្រពាំងស្វាយ | គោកឃ្លាង | សែនសុខ | ១១១ | ៣៩៩ | ៣៣ |
| ពង្រសែនជ័យ | ទួលពង្រ | ចោមចៅទីមួយ | ពោធិ៍សែនជ័យ | ១៤៧ | ៤៥៩ | ៣៩ |
| សំរោងត្បូង | សំរោងត្បូង | សំរោង | ព្រែកព្នៅ | ៧៧ | ៣៥០ | ៣០ |
| ស្ទឹងកំបុត | ឡកំបោរ | ស្វាយប៉ាក | ឫស្សីកែវ | ២០៩ | ៨៤៧ | ៦៣ |
| ស្ត្រីក្លាហាន | ក្រោលគោ | គីឡូម៉ែត្រលេខប្រាំមួយ | ឫស្សីកែវ | ៣៨ | ២៧០ | ១២ |
| សាមគ្គីរុងរឿង | ភូមិប្រាំ | ផ្សារដើមថ្កូវ | មានជ័យ | ៨៤ | ៥២២ | ២៦ |
| ស្មើសាមគ្គី | ឫស្សីទីមួយនិង ឫស្សីទីពីរ | ស្ទឹងមានជ័យទីបី | មានជ័យ | ៧៣ | ២៦៣ | ២៣ |
| បឹងឈូក មានជ័យថ្មីពីរ | បឹងឈូក | និរោធន៍ | ច្បារអំពៅ | ៣៤ | ១៥០ | ១០ |
| ផ្ទះអើត | ចំពុះក្អែក | ព្រែកថ្មី | ច្បារអំពៅ | ៣២ | ១៣៨ | ១២ |
| អណ្តូងតាអៀង | ព្រែកថ្មី | ព្រែកថ្មី | ច្បារអំពៅ | ៤៧ | ២០០ | ១៦ |
| ទំនប់តាថ្លាង | ចំពុះក្អែក | ព្រែកថ្មី | ច្បារអំពៅ | ៣២ | ២០០ | ១០ |
| **សរុប** | **១១** | **៩** | **៦** | **៨៨៤** | **៣៧៩៨** | **២៧៤** |

១៦ វិធាននេះ (The rule of thumb) *គឺថា ការយកសំណាក PSS ត្រូវបានប្រើក្រោមលក្ខខណ្ឌបីដូចជា "(១) នៅពេលអ្នកកំពុងដោះស្រាយជាមួយចំនួនប្រជាជនដ៏ច្រើន និងរស់នៅរាយប៉ាយមិនស្មើគ្នា"*, អាចរកបាននៅ៖ https://cdn.who.int/media/docs/default-source/hq-tuberculosis/global-task-force-on-tb-impact-measurement/meetings/2008-03/p20_probability_proportional_to_size.pdf?sfvrsn.

# លទ្ធផលស្រាវជ្រាវ

## ការពិនិត្យឯកសារ

សិទ្ធិទទួលបានសុវត្ថិភាពដីធ្លីនិងលំនៅឋានសមរម្យ គឺជាកត្តាសំខាន់ដែលបន្តប៉ះពាល់ដល់ប្រជាជនក្រីក្រនៅក្នុងរាជធានីភ្នំពេញ។ កង្វះសុវត្ថិភាពដីធ្លីរួមចំណែកដល់ភាពក្រីក្រក្នុងទីក្រុង រួមទាំងកង្វះលំនៅឋានសមរម្យអនាម័យ ម្ហូបអាហារ និងសេវាកម្មសម្រាប់ប្រជាជនក្រីក្រនៅរាជធានីភ្នំពេញ។ ទោះបីជាមានការរីកចម្រើនក្នុងការបង្កើតគោលនយោបាយសិទ្ធិដីធ្លី និងលំនៅឋាន រួមទាំងការបង្កើនការចុះបញ្ជីដីធ្លីនៅក្នុងការតាំងទីលំនៅឋានក្រីក្រក្នុងរាជធានីក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ[១៧]ក៏ដោយ ក៏ប្រជាសហគមន៍ក្រីក្រនៅរាជធានីនៅតែបន្តជួបប្រទះនឹងបញ្ហាអសុវត្ថិភាពដីធ្លី លំនៅឋាន និងជីវភាពរស់នៅ។ បញ្ហាអសុវត្ថិភាពទាំងនេះ រួមមានការគំរាមកំហែងនៃការបណ្តេញចេញដោយបង្ខំដោយសារសម្ពាធនៃការអភិវឌ្ឍ ដូចជាការលុបបឹងក្នុងរាជធានីភ្នំពេញ ដោយសារហោងឆេងទីផ្សារ ឧទាហរណ៍ សហគមន៍ក្រីក្រ ក្នុងទីក្រុងបាត់បង់ដីដោយសារការប្រើប្រាស់វាជាវត្ថុបញ្ចាំសម្រាប់ការទទួលបានប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ ក៏ដូចជាការបង្ខំឱ្យលក់ដីរបស់ពួកគេ ដើម្បីទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុក្នុងករណីមានអាសន្នដូចជាជួបប្រទះបញ្ហាសុខភាពជាដើម[១៨]។

តារាងទី៣ ផ្តល់នូវសេចក្តីសង្ខេបនៃគោលនយោបាយនៅក្នុងប្រទេសកម្ពុជាដែលពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងលំនៅឋានសម្រាប់សហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ។ តារាងទី៤ សង្ខេបច្បាប់អន្តរជាតិសំខាន់ៗដែលទាក់ទងនឹងសិទ្ធិដីធ្លី និងលំនៅឋានសម្រាប់សហគមន៍ក្រីក្រនៅទីប្រជុំជនទូទាំងពិភពលោក ដែលពាក់ព័ន្ធនឹងករណីសហគមន៍ក្រីក្រចំនួន ១១ទីតាំង ដែលជាផ្នែកមួយនៃការសិក្សានេះ។

---

១៧ អង្គការសមាគមធាងត្នោត, *ការស្ទង់មតិក្នុងរាជធានីភ្នំពេញក្នុងឆ្នាំ ២០២៣៖ ការសិក្សាលើទីតាំងលំនៅឋានក្រីក្រនៅទីក្រុងភ្នំពេញ*, អាចរកបាននៅ៖ https://teangtnaut.org/wp-content/uploads/2023/09/STT_Phnom-Penh-Survey_2023_KH_Final.pdf

១៨ Brugman, J, *ការលោតត្រដាងអំពីគំនិតមិនស្របគ្នារបស់បុគ្គល ឬសមូហភាពនៅក្នុងការធ្វើផែនការឆ្លើយតបចំពោះការតាំងទីលំនៅមិនស្របច្បាប់ ខណៈដែលមានអសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លីនៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា និងការពិនិត្យឡើងវិញផែនការអភិវឌ្ឍអន្តរជាតឆ្នាំ២០២២*, អាចរកបាននៅ៖ https://doi.org/១០.៣៨២៨/idpr.២០២២.៥



*រូបភាពទី៥៖ ស្ត្រីចំណាស់ម្នាក់រស់នៅសហគមន៍ស្ទឹងកំបុតដើរកាត់លំនៅឋានដែលមានបាញ់ស្រ្តេក្រហម ឆ្នាំ២០២៤*

### *តារាងទី៤៖ សង្ខេបនៃគោលនយោបាយជាតិ និងលិខិតូបករណ៍អន្តរជាតិសម្រាប់សិទ្ធិដីធ្លី និងលំនៅឋានសម្រាប់ប្រជាជនក្រីក្រនៅទីក្រុងភ្នំពេញ*

| គោលនយោបាយជាតិ | | | | |
|---|---|---|---|---|
| **គោលនយោបាយ** | **ឆ្នាំ** | **ស្ថាប័នគ្រប់គ្រង** | **គោលបំណង** | **សមិទ្ធិផល និងវឌ្ឍនភាព** |
| ច្បាប់ភូមិបាល | ២០០១ | ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និង សំណង់ | ច្បាប់ភូមិបាលឆ្នាំ២០០១ ផ្តល់នូវមូលដ្ឋានច្បាប់ដើម្បីសម្រេចបាននូវការទទួលស្គាល់ស្របច្បាប់នៃសិទ្ធិកាន់កាប់ដីធ្លី ជាពិសេស មានគោលបំណងកំណត់របបនៃភាពជាម្ចាស់លើអចលនវត្ថុនៅកម្ពុជា ក្នុងគោលបំណង ធានាសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតទាក់ទងនឹង អចលនវត្ថុ។ វាក៏មានបំណងបង្កើត ប្រព័ន្ធទំនើបនៃការចុះ បញ្ជីដីធ្លីដែលធានាសិទ្ធិ របស់ប្រជាពលរដ្ឋក្នុងការកាន់កាប់ដីធ្លីផងដែរ។ | ច្បាប់ភូមិបាលឆ្នាំ២០០១ គឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការសម្រេចបាន នូវសិទ្ធិដីធ្លីសម្រាប់អ្នកក្រីក្រក្នុងទីក្រុង ដោយសារច្បាប់នេះគឺជាច្បាប់ចម្បងដែលបង្ហាញពីប្រភេទនៃសិទ្ធិកាន់កាប់ដីធ្លីក្នុងប្រទេស និង វិធាននានា អំពីរបៀបដែលប្រជាពលរដ្ឋជាច្រើនអាច ឬមិនអាចទាមទារកម្មសិទ្ធិដីធ្លី។ ច្បាប់បានបែងចែកប្រភេទនៃកម្មសិទ្ធិ ការកាន់កាប់ស្របច្បាប់ និងការកាន់កាប់ខុសច្បាប់ ហើយចាត់ថ្នាក់ដីទៅជាកម្មសិទ្ធិរដ្ឋ កម្មសិទ្ធិឯកជន និងកម្មសិទ្ធិសមូហភាព។ ដូចគ្នាផងដែរ គណៈកម្មការសុរិយោដីត្រូវបានបង្កើតឡើងក្រោមច្បាប់ភូមិបាលឆ្នាំ២០០១ ដើម្បីជួយដល់ការចុះបញ្ជីដីធ្លីនៅទូទាំងប្រទេស និងដោះស្រាយវិវាទលើដីដែលមិនបានចុះបញ្ជី។ ច្បាប់ភូមិបាលគឺជាលិខិតូបករណ៍សំខាន់សម្រាប់សហគមន៍ក្រីក្រនៅទីក្រុង និងអង្គការសង្គមស៊ីវិលដើម្បីយល់ពីស្ថានភាពដីធ្លីរបស់ពួកគេ ដោយស្របច្បាប់ និងអាចទាមទារដីជា "កម្មសិទ្ធ" ឬស្វែងរកដំណោះស្រាយជំនួសតាមរយៈ លិខិតូបករណ៍ច្បាប់ផ្សេងទៀត ក្នុងករណីដែលដីសាធារណៈត្រូវបានកាន់កាប់។ |

| | | | | |
|---|---|---|---|---|
| កម្មវិធីចាត់ចែង និងគ្រប់គ្រងដីធ្លី ឬការបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ដំណាក់កាលទី១ ទី២ និងទី៣ | ២០០២-២០០៩<br><br>២០០៨ - មកដល់បច្ចុប្បន្ន | ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ធនាគារពិភពលោក (រហូតដល់ឆ្នាំ២០០៩) | កម្មវិធីចុះបញ្ជីដីធ្លី ដើម្បីចុះបញ្ជីដីធ្លីសម្រាប់សហគមន៍ក្រីក្រនៅទីក្រុង និងជនបទ តាមរយៈការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងសម្បទានដីសង្គមកិច្ច ព្រមទាំងកសាងសមត្ថភាពសុរិយោដី ដើម្បីរក្សាបាននូវប្រព័ន្ធទិន្នន័យ នៃកំណត់ត្រាដីធ្លីក្នុងប្រទេស។ | LMAPគឺជាកម្មវិធីដំបូងដែលមានគោលបំណងចុះបញ្ជីដីធ្លីនៅតំបន់ទីក្រុង និងជនបទក្នុងប្រទេសកម្ពុជា។ក្នុងឆ្នាំ២០១៦ក្បាលដីចំនួន២.២លានត្រូវបានចុះបញ្ជីនៅក្នុងប្រព័ន្ធចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅទូទាំងប្រទេសជាមួយនឹងចំនួនក្បាលដី ១៣៤ ០៦៧ នៅរាជធានីភ្នំពេញ[១៩]។ ទោះបីជាយ៉ាងនេះក្តី កម្មវិធីចាត់ចែង និងគ្រប់គ្រងដីធ្លី (LMAP) មិនទទួលបានជោគជ័យដូចនៅក្នុងទីក្រុងភ្នំពេញនៅឡើយទេ ដោយសារតែមានជម្លោះដីធ្លី និងការបណ្តេញចេញដោយបង្ខំ ដូចជាបឹងដែលស្ថិតនៅបឹងកក់ និងការគ្រប់គ្រងកម្មវិធីមិនបានត្រឹមត្រូវដោយរាជរដ្ឋាភិបាល។ នៅឆ្នាំ២០១៦ កិច្ចសហប្រត្តិបត្តិការអាល្លឺម៉ង់(GIZ)(ដៃគូសហការដ៏សំខាន់របស់រដ្ឋលើគម្រោងនេះ) បានដកការគាំទ្រសម្រាប់ការអនុវត្តផ្ទាល់នៃកម្មវិធីចាត់ចែង និងគ្រប់គ្រងដីធ្លី (LMAP) នៅក្នុងក្រសួងដែនដី។ កិច្ចសហប្រត្តិបត្តិការអាល្លឺម៉ង់ (GIZ) បន្តផ្តល់ជំនួយមួយចំនួនដល់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងគម្រោងការបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ដំណាក់កាលទី ១, ២, ៣។<br><br>ការចុះបញ្ជីដីធ្លីសម្រាប់ប្រជាជនក្រីក្រនៅជនបទត្រូវបានគាំទ្រដោយកម្មវិធីបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ដែលផ្តល់មូលនិធិដោយធនាគារពិភពលោក។ ដំណាក់កាលបីផ្សេងគ្នានៃ កម្មវិធីត្រូវបានអនុវត្តនៅក្នុង ខេត្តជនបទក្នុងប្រទេសកម្ពុជា ហើយសហគមន៍ជនបទ និងជនជាតិដើមភាគតិចដែលបានជ្រើសរើសបានចុះបញ្ជីដីធ្លីរបស់ពួកគេដោយជោគជ័យ។ |

១៩ កិច្ចសហអាល្លឺម៉ង់, *មេរៀនដែលបានរៀនសូត្រស្តីពីការដោះស្រាយវិវាទដីធ្លីក្នុងកម្មវិធីអង្គការ GTZ នៅកម្ពុជា ឆ្នាំ១៩៩៩-២០១៦*, អាចរកបាននៅ៖ https://www.giz.de/en/search/searchresult.aspx?query=.+Lessons+learned+on+land+dispute+resolution+during+GIZ+and+GIZ+programs+in+Cambodia+1999-2016.+&send_button_search=Search

| | | | | |
|---|---|---|---|---|
| | | | | មកដល់ពេលនេះនៅរាជធានីភ្នំពេញ ការចុះបញ្ជីដីសម្រាប់លំនៅឋានបានកើតឡើងក្នុងលក្ខណៈពិសេស។ មិនមានទិន្នន័យផ្លូវការអំពីក្បាលដីពិតប្រាកដដែលបានចុះបញ្ជីនៅក្នុងទីក្រុងនោះទេ។ ការចុះបញ្ជីដីធ្លីនៅរាជធានី ភ្នំពេញ គឺជាដំណើរការនយោបាយដែលអនុគ្រោះដល់ការអភិវឌ្ឍ និងប្រជាពលរដ្ឋមួយចំនួន ជាជាងអ្នកក្រីក្រនៅទីក្រុង។ម្យ៉ាងទៀត កង្វះការចុះបញ្ជីច្បាស់លាស់ពីផលប៉ះពាល់ដីសាធារណៈលើការចុះបញ្ជីដីធ្លីសម្រាប់សហគមន៍ក្រីក្រក្នុងទីប្រជុំជន។<br><br>ការស្ទង់មតិចុងក្រោយបង្អស់នៃសហគមន៍ក្រីក្រនៅទីក្រុងដែលធ្វើឡើងដោយអង្គការសមាគមជាងត្នោត បានបង្ហាញចំនួននៃការតាំងទីលំនៅក្រីក្រក្នុងទីក្រុងដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីក្រោមការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ក្នុងរាជធានីភ្នំពេញ ជាប័ណ្ណកម្មសិទ្ធិបុគ្គលដែលបង្ហាញពីនិន្នាការថយចុះនៃការតាំងទីលំនៅក្រីក្រនៅទីក្រុងភ្នំពេញចាប់តាំងពីឆ្នាំ ២០១៤[២០] ។ |

២០ អង្គការសមាគមជាងត្នោត, *ការស្ទង់មតិក្នុងរាជធានាភ្នំពេញក្នុងឆ្នាំ ២០២៣៖ ការសិក្សាលើការតាំងទីលំនៅក្រីក្រនៅទីក្រុងភ្នំពេញ*, អាចរកបាននៅ៖ https://teangtnaut.org/wp-content/uploads/2023/09/STT_Phnom-Penh-Survey_2023_KH_Final.pdf

| | | | | |
|---|---|---|---|---|
| ក្រមរដ្ឋប្បវេណីកម្ពុជា | ២០០៧ | រាជរដ្ឋាភិបាល និង ប្រជាពលរដ្ឋខ្មែរទាំងអស់។ | ក្រមរដ្ឋប្បវេណីកម្ពុជា ត្រូវបានអនុម័តក្នុងឆ្នាំ២០០៧ ជាផ្នែកនៃដំណាក់កាលទី ១ នៃផែនការសកម្មភាពសម្រាប់ការអនុវត្ត យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលរាជរដ្ឋាភិបាល កម្ពុជា អនុវត្តន៍នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥។ | ក្រមនេះមាន១៣០៥មាត្រានិង ៩គន្ថី៖ បទប្បញ្ញត្តិទូទៅ (ទី១) បុគ្គល (ទី២) សិទ្ធិប្រត្យក្ស (ទី៣) កាតព្វកិច្ច (ទី៤) ប្រភេទជាក់លាក់នៃកិច្ចសន្យា សំខាន់អនីត្យានុកូល (ទី៥) ការធានាកាតព្វកិច្ច(ទី៦) ញាតិ (ទី៧) សន្តតិកម្ម (ទី៨) និង អវសានប្បញ្ញត្តិ (ទី៩)។<br><br>ក្រមនេះមានបទប្បញ្ញត្តិជាច្រើនស្តីពីសិទ្ធិដីធ្លី។ មាត្រា១៣៩ ស្តីពីកម្មសិទ្ធិដីធ្លី មាត្រា២១៥ ដល់ ២២៦ ស្តីពីកម្មសិទ្ធិរួម ដែលមិនអាចបំបែកបាន ដែលកំណត់ ដោយក្រមថាជាសហកម្មសិទ្ធិដោយបុគ្គលដែលមានក្បាលដីនៅជាប់គ្នាមានកម្មសិទ្ធិរួមដោយមានភាពអវិភាគលើ ជញ្ជាំង ឬកំពែងដូចជាស្នាមភ្លោះ ភ្លឺ របង ដែលនៅត្រង់ព្រំខណ្ឌដី ឬអាគារលើ ដីនោះ។ មាត្រា ២៤៣ (ការការពារភោគីដែលកាន់កាប់អចលនវត្ថុតាំងពីពេលដែលមិនទាន់ប្រកាសឱ្យប្រើច្បាប់ភូមិបាល)។ ចំពោះផលុបភោគដី ដែលមានរដូវប្រមូលផល (មាត្រា ២៥៨) និងសិទ្ធិប្រមូលផលធម្មជាតិ (មាត្រា ២៦១); និងសិទ្ធិដីធ្លីដែលបង្កើតឡើងដោយសម្បទាន (មាត្រា ៣០៧)។ |
| សារាចរលេខ០៣៖ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានីទីក្រុង និងទីប្រជុំជន ឆ្នាំ២០១០) | ឆ្នាំ២០១០ | ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋានលំនៅឋាន អាជ្ញាធរមូលដ្ឋានក្នុងតំបន់ អង្គការក្រៅ រដ្ឋាភិបាល សហគមន៍ក្រីក្រទីក្រុង មានការគាំទ្រដោយ កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) រហូតដល់ឆ្នាំ២០១៦។ | លិខិតូបករណ៍សំខាន់អាចរកបានសម្រាប់រាជរដ្ឋាភិបាលកម្ពុជា សហគមន៍ក្រីក្រនៅទីក្រុង និងអង្គការសង្គមស៊ីវិល ដើម្បីស្វែងរកដំណោះស្រាយ សម្រាប់សុវត្ថិភាពដីធ្លី សម្រាប់ការតាំងទីលំនៅបណ្តោះអាសន្ន ក្នុងរាជធានីភ្នំពេញ និងទីក្រុងធំៗផ្សេងទៀតនៅកម្ពុជា តាមរយៈការធ្វើផែនទី ការរៀបចំបញ្ជីឈ្មោះ និងលំនៅឋាន និងជម្រើសសិទ្ធិកាន់កាប់ដីធ្លី។ | ១.គម្រោងសាកល្បងនៅភ្នំពេញ សៀមរាប និងបាត់ដំបង ដើម្បីសាកល្បងបទប្បញ្ញត្តិនៃសារាចរនេះ និងប្រសិទ្ធភាពរបស់វាក្នុងការធានាដីសម្រាប់សហគមន៍ក្រីក្រនៅទីប្រជុំជនដោយមានការគាំទ្រពីកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) (រហូតដល់ឆ្នាំ២០១៦)។<br>២. សហគមន៍ស្ទឹងមានជ័យក្នុងរាជធានីភ្នំពេញបានប្រើប្រាស់សារាចរនេះដើម្បីយល់ព្រមលើការផ្លាស់ទីលំនៅនៅនឹងកន្លែង និងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី និងការតភ្ជាប់ទឹកស្អាត។ |

| | | | | |
|---|---|---|---|---|
| | | | | រវាងឆ្នាំ២០១៨-២០២០ សហភាពអឺរ៉ុបបានគាំទ្រកម្មវិធីធ្វើឱ្យប្រសើរឡើងដល់ទីធ្លាសាធារណៈ និងបរិក្ខារនានាក្នុងសហគមន៍ស្ទឹងមានជ័យ ប៉ុន្តែមិនទាន់មានការបង្កើតយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ការកែលម្អផ្ទះនីមួយៗនោះទេ។ |
| គោលនយោបាយជាតិស្តីពីលំនៅឋាន | ឆ្នាំ២០១៤ | ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋានលំនៅឋាន | គោលនយោបាយគឺជាឯកសារផ្លូវការដំបូងគេដែលផ្តោតលើយុទ្ធសាស្ត្រដែលត្រូវធ្វើដើម្បីផ្តល់លំនៅឋានតម្លៃសមរម្យនៅកម្ពុជាទាំងតាមរយៈកម្មសិទ្ធិ និងការជួល។ វិសាលភាពនៃគោល នយោបាយនេះគឺទូលំទូលាយ និងដើរតួជាក្របខ័ណ្ឌដើម្បីណែនាំសកម្មភាពផែនការអភិវឌ្ឍន៍លំនៅឋានសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ មិនមែនតែអ្នកក្រីក្រក្នុងទីក្រុងប៉ុណ្ណោះនោះទេ។ | ចាប់តាំងពី ការអនុម័តគោលនយោបាយលំនៅឋាន បានផ្តោតលើការអនុញ្ញាតឱ្យមាន ការវិនិយោគឯកជន សម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ។ |
| គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើត កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ | ឆ្នាំ២០១៧ | ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អគ្គនាយកដ្ឋានលំនៅឋាន អ្នកអភិវឌ្ឍន៍ ឯកជន | គោលនយោបាយនេះ បង្កើតក្របខណ្ឌគាំទ្រការអភិវឌ្ឍលំនៅឋាន តម្លៃចន្លោះពី ១៥ ០០០ ដុល្លារ ទៅ ៣០ ០០០ ដុល្លារអាមេរិក។ អ្នកអភិវឌ្ឍន៍សាងសង់យ៉ាងហោចណាស់បុរីដែលមាន ១០០ខ្នង នៅក្នុងតម្លៃចន្លោះនេះ ចម្ងាយជាអតិបរមា ២០ គ.មពីកណ្តាលរាជធានី ហើយរៀបចំជាកន្លែងបៃតង និងទីកន្លែង សហគមន៍ នៅក្នុងដីអភិវឌ្ឍន៍ អ្នកទាំងនេះអាចទទួលបាន អត្ថប្រយោជន៍ពី "ការលើកទឹកចិត្ត" ដូចជា សម្បទានពន្ធ ការចូលប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម និងការសម្របសម្រួលនៃនីតិវិធីការិយាធិបតេយ្យដើម្បីទទួលបានលិខិតអនុញ្ញាតសាងសង់ អាជ្ញាប័ណ្ណអាជីវកម្ម និងឯកសារចាំបាច់ផ្សេងទៀត សម្រាប់ការអភិវឌ្ឍ ជាលក្ខណៈឯកជន។ | គម្រោងសាកល្បង នៅខេត្តកណ្តាល (គម្រោង Worldbridge homes Co Ltd) និងរាជធានីភ្នំពេញ (The Arakawa Residences) ត្រូវបានសាងសង់។ |

| | | | | |
|---|---|---|---|---|
| | | | អ្នកអភិវឌ្ឍន៍ក៏ត្រូវតែសហការជាមួយស្ថាប័នហិរញ្ញវត្ថុផងដែរ។ ស្ថាប័នផ្តើរបេបឥណទានដែលមាន អត្រាការប្រាក់ទាបសម្រាប់អ្នកចូលរួមដែលមានសិទ្ធិ។ នៅក្រោមគោលនយោបាយលើកទឹកចិត្តនេះ អង្គការសង្គមស៊ីវិលក៏ត្រូវបានលើកទឹកចិត្តឱ្យវិនិយោគលំនៅឋានក្នុងតម្លៃសមរម្យផងដែរ។ | |
| សារាចរលេខ០៦៖ ស្តីពីវិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ | ២០១៩ | រាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សារាចរលេខ០៦ នេះដែរគឺបានបង្ហាញពីគោលបំណងរបស់រដ្ឋាភិបាលក្នុងការដោះស្រាយនូវបញ្ហាភាពក្រីក្រ ដោយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការសាធារណៈ ដែលមានភាពលំបាកដោយសារពុំមានលំនៅឋានច្បាស់លាស់សម្រាប់រស់នៅ និងសម្រាប់ជីវភាព ព្រមទាំងដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋប្រកបដោយប្រសិទ្ធភាព។ | តាមរយៈសារាចរនេះ ការផ្តល់ជូននេះត្រូវគោរពនូវលក្ខខណ្ឌចំនួនពីរដូចខាងក្រោម៖<br>ទី១ ប្រជាពលរដ្ឋ ឬមន្ត្រីរាជការ ដែលមានប្រវត្តិ និងអត្តសញ្ញាណតាំងទីលំនៅ និង/ឬ អាស្រ័យផលលើដីនោះយ៉ាងតិច១០ឆ្នាំ និងកំណត់ឆ្នាំចុងក្រោយគិតត្រឹមឆ្នាំ២០១៥ និងដោយមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច។ នេះទំនងជាមានន័យថា ការដោះស្រាយគឺចំពោះអ្នកដែលកាន់កាប់ដីធ្លីចាប់ពីឆ្នាំ២០១៥ ចុះមកក្រោម តែចំពោះអ្នកកាន់កាប់ដីក្នុងឆ្នាំបន្ទាប់ចាប់ពីឆ្នាំ ២០១៥ ទៅ គឺមិនទទួលបានការដោះស្រាយនោះទេ។<br>ទី២ ជាប្រជាពលរដ្ឋ ឬ មន្ត្រីរាជការក្រីក្រមានជីវភាពខ្វះខាតពិតប្រាកដ និងមិនមានដី ឬផ្ទះជាកម្មសិទ្ធិផ្សេងទៀត។ ការកំណត់ពីទំហំដី ឬលំនៅឋានសម្រាប់ប្រទានកម្ម គឺត្រូវធ្វើឡើងដោយអាជ្ញាធររបស់រដ្ឋ និងដោយតម្លាភាព ព្រមទាំងឈរលើគោលការណ៍សមធម៌។ ក្រោយការកាន់កាប់លើដីដែលរដ្ឋបានផ្តល់ជូនរយៈពេល៥ឆ្នាំ ទើបអាចស្នើសុំវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបាន ដោយអនុលោមទៅតាមគោលការណ៍ផ្តល់សម្បទានដីសង្គមកិច្ច។<br>ផ្អែកលើសារាចរនេះ ប្រជាពលរដ្ឋ ឬមន្ត្រីរាជការដែលក្រីក្រ រស់នៅលើទ្រព្យសម្បត្តិរដ្ឋ អាចទទួលបាននូវសិទ្ធិកម្មសិទ្ធិ តាមរយៈល័ក្ខខ័ណ្ឌដែលមានក្នុងសារាចរនេះ។ |

| | | | | |
|---|---|---|---|---|
| ច្បាប់ស្តីពីការ គ្រប់គ្រងការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ | ឆ្នាំ២០២០ | រាជរដ្ឋាភិបាល | ច្បាប់នេះមានគោល បំណងគ្រប់គ្រងការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទ។ គោលបំណងនៃច្បាប់នេះគឺដើម្បី ពង្រឹងក្របខណ្ឌច្បាប់ និងរចនាសម្ព័ន្ធស្ថាប័ន ក៏ដូចជាពង្រឹងសមត្ថភាពគ្រប់គ្រង ទ្រព្យ សម្បត្តិរដ្ឋ រួមទាំងការកំណត់ប្រភព និងប្រភេទនៃទ្រព្យ សម្បត្តិរដ្ឋ របបច្បាប់ ការរៀបចំសារពើភ័ណ្ឌដីរដ្ឋ។ ការផ្ទេរសិទ្ធិការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ ការត្រួតពិនិត្យ និងសវនកម្ម និងការកំណត់ការលើកទឹកចិត្ត និងការផាកពិន័យចំពោះការរំលោភបំពាន ។ល។ | បុគ្គលិករបស់រដ្ឋបាល ក្រុងស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់។ ក្រុមការងារនេះកំពុងធ្វើការកំណត់អត្តសញ្ញាណ ធ្វើផែនទីដីសាធារណៈរបស់រដ្ឋក្នុងរាជធានីភ្នំពេញ។ |



*រូបភាពទី៥៖ លំនៅឋាននៅក្នុងសហគមន៍អណ្តូងតាអៀង*

*តារាងទី៥៖ សង្ខេបលិខិតូបករណ៍អន្តរជាតិស្តីពីសិទ្ធិដីធ្លី និងលំនៅឋានសម្រាប់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ*

| លិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងលំនៅឋាន | | | | |
|---|---|---|---|---|
| **លិខិតូបករណ៍** | **ឆ្នាំ** | **ស្ថាប័នគ្រប់គ្រង** | **គោលបំណង** | **ភាពពាក់ព័ន្ធក្នុង បរិបទនៃរាជធានី ភ្នំពេញ** |
| សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស | ឆ្នាំ១៩៤៨ | អង្គការសហប្រជាជាតិ | មាត្រា២៥ ទទួលស្គាល់សិទ្ធិទទួលបានលំនៅឋានគ្រប់គ្រាន់ជាសិទ្ធិមនុស្ស និងជាផ្នែកមួយនៃស្តង់ដារស់នៅគ្រប់គ្រាន់។<br><br>សិទ្ធិទទួលបានលំនៅឋានគ្រប់គ្រាន់ទាក់ទងនឹងសិទ្ធិទទួលបានរួមមាន៖<br>សុវត្ថិភាពនៃ សិទ្ធិកាន់កាប់<br>១. លំនៅឋានដីធ្លី និងសំណងទ្រព្យសម្បត្តិ។<br>២. សិទ្ធិទទួលបាន លំនៅឋានសមរម្យ និងស្មើភាពគ្នា និងមិនរើសអើង។<br>៣. ការចូលរួមក្នុងការ សម្រេចចិត្តទាក់ទងនឹងលំនៅឋាននៅថ្នាក់ជាតិ និងសហគមន៍។<br><br>សិទ្ធិទទួលបាន លំនៅឋានគ្រប់គ្រាន់ទាក់ទងនឹងសេរីភាពរួមមាន៖<br>១. ការការពារ ប្រឆាំង នឹងការបណ្តេញ ចេញដោយបង្ខំ និងការបំផ្លិចបំផ្លាញ និងការរុះរើផ្ទះដោយបំពាន។<br>២. សិទ្ធិ រួចផុតពីការជ្រៀតជ្រែកតាមអំពើចិត្តទៅក្នុងផ្ទះរបស់បុគ្គលណាមួយ ឯកជនភាព និងគ្រួសាររបស់ បុគ្គលណាម្នាក់។<br>៣. សិទ្ធិ ក្នុងការជ្រើសរើសលំនៅឋាន ដើម្បីកំណត់ទីកន្លែងរស់នៅ និងសេរីភាពក្នុងការធ្វើដំណើរ | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិ មនុស្សគឺជាលិខិតូបករណ៍ដ៏សំខាន់នៃច្បាប់សិទ្ធិមនុស្សដែលបង្ហាញពីសិទ្ធិ មនុស្សជាមូលដ្ឋាន ដែលរាជរដ្ឋាភិបាលត្រូវតែធានាសម្រាប់ប្រជាពលរដ្ឋគ្រប់រូប និងអាចប្រើប្រាស់ ដើម្បីតស៊ូមតិទាមទារសិទ្ធិដីធ្លី និងលំនៅឋាន សម្រាប់ជនក្រីក្រនៅទីក្រុងភ្នំពេញ។ |

| | | | | |
|---|---|---|---|---|
| កតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ | ឆ្នាំ១៩៦៦ | អង្គការសហប្រជាជាតិ | មាត្រា១១ ទទួលស្គាល់សិទ្ធិទទួលបានលំនៅឋានសមរម្យ (រួមទាំងសុវត្ថិភាពនៃការកាន់កាប់) ដែលជាផ្នែកមួយនៃបទដ្ឋាននៃការរស់នៅសមរម្យជាមនុស្ស | កតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជា លិខិតូបករណ៍សំខាន់នៃច្បាប់សិទ្ធិមនុស្ស ដែលចែងអំពីសិទ្ធិមនុស្សជាមូលដ្ឋាន ដែលរាជរដ្ឋាភិបាលត្រូវតែធានាសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ហើយអាចប្រើប្រាស់ដើម្បីតស៊ូមតិទាមទារសិទ្ធិដីធ្លី និងលំនៅឋាន សម្រាប់សហគមន៍ក្រីក្រនៅរាជធានីភ្នំពេញ។ |
| គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការ បណ្តេញចេញ និងការផ្លាស់ទីលំនៅដោយផ្អែកលើការអភិវឌ្ឍ | ឆ្នាំ២០០៧ | អង្គការសហប្រជាជាតិ | គោលការណ៍ណែនាំទាំងនេះ មានគោលបំណងជួយរដ្ឋក្នុងការបង្កើតគោលនយោបាយ និងច្បាប់ ដើម្បីការពារការបណ្តេញចេញដោយបង្ខំនៅក្នុងប្រទេស។ គោលការណ៍ទាំងនេះបញ្ជាក់កាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋមុន និងអំឡុងពេល និងក្រោយការបណ្តេញចេញ ដំណោះស្រាយសម្រាប់ការបណ្តេញចេញដោយបង្ខំ ដូចជា សំណង ការជួសជុលឡើងវិញ និងការប្រគល់មកវិញការតាំងលំនៅថ្មី និងការស្តារនីតិសម្បទា ការត្រួតពិនិត្យការវាយតម្លៃ និងការតាមដានកាតព្វកិច្ចរបស់អង្គការអន្តរជាតិ។ | គោលការណ៍ណែនាំនេះ មានព័ត៌មានអំពីកាតព្វកិច្ចរបស់រដ្ឋទាក់ទងនឹងការបណ្តេញចេញដោយបង្ខំ ដែលអាចប្រើជាឧបករណ៍តស៊ូមតិក្នុងរាជធានីភ្នំពេញដើម្បីធានាថារដ្ឋគោរពតាមបទដ្ឋានអន្តរជាតិ និងសិទ្ធិមនុស្ស។ |

| | | | | |
|---|---|---|---|---|
| គោលការណ៍ណែនាំស្ដីពីសុវត្ថិភាពនៃការកាន់កាប់សម្រាប់សហគមន៍ក្រីក្រក្នុងទីប្រជុំជន | ឆ្នាំ២០១៤ | អង្គការសហប្រជាជាតិ | អង្គការសហប្រជាជាតិ គោលការណ៍ណែនាំទាំងនេះផ្ដល់ការណែនាំ អំពីស្តង់ដារសិទ្ធិមនុស្សដែលមានស្រាប់ ដោយសារវាទាក់ទងនឹងលំនៅឋាន និងការកាន់កាប់ដីធ្លី។ វាគ្របដណ្ដប់ លើប្រធានបទដូចខាងក្រោម៖<br>១. ការពង្រឹងទម្រង់កាន់កាប់ចម្រុះ<br>២. ការកែលម្អសុវត្ថិភាពនៃសិទ្ធិកាន់កាប់<br>៣.ការផ្ដល់អាទិភាពដល់ដំណោះស្រាយ លើទីតាំងដើម<br>៤. ការលើកកម្ពស់ មុខងារសង្គមនៃទ្រព្យសម្បត្តិ<br>៥. ការប្រយុទ្ធប្រឆាំងនឹងការរើសអើងដោយផ្អែកលើសិទ្ធិកាន់កាប់<br>៦.លើកកំពស់សុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លីរបស់ស្ត្រី<br>៧.ពង្រឹងអំណាចដល់ប្រជាជនក្រីក្រនៅទីក្រុង និងដាក់ឱ្យរដ្ឋទទួលខុសត្រូវ<br>៨. ធានាសិទ្ធិទទួលបានយុត្តិធម៌ | គោលការណ៍ណែនាំនេះមានព័ត៌មានអំពីគោលការណ៍ដែលអាចត្រូវបានគាំទ្រដោយរដ្ឋ ដើម្បីធានាបាននូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លីសម្រាប់ជនក្រីក្រនៅទីក្រុង។ គោលការណ៍ណែនាំគឺជាឧបករណ៍ដ៏សំខាន់ ដែលអាចជួយអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ស្នើសុំឱ្យរដ្ឋទទួលខុសត្រូវក្នុងការធានាឱ្យជនក្រីក្រនៅទីក្រុងមានសុវត្ថិភាពកាន់កាប់ដីធ្លី។ ប៉ុន្តែក៏ធ្វើការតស៊ូមតិសម្រាប់ជម្រើសកាន់កាប់ចម្រុះផ្សេងទៀត (ដូចជាលិខិតូបករណ៍កាន់កាប់ដីសមូហភាព) នៅក្នុងកម្មវិធីសិទ្ធិដីធ្លី ដែលសមស្របជាសម្រាប់អ្នកក្រីក្រនៅរាជធានី ជាជាងការទទួលបានតែប័ណ្ណកម្មសិទ្ធិផ្ទាល់ខ្លួនប៉ុណ្ណោះ។ |
| សេចក្តីណែនាំ សម្រាប់ការអនុវត្ត សិទ្ធិទទួលបានលំនៅឋានសមរម្យ | ឆ្នាំ២០២០ | អង្គការសហប្រជាជាតិ | គោលការណ៍ណែនាំ ទាំងនេះបង្ហាញអំពីធាតុសំខាន់ៗសម្រាប់រដ្ឋ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្សេងទៀត ដែលចាំបាច់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃសិទ្ធិទទួលបានលំនៅឋាន។ គោលការណ៍ណែនាំលេខ៧ ទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងនូវការតាំងទីលំនៅក្រៅផ្លូវការដោយប្រើវិធីសាស្ត្រសិទ្ធិមនុស្ស។ | គោលការណ៍ណែនាំ ទាំងនេះបង្ហាញអំពីធាតុសំខាន់ៗសម្រាប់រដ្ឋ អាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្សេងទៀត ដែលចាំបាច់សម្រាប់ការអនុវត្តប្រកបដោយ ប្រសិទ្ធភាពនៃសិទ្ធិ ទទួលបានលំនៅឋាន។ គោលការណ៍ណែនាំ លេខ ៧ ទាក់ទងនឹងការធ្វើឱ្យប្រសើរឡើងនូវការតាំងទីលំនៅក្រៅផ្លូវការដោយប្រើវិធីសាស្ត្រសិទ្ធិមនុស្ស។ |

| | | | | |
|---|---|---|---|---|
| របៀបវារៈ ២០២៣ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | ឆ្នាំ២០២៣ | អង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជា | របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព រួមមានគោលដៅ អភិវឌ្ឍន៍ប្រកបដោយ និរន្តរភាព គោលដៅទី១១ ដើម្បីធ្វើឱ្យទីក្រុង និងការតាំងទីលំនៅ របស់មនុស្សមានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព មានភាពធន់ និងមាននិរន្តរភាព។<br><br>នៅក្រោមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី ១១.១ រដ្ឋបានប្រកាសដើម្បី ធានា "នៅឆ្នាំ ២០៣០ [...] លទ្ធភាពទទួលបានសម្រាប់ទាំងអស់គ្នានូវលំនៅឋានតម្លៃសមរម្យ និងសេវាមូលដ្ឋានសមរម្យ និងអាចលៃលកបាន និងធ្វើឱ្យប្រសើរឡើងនូវតំបន់មិនរៀបរយ"។ | ប្រទេសកម្ពុជា ជារដ្ឋសមាជិក ដែល បានផ្តល់សច្ចាប័នលើរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដូច្នេះហើយប្រទេសកម្ពុជាប្តេជ្ញាចិត្តខិតខំអនុវត្តរបៀបវារៈនេះ។ |

ការពិនិត្យឡើងវិញនេះបានពន្យល់អំពីសាវតានៃលិខិតូបករណ៍គោលនយោបាយនៅក្នុងប្រទេសកម្ពុជាទាក់ទងនឹងសិទ្ធិដីធ្លី និងលំនៅឋានដែលពាក់ព័ន្ធសម្រាប់សហគមន៍ទាំង១១ ដែលជាផ្នែកមួយនៃការសិក្សានេះ។ សហគមន៍ចំនួន១១ ដែលបានចូលរួមក្នុងការសិក្សានេះ កាន់កាប់ដីសាធារណៈមួយចំនួនដូចជា ផ្លូវបេម្រុង ឬប្រាំងទន្លេ ដូច្នេះហើយត្រូវបានចាត់ទុកថាខុសច្បាប់ក្រោមច្បាប់ភូមិបាលឆ្នាំ២០០១។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែមិនមានការបញ្ជាក់ច្បាស់លាស់ក្នុងការចុះបញ្ជីដីសាធារណៈនៅក្នុងរាជធានីភ្នំពេញ វាមិនច្បាស់ទេចំពោះសហគមន៍ទាំងនោះថា តើពួកគេពិតជាតាំងទីលំនៅខុសច្បាប់មែន ឬមួយយ៉ាងណា ហើយត្រូវផ្អែកលើអ្វីជាពិតប្រាកដដែលថាដីនោះជាដីសាធារណៈ ហើយតើមានជម្រើសអ្វីខ្លះសម្រាប់សហគមន៍ទាំងនោះក្នុងការស្វែងរកដំណោះស្រាយចំពោះស្ថានភាពរបស់ពួកគេ។ ដូចដែលបានរកឃើញនៅក្នុងលទ្ធផលនៃការពិភាក្សាជាក្រុម ការចុះបញ្ជីដីធ្លី ការស្ទង់មតិគ្រួសារនៅក្នុងសហគមន៍ទាំងនេះបានធ្វើឡើងតាមការចាំបាច់ប៉ុណ្ណោះ ហើយសូម្បីតែសហគមន៍មួយចំនួនការចុះបញ្ជីរបស់ពួកគេត្រូវបានរដ្ឋទុកជាមោឃៈដោយសារតែពួកគេកាន់កាប់ដីសាធារណៈ។ ដូច្នេះហើយ សហគមន៍កំពុងស្ថិតក្នុងការគំរាមកំហែងឥតឈប់ឈរនៃការបណ្តេញចេញ និងអសុវត្ថិភាពកាន់កាប់ដីធ្លី។ ក្រៅពីច្បាប់ជាមូលដ្ឋាន ដូចជាក្រមរដ្ឋប្បវេណីកម្ពុជាដែលធានាថាសិទ្ធិជាមូលដ្ឋានលើដីធ្លី ត្រូវបានគោរពសម្រាប់បុគ្គលនានាក្នុងប្រទេស ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២០ក៏ដូចជាសារាចរលេខ០៣ គឺជាលិខិតូបករណ៍ដ៏សំខាន់ដែលសហគមន៍គួរយល់ដឹង និងប្រើប្រាស់ដើម្បីបន្តការស្នើសុំ និងធ្វើផែនការសម្រាប់កែលម្អលំនៅឋានរបស់ពួកគេ និងទាំងជម្រើសផ្លាស់ប្តូរទីលំនៅដែលត្រូវចរចាជាមួយរាជរដ្ឋាភិបាល។

ដូចគ្នាផងដែរ តាមរយៈឯកសារផ្លូវច្បាប់ និងគោលនយោបាយខាងលើនេះបង្ហាញថា បច្ចុប្បន្នរាជរដ្ឋាភិបាលមិនមានផែនការដាក់លាក់ណាមួយដើម្បីផ្តល់លំនៅឋានសង្គម សម្រាប់ដោះស្រាយតម្រូវការជាក់លាក់របស់សហគមន៍ក្រីក្រក្នុងទីក្រុងដែលរស់នៅក្នុងស្ថានភាពមិនស្របច្បាប់ឡើយ។ ពួកគេត្រូវការនូវគោលនយោបាយលំនៅឋានកាន់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយបញ្ហាអសុវត្ថិភាពដីធ្លី និងលំនៅឋានដែលប្រជាសហគមន៍ក្រីក្រនៅរាជធានីភ្នំពេញជួបប្រទះ ពោលគឺគោលនយោបាយដែលផ្តោតតែលើបច្ចេកទេសនៃការចុះបញ្ជីដីធ្លីប៉ុណ្ណោះដែលដោះស្រាយតម្រូវការភាពក្រីក្រផ្សេងៗរបស់ប្រជាសហគមន៍ក្រីក្រក្នុងទីក្រុងក្រោម "សិទ្ធិមានលំនៅឋាន"។

លិខិតូបករណ៍ សិទ្ធិមនុស្សអន្តរជាតិដែលត្រូវបានពិនិត្យនៅក្នុងការសិក្សានេះ ពន្យល់អំពីបទដ្ឋានអន្តរជាតិទាក់ទងនឹងសិទ្ធិដីធ្លីនិងលំនៅឋានសម្រាប់ប្រជាសហគមន៍ក្រីក្រនៅទីក្រុងទូទាំងពិភពលោក។ វាមានសារៈសំខាន់ក្នុងការគូសបញ្ជាក់លិខិតូបករណ៍ទាំងនេះនៅក្នុងបរិបទនៃស្ថានភាពនៃសហគមន៍ក្រីក្រចំនួន ១១សហគមន៍ដែលជាផ្នែកមួយនៃការសិក្សានេះ ដោយសារលិខិតូបករណ៍ទាំងនេះ ផ្តល់ជាឯកសារយោងទាក់ទងនឹងសិទ្ធិមាន "លំនៅឋានសមរម្យ" ដែលជាសិទ្ធិមនុស្សជាមូលដ្ឋាន ដែលរដ្ឋគួរតែធានាសម្រាប់ប្រជាពលរដ្ឋគ្រប់រូប នៅទូទាំងពិភពលោក។ លិខិតូបករណ៍ទាំងនេះ អាចប្រើប្រាស់ក្នុងគោលបំណងតស៊ូមតិ ដើម្បីដាក់ឱ្យរាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះតម្រូវការក្នុងការផ្តល់ដំណោះស្រាយលំនៅឋានសមរម្យសម្រាប់សហគមន៍ទាំង១១ ដែលជាផ្នែកមួយនៃការសិក្សានេះ។ លើសពីនេះ គោលការណ៍ណែនាំដូចជា គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការផ្លាស់ប្តូរទីលំនៅដោយផ្អែកលើការអភិវឌ្ឍផ្តល់ការណែនាំអំពីរបៀបគ្រប់គ្រងដំណើរការទាំងនេះ និងការរំលោភបំពានលើការបណ្តេញចេញ ដែលប៉ះពាល់ដល់សិទ្ធិមនុស្ស។ ដូចគ្នាផងដែរគោលការណ៍ណែនាំជាក់ស្តែងផ្សេងទៀតដូចជា គោលការណ៍ណែនាំស្តីពីសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីសម្រាប់ប្រជាសហគមន៍ក្រីក្រក្នុងទីក្រុង និងគោលការណ៍ណែនាំសម្រាប់ការអនុវត្តសិទ្ធិទទួលបានលំនៅឋានសមរម្យផ្តល់នូវអនុសាសន៍ជាក់ស្តែង សម្រាប់រាជរដ្ឋាភិបាល និងសង្គមស៊ីវិលលើយុទ្ធសាស្រ្តផ្សេងៗគ្នា ដែលអាចយកមកអនុវត្តន៍ ដើម្បីសម្រេចបាននូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងសិទ្ធិមានលំនៅឋានសមរម្យសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុង ដូចជាការទទួលស្គាល់ និងការអនុវត្តគម្រូកាន់កាប់ដីធ្លីចម្រុះមិនត្រឹមអចលនទ្រព្យបុគ្គលប៉ុណ្ណោះនោះទេ។

# ករណីសិក្សាអន្តរជាតិ

## ករណីសិក្សាទី១៖ សិទ្ធិទទួលបានដីក្រោមកម្មវិធី The Baan Mankong Upgrading Program

កម្មវិធីកែលម្អនៅឋាននៅតំបន់មិនរៀបរយនៅ បានមេគង្គ (Baan Mankong) ដែលគ្រប់គ្រងដោយវិទ្យាស្ថានអភិវឌ្ឍន៍ការងារចងក្រងសហគមន៍របស់រាជរដ្ឋាភិបាលថៃ គឺជាកម្មវិធីលំនៅឋាននិងដីធ្លីដែលដឹកនាំដោយសហគមន៍ ហើយសហគមន៍ក្រីក្រដែលបានចងក្រងទាំងនេះ អាចទទួលបានប្រាក់កម្ចីជាសមូហភាពដែលមានការប្រាក់ទាបដើម្បីទិញដី ដើម្បីធ្វើការកែលម្អលំនៅឋាន និង ឬ គម្រោងបង្កើតប្រាក់ចំណូល។ វិទ្យាស្ថាននេះ គាំទ្រសហគមន៍ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដែលអាចបត់បែនបានក៏ដូចជាការភ្ជាប់បណ្តាញសហគមន៍ក្រីក្រទាំងនេះ ទៅសហគមន៍ផ្សេង

ទៀតនៅក្នុងប្រទេស និងក្រៅប្រទេស។ តាមរយៈការផ្តល់នូវព័ត៌មាន ហិរញ្ញវត្ថុ ការធ្វើសកម្មភាពជាសមូហភាព និងមានអំណាចនៃការធ្វើសេចក្តីសម្រេចចិត្ត កម្មវិធី នេះ អនុញ្ញាតឱ្យសហគមន៍ក្រីក្រក្នុងទីក្រុង មានការពិភាក្សាគ្នាដ៏ពិតប្រាកដអំពីអនាគតរបស់ពួកគេ និងដោះស្រាយតម្រូវការភាពក្រីក្រផ្សេងៗតាមរយៈដីធ្លី និងលំនៅឋាន។

## ករណីសិក្សាទី២៖ គម្រោង ឪ ម៉ាទីន កេណា ឆានែល ខុមម្មូនីធី លេនត្រាស៍ (The Martín Peña Channel Community Land Trust) នៅប្រទេសព័រតូរីកូ

ផ្លូវទឹកមួយខ្សែនៅក្នុងរដ្ឋធានីសានជួន( San Juan) នៃប្រទេសព័រតូរីកូមានឈ្មោះថា ឪ ម៉ាទីន កេណា ឆានែល។ អ្នកតាំងលំនៅខុសច្បាប់បានតាំងទីលំនៅលើព្រៃក ដែលមានដើមកោងកាងដោយបានសង់ផ្ទះជាង ៥ពាន់ខ្នង។ ទឹកពោរពេញដោយកម្ទេចកម្ទី និងដីល្បាប់ និងគ្មានប្រព័ន្ធលូបានក្លាយជាការបំពុល ក៏ដូចជាទឹកជំនន់ ដែលបង្កើតស្ថានភាពគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ។ ជាការឆ្លើយតបរាជរដ្ឋាភិបាលបានបង្កើតផែនការបូមខ្សាច់ និងបង្ហូរដើមកបំពេញច្រាំង។ ទោះបីជាមានអត្ថប្រយោជន៍ពីផែនការនេះក៏ដោយក៏វាបានបង្កើតហានិភ័យ នៅពេលដែលបញ្ហាបរិស្ថានត្រូវបានដោះស្រាយហើយ តម្លៃដី (នៅក្នុងទីតាំងសំខាន់ៗក្នុងទីក្រុង) នឹងកើនឡើងដែលអ្នករស់នៅដើមត្រូវផ្លាស់ទីកន្លែង។ គម្រោង ហ្វេឌីអីកូមីសូ (Fideicomiso) ឬ ជឿជាក់លើដីសហគមន៍ (Community Land Trust) ត្រូវបានបង្កើតឡើងនៅចន្លោះឆ្នាំ២០០២ និង ២០០៤ ក្នុងភាពជាដៃគូរវាងសហគមន៍ និងរាជរដ្ឋាភិបាល ដើម្បីធានាថាការកែលម្អទាំងឡាយដែលបានធ្វើឡើងនៅក្នុងតំបន់នេះមិនធ្វើឱ្យសហគមន៍ ដើមផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ពួកគេនោះទេ។

## ករណីសិក្សាទី៣៖ លក្ខន្តិកៈទីក្រុងនៅក្នុងប្រទេសប្រេស៊ីល (ច្បាប់សហព័ន្ធលេខ ១០,២៥៧ ឆ្នាំ២០០១)

លក្ខន្តិកៈទីក្រុង មានបញ្ចូលឧបករណ៍ផ្លូវច្បាប់នានា ដែលរដ្ឋបាលក្រុងអាចប្រើដើម្បីបង្កើតផែនការមេដែលត្រូវបានរចនាឡើងដើម្បីគ្រប់គ្រងជំរុញ និងឬមោឃភាពកិច្ចព្រមព្រៀងទាំងឡាយទាក់ទងនឹងទីផ្សារដីធ្លី និងទីផ្សារអចលនទ្រព្យក្នុងទីក្រុងស្របតាមគោលការណ៍បរិយាប័ន្នសង្គម និងនិរន្តរភាពបរិស្ថាន។ ច្បាប់សហព័ន្ធនេះគឺជាលទ្ធផលនៃដំណើរការចរចាអស់រយៈពេលជាងដប់ឆ្នាំ ដែលពាក់ព័ន្ធនឹងកម្លាំងសង្គម និងកម្លាំងនយោបាយ នៅក្នុងប្រទេសប្រេស៊ីល។ លិខិតូបករណ៍ចម្រុះនេះមានបញ្ចូលនៅក្នុងច្បាប់សហព័ន្ធដែលរួមមាន យន្តការរៀបចំផែនការបែបប្រពៃណី ដូចជាវិធានកំណត់តំបន់ដែលមានលិខិតូបករណ៍ថ្មីៗទាក់ទងនឹងការផ្ទេរសិទ្ធិសាងសង់ដែលអនុញ្ញាតឱ្យមានភាពបត់បែនក្នុងការកែលម្អទីលំនៅមិនស្របច្បាប់ និងការផ្តល់លំនៅឋានសង្គមជាដើម។ នេះគឺជាករណីសិក្សាទាំង៣ ដែលទទួលបានជោគជ័យក្នុងការសម្រេចបាននូវសិទ្ធិទទួលបានលំនៅឋាន និងសុវត្ថិភាពដីធ្លីរបស់សហគមន៍ក្រីក្រនៅក្នុងទីក្រុង ដែលមានការពង្រីកនគរូបនីយកម្មយ៉ាងរហ័សដូចជារាជធានីភ្នំពេញ។ ទោះបីជាបរិបទនៃករណីសិក្សានីមួយៗមានភាពខុសប្លែកគ្នា និងខុសពីបរិបទនៃរាជធានីភ្នំពេញក៏ដោយក៏មានលក្ខណៈស្រដៀងគ្នាខ្លះដែរដែលធ្វើឱ្យកម្មវិធីទាំងនេះទទួលបានជោគជ័យ៖

១. ***សហគមន៍រឹងមាំ និងការប្តេជ្ញាចិត្តនយោបាយ៖*** រាល់គំនិតផ្តួចផ្តើមដែលបង្ហាញក្នុងករណីសិក្សាទាំងនេះបានទទួលជោគជ័យ ដោយសារមានការគាំទ្រផ្នែកនយោបាយពីតួអង្គសំខាន់ៗរបស់រាជរដ្ឋាភិបាលដើម្បីអនុវត្ត កម្មវិធីដីធ្លីនិង

លំនៅឋានក្នុងភាពជាដៃគូជាមួយសហគមន៍ក្រីក្រក្នុងទីក្រុង។ ការគាំទ្រផ្នែកនយោបាយនេះគឺជាលទ្ធផលនៃសហគមន៍ក្រីក្រនៅទីក្រុងដែលត្រូវបានគេចងក្រងឡើង និងមានគោលដៅច្បាស់លាស់លើតម្រូវការដីធ្លី និងលំនៅឋានរបស់ពួកគេ ដើម្បីអាចចរចាជាក់ស្តែងជាមួយអាជ្ញាធររដ្ឋាភិបាលអំពីអាទិភាពរបស់ពួកគេ និងធ្វើការសហការជាមួយអាជ្ញាធរទាំងនោះ។

២. ***សិទ្ធិកាន់កាប់ជាសមូហភាព៖*** ករណីសិក្សាទាំងអស់គាំទ្រការកាន់កាប់ដីធ្លី ការផ្តល់កម្មសិទ្ធិជាសមូហភាព (ជាជាងការផ្តល់កម្មសិទ្ធិជាបុគ្គល) នៅក្នុងកម្មវិធីរបស់ពួកគេ។ ការកាន់កាប់ដីធ្លីជាសមូហភាពការពារសុវត្ថិភាពដីធ្លីរបស់សហគមន៍ក្រីក្រក្នុងទីក្រុងក្នុងរយៈពេលវែង ដោយកាត់បន្ថយការបង្កក់ដីធ្លីទុកលក់ពេលដីឡើងថ្លៃ និងធានាថាសមាជិកម្នាក់ៗមិនលក់ដីរបស់ពួកគេរៀងៗខ្លួន។

៣. ***ការចូលរួមរបស់សហគមន៍ក្រីក្រក្នុងទីក្រុងក្នុងការសម្រេចចិត្ត៖*** ករណីសិក្សាទាំងអស់គឺផ្អែកលើគោលការណ៍នៃសហគមន៍ក្រីក្រនៅទីក្រុង ដែលដឹកនាំការសម្រេចចិត្តតាមរយៈការចូលរួម និងសកម្មភាពរួម។

៤. ***ការគាំទ្រផ្នែកហិរញ្ញវត្ថុដ៏ទូលំទូលាយសម្រាប់សកម្មភាពដីធ្លី លំនៅឋាន និងជីវភាពរស់នៅ៖*** ទោះបីជាកម្មវិធីផ្តោតសំខាន់លើសុវត្ថិភាពដីធ្លីសម្រាប់ប្រជាសហគមន៍ក្រីក្រក្នុងទីក្រុងក៏ពិតមែន តែកម្មវិធីទាំងនេះក៏ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសម្រាប់ការអភិវឌ្ឍលំនៅឋាន និងសកម្មភាពចិញ្ចឹមជីវិតផងដែរ។ កម្មវិធីដ៏គ្រប់ជ្រុងជ្រោយទាំងនេះដែលបានជួយដោះស្រាយតម្រូវការភាពក្រីក្រផ្សេងៗនៃសហគមន៍ក្រីក្រក្នុងទីក្រុងពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធ្វើឱ្យសម្រេចបាននូវសិទ្ធិទទួលបានលំនៅឋាន។

ករណីសិក្សាទាំងនេះ អាចជាឯកសារយោងដ៏មានតម្លៃចំពោះយុទ្ធសាស្ត្រដែលអាចជួយដល់ស្ថានភាពនៃសហគមន៍ក្រីក្រទាំង១១សហគមន៍ដែលជាផ្នែកមួយនៃការសិក្សានេះ។ ការស្នង់មតិអំពីបញ្ហាដីធ្លីនៅទូទាំងក្រុងដូចករណីរបស់ កម្មវិធីបានមេគង្គ (Baan Mankong) អាចជួយសហគមន៍ក្រីក្រទាំង ១១ទីតាំងក្នុងការស្វែងរកដីមានតម្លៃដ៏សមរម្យនៅក្នុងរាជធានីភ្នំពេញ ដែលអាចប្រើប្រាស់សម្រាប់គោលបំណងតាំងលំនៅថ្មីក្នុងករណីដែលការកែលម្អលំនៅឋាននៅក្នុងសហគមន៍នោះមិនអាចធ្វើទៅបាន។ យុទ្ធសាស្ត្រនេះអាចជួយសហគមន៍ឱ្យពង្រឹងភាពអង់អាចរបស់ពួកគេកាន់តែខ្លាំងចំពោះទីតាំងដែលពួកគេនឹងផ្លាស់ទីទៅរស់នៅ និងបង្កើតផែនការដ៏គ្រប់ជ្រុងជ្រោយមួយដើម្បីបង្ហាញដល់រាជរដ្ឋាភិបាល។ ម្យ៉ាងវិញទៀត មូលនិធិដីសហគមន៍ និងលិខិតូបករណ៍ទាក់ទងនឹងការប្រើប្រាស់ដីដែលបង្ហាញនៅក្នុងករណីប្រទេសព័រតូរីកូ និងប្រទេសប្រេស៊ីលអាចត្រូវបានប្រើជាគំរូដែលសហគមន៍អាចយកមកគិតសម្រាប់អនុវត្តន៍ និងធ្វើការតស៊ូមតិជាមួយរាជរដ្ឋាភិបាល និងភ្នាក់ងារអន្តរជាតិនានាសម្រាប់ការអនុវត្ត។

# លទ្ធផលពីការពិភាក្សាជាក្រុមស្នូល

*តារាងទី៦៖ សង្ខេបនៃអ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាក្រុមស្នូល*

| សហគមន៍ | អ្នកចូលរួម | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|
| ទំនប់តាថ្លាង | ស្ត្រី ៥ នាក់ | ១៥-០១-២០២៤ | ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ |
| ស្ទឹងកំបុត | ស្ត្រី ១០នាក់<br>និងបុរស ១នាក់ | ១១-០១-២០២៤ | ក្រុមទី៥ & ៧ ភូមិឡកំបោរ សង្កាត់ស្វាយប៉ាក<br>ខណ្ឌឫស្សីកែវ |
| ស្ត្រីក្លាហាន | ស្ត្រី ១២នាក់ | ១២-០១-២០២៤ | ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ |
| សំពោងត្បូង | ស្ត្រី ១១ នាក់។ | ១១-០១-២០២៤ | ភូមិសំពោងត្បូង សង្កាត់សំពោង ខណ្ឌព្រែកព្នៅ |
| ស្មើសាមគ្គី | ស្ត្រី ២ នាក់<br>និងបុរស ២ នាក់ | ១០- ០១- ២០២៤ | ភូមិឫស្សីទី១ និងភូមិឫស្សីទី២ សង្កាត់ស្ទឹងមានជ័យទី៣<br>ខណ្ឌមានជ័យ |
| ពង្រសែនជ័យ | ស្ត្រី ៤នាក់<br>និងបុរស ១នាក់ | ១០-០១-២០២៤ | ភូមិទួលពង្រ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ |
| កៅពីរ | ស្ត្រី ៦នាក់ | ១២-០១-២០២៤ | ក្រុមទី២ ក្រុមទី៤ ភូមិត្រពាំងស្វាយ សង្កាត់គោកឃ្លាង<br>ខណ្ឌសែនសុខ |
| ផ្ការអើត | ស្ត្រី ៦នាក់ | ១៥-០១-២០២៤ | ភូមិចំពុះក្អែក  សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ |
| បឹងឈូកមានជ័យ<br>ថ្មី២ | ស្ត្រី ៦នាក់<br>និងបុរស ២នាក់ | ១៣-០១-២០២៤ | ភូមិបឹងឈូក សង្កាត់និរោធន៍ ខណ្ឌច្បារអំពៅ |
| អណ្តូងតាអៀង | ស្ត្រី ១១ នាក់ | ១៥-០១-២០២៤ | ភូមិព្រែកថ្មី១ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ |
| សាមគ្គីរុងរឿង | ស្ត្រី ៤ នាក់ | ១២-០១-២០២៤ | ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន |

## ការពិភាក្សាអំពីលទ្ធផលពីកិច្ចពិភាក្សាក្រុមស្នូល

សហគមន៍ទាំងអស់ ដែលបានចូលរួមក្នុងការស្រាវជ្រាវនេះបានកាន់កាប់ដី ក្នុងទម្រង់ដីសាធារណៈខ្លះ ហេតុដូច្នេះ ពួកគេប្រឈមមុខនឹងអសុវត្ថិភាពដីធ្លី និងលំនៅឋាន។ ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ទំនប់តាថ្លាងជួបប្រទះនឹងបញ្ហាអសុវត្ថិភាពដីធ្លី និងលំនៅឋាន បើទោះបីជាពួកគាត់ធ្លាប់បានដំណើរការនីតិវិធីចុះបញ្ជីដីធ្លីជាប្រព័ន្ធក្នុងឆ្នាំ២០១៩ ក៏ដោយ។ ប៉ុន្តែដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធនេះ ត្រូវបានដកហូតពីសហគមន៍ដោយសាររាជរដ្ឋាភិបាលមានគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូ។ ទោះជាយ៉ាងណា ប្រព័ន្ធលូត្រូវបានសាងសង់នៅតាមដងផ្លូវមុខផ្ទះរបស់សហគមន៍

មិនមែននៅក្នុងផ្ទះរបស់ពួកគេទេ។ អាជ្ញាធរមូលដ្ឋានបានស្នើឱ្យសហគមន៍ប្រគល់បង្កាន់ដៃចុះបញ្ជីដីធ្លីជាប្រព័ន្ធ របស់ពួកគេទៅការិយាល័យរដ្ឋបាល ដែលនេះវាធ្វើឱ្យប្រជាពលរដ្ឋគ្មានភស្តុតាងបង្ហាញអំពីដំណើរការចុះបញ្ជីដីធ្លី។
ពួកគេនិយាយថា៖

*បង្កាន់ដៃការចុះបញ្ជីដីធ្លីជាប្រព័ន្ធ របស់យើងត្រូវបានដកហូត និងរក្សាទុកនៅក្នុងសង្កាត់ហើយ ពួកគេបាន ប្រាប់យើងឱ្យរង់ចាំវិក័យបត្រថ្មីមួយទៀត*

ជាងនេះទៅទៀត ប្រជាពលរដ្ឋក្នុងសហគមន៍នេះជួបប្រទះនឹងបញ្ហាអសន្តិសុខ ដោយសារការអភិវឌ្ឍបុរី នៅតំបន់ក្បែរនោះ ក៏ដូចជាការចាក់ដីលុបបឹងផងដែរ។ អ្នកអភិវឌ្ឍន៍ឯកជនបានស្នើឱ្យសមាជិកសហគមន៍លក់ដីឱ្យពួកគេដើម្បីធ្វើការអភិវឌ្ឍទៅថ្ងៃអនាគត។ រហូតមកដល់ពេលនេះមាន២គ្រួសារ(ដែលមិនរស់នៅក្នុងសហគមន៍នៅពេលនោះ) បានលក់ដីរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ អ្នកស្រុកភាគច្រើនមិនលក់ដីរបស់ពួកគេទេ ព្រោះគេឱ្យតម្លៃទាបជាងតម្លៃទីផ្សារ ហើយបើពួកគេលក់ពួកគេនឹងគ្មានកន្លែងរស់នៅ។

ក្នុងករណីសហគមន៍ថ្នាអើត និងអណ្តូងតាអៀង ប្រជាពលរដ្ឋត្រូវបានគេផាត់ចេញពីដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ដោយសារប្រជាសហគមន៍ថ្នាអើតរស់នៅលើខ្នងប្រឡាយ ចំណែកប្រជាសហគមន៍អណ្តូងតាអៀង កំពុងរស់នៅទីតាំងមួយដែលជាអតីតអណ្តូង ដែលអាជ្ញាធរចាត់ទុកថាទីតាំងទាំងពីរនេះជាដីសាធារណៈរបស់រដ្ឋ។ ទោះយ៉ាងណាក៏ដោយ គ្រួសារអ្នកមានមួយចំនួនបានប្រកបអាជីវកម្មលើផ្នែកខ្លះនៃដីដូចគ្នានេះអាចទទួលបានបង្កាន់ដៃនៃការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ ប្រជាសហគមន៍អណ្តូងតាអៀងបានឱ្យដឹងថា៖

*នៅពេលនោះ សមាជិកសហគមន៍មិនបានសួរមន្ត្រីសុរិយោដីអំពីមូលហេតុនៃការដកចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ នោះទេ ដោយសារប្រជាសហគមន៍មិនមានចំណេះដឹងលើបញ្ហាដីធ្លី។ នៅឆ្នាំ២០២៣ សមាជិកសហគមន៍បានទទួលការអភិវឌ្ឍសមត្ថភាព និងចំណេះដឹងអំពីច្បាប់ដីធ្លីដោយអង្គការសមគមជាងត្នោត និងការយល់ដឹងអំពីបញ្ហាដីធ្លី។ ឥឡូវនេះ ពួកគេមានទំនុកចិត្តក្នុងការតស៊ូមតិ ដើម្បីដីរបស់ពួកគេ។*

អាជ្ញាធរមូលដ្ឋានបានប្រាប់ប្រជាពលរដ្ឋថា ពួកគេនឹងមិនទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីឡើយ។ ប្រជាពលរដ្ឋបានផ្ញើលិខិតទៅសាលាសង្កាត់ដើម្បីស្នើសុំព័ត៌មានអំពីស្ថានភាពដីធ្លីរបស់ពួកគេ ប៉ុន្តែរហូតមកដល់ពេលនេះពួកគេមិនបានទទួលព័ត៌មានអ្វីមកវិញនោះទេ។ សហគមន៍ចង់បង្កើតទំនាក់ទំនងជាមួយអាជ្ញាធរ ដើម្បីបង្កើតផែនការសម្រាប់ធ្វើការកែលម្អលំនៅឋាននៅលើដីរបស់សហគមន៍នោះ ឬការផ្លាស់ប្តូរទីតាំង។ នេះជាករណីដូចគ្នានឹងសហគមន៍អណ្តូងតាអៀង ដែលប្រជាពលរដ្ឋត្រូវបានគេផាត់ចេញពីការចុះបញ្ជីដីធ្លីជាប្រព័ន្ធ ហើយមិនបានទទួលព័ត៌មានពីអាជ្ញាធរមូលដ្ឋានអំពីវិធីថាតើត្រូវធ្វើអ្វីទៀតនៅពេលខាងមុខ ដើម្បីធានាការទទួលបានដីធ្លីរបស់ពួកគេ។

នៅសហគមន៍សំពោងត្បូង ឯកសារដីធ្លីរបស់ប្រជាពលរដ្ឋ ដែលមានការទទួលស្គាល់ពីអាជ្ញាធរសង្កាត់ក៏ត្រូវបានដកហូតដែរ ខណៈពេលដែលបុរីត្រូវបានអភិវឌ្ឍន៍ជុំវិញសហគមន៍។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដូចជាប្រឡាយ និងផ្លូវថ្នល់ដែលអាចប៉ះពាល់ដោយផ្ទាល់ដល់សហគមន៍ ដូចជាការជន់លិចសហគមន៍ជាដើម។ ជាច្រើនឆ្នាំមកនេះ រាជរដ្ឋាភិបាលបានសម្របសម្រួលផ្តល់ជាដំណោះស្រាយលើបញ្ហាវិវាទដីធ្លីជូនសហគមន៍។ សាលារាជធានីភ្នំពេញបានប្រាប់ប្រជាសហគមន៍នៅឆ្នាំ២០២១ ថា ពួកគេអាចធ្វើការកែលម្អលំនៅឋាន

របស់ពួកគេនៅលើដីក្នុងសហគមន៍នោះ។ ទោះយ៉ាងណាក៏ដោយ នៅឆ្នាំ២០២៣ សង្កាត់បានស្នើឱ្យប្រជាពលរដ្ឋពិចារណាលើសំណងសម្រាប់ដីរបស់ពួកគេហើយផ្លាស់ទីតាំងថ្មី។ សមាជិកសហគមន៍ដែលចូលរួមក្នុងកិច្ចពិភាក្សាក្រុមស្នូល បានរៀបរាប់ថា៖

*“សាលារាជធានីភ្នំពេញធ្លាប់ប្រាប់ ថាពួកគេអាចកែលម្អលំនៅឋានរបស់ពួកគេដែលមានទំហំ៤,២ ម x ១៨ ម បន្ទាប់ពីការស្ទង់មតិបែបស្ថិតិឆ្នាំ ២០២១ ដោយសាលាខណ្ឌ និងសាលារាជធានីភ្នំពេញ។ ទោះជាយ៉ាងនេះក្តី កាលពីខែតុលា ឆ្នាំ២០២៣ សាលាសង្កាត់បានស្នើឱ្យប្រជាពលរដ្ឋពិចារណាលើជម្រើសនៃសំណង ប៉ុន្តែប្រជាសហគមន៍មួយចំនួនបានស្នើសុំលក់ដីក្នុងតម្លៃទីផ្សារ ហើយគ្រួសារខ្លះស្នើឱ្យមានការកែលម្អផ្ទះរបស់ពួកគេនៅលើដីនោះតែម្តង ។ ប៉ុន្តែការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន ពួកខ្ញុំភាគច្រើនមិនអាចទទួលយកបានទេ។”*

ប្រជាសហគមន៍ចំនួន៣២ គ្រួសារបានទទួលយកសំណង និងផ្លាស់ប្តូរលំនៅឋានទៅទីតាំងលំនៅថ្មីប្រហែល ២គីឡូម៉ែត្រពីសហគមន៍ចាស់ ហើយ ពួកគេទទួលបានប្រាក់ចំនួន១០ ០០០ ដុល្លារ។ ទោះជាយ៉ាងនេះក្តី ប្រជាសហគមន៍ដែលរស់នៅក្នុងសហគមន៍បច្ចុប្បន្នចង់រស់នៅលើដីចាស់របស់ពួកគេ។ ប្រជាសហគមន៍បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយ និងបានចរចាជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ការអភិវឌ្ឍនៅនឹងកន្លែងចាស់របស់គាត់។ ពួកគេបានផ្ញើលិខិតស្នើសុំទៅអភិបាលខណ្ឌថ្មី សាលារាជធានីភ្នំពេញ ស្ថានទូត ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។ ស្ថាប័នទាំងអស់នេះបានប្រគល់លិខិតរបស់សហគមន៍ត្រឡប់ទៅខណ្ឌវិញ ហើយប្រជាសហគមន៍មិនបានទទួលដំណឹងឆ្លើយតបវិញឡើយ ។

ករណីសហគមន៍ទំនប់តាថ្លាងមានសភាពស្រដៀងគ្នានឹងស្ថានភាព នៅសហគមន៍ស្ទឹងកំបុតដែរ។ ដីនៅសហគមន៍ ស្ទឹងកំបុតគឺជាអតីតប្រឡាយមួយ ហើយក្រុមហ៊ុនសំណង់ឡុង ឈិនបានចាក់ដីបំពេញប្រឡាយនោះនៅឆ្នាំ២០០០។ ក្រុមហ៊ុនក៏បានសាងសង់ប្រឡាយថ្មីមួយនៅម្ខាងទៀតនៃសហគមន៍ផងដែរ។ ក្រោយមកបុរី លឹម ឈាងហាក់ និងបុរីអង្គរបានបន្តចាក់បំពេញប្រឡាយ។ ឥឡូវនេះ បុរីត្រូវបានអភិវឌ្ឍន៍ ហើយក្រុមហ៊ុនឯកជនកំពុងទិញដីពីអ្នករស់នៅក្នុងសហគមន៍។ កន្លងមកអាជ្ញាធរមូលដ្ឋានមិនអនុញ្ញាតឱ្យក្រុមហ៊ុនទិញដីពីប្រជាពលរដ្ឋនោះទេ ដោយសារពួកគេចាត់ទុកដីនោះជាដីសាធារណៈ ដោយសារដីនោះជាដីចំណីផ្លូវ ហេតុដូច្នេះការលក់ដីបែបនោះវាខុសច្បាប់។ ទោះបីជាយ៉ាងនេះក្តី ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អាជ្ញាធរមូលដ្ឋានបានអនុញ្ញាតឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនទិញដីពីប្រជាពលរដ្ឋ។ រហូតមកដល់ពេលនេះ មានប្រជាពលរដ្ឋសរុប ៥៨គ្រួសារបានលក់ដីរបស់ពួកគេរួចហើយ។ បច្ចុប្បន្នគម្រោងអភិវឌ្ឍន៍ផ្លូវចង់ពង្រីកផ្លូវពី ១៦ម ទៅ ៣០ម ដែលប៉ះពាល់ដី ១៤ម ដែលកាន់កាប់ដោយសមាជិកសហគមន៍ស្ទឹងកំបុត។ នេះជាករណីដូចគ្នានឹងសហគមន៍កៅពីរ ដែលដើមឡើយត្រូវបានបណ្តេញចេញកាលពីឆ្នាំ១៩៩២ ពីតំបន់សណ្ឋាគារកាំបូឌីយ៉ាណា ហើយបច្ចុប្បន្នរស់នៅតាមច្រករបៀងផ្លូវដែលចាត់ទុកជាដីសាធារណៈរបស់រដ្ឋ។ ចាប់តាំងពីពេលនោះមកសហគមន៍មានជម្លោះដីធ្លីជាមួយក្រុមហ៊ុនផ្សេងៗ ប៉ុន្តែមិនត្រូវបានបណ្តេញចេញនោះទេ។ ទោះយ៉ាងណាក៏ដោយ ពួកគេតែងតែស្ថិតនៅក្រោមការគំរាមកំហែងនៃការបណ្តេញចេញ។

អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាក្រុមស្នូល បាននិយាយថា៖

*"នៅឆ្នាំ២០២៣ សមាជិកសហគមន៍ចំនួន ៣៨នាក់មានជម្លោះជាមួយបុគ្គលឯកជនម្នាក់។ កាលពីថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០២៣ គាត់បានដាក់ពាក្យបណ្តឹង ហើយសមាជិកសហគមន៍ ៣នាក់ត្រូវបានកោះហៅទៅតុលាការ។ ជាលទ្ធផល មាន ២គ្រួសារក្នុងចំណោម ៣គ្រួសារបានកាត់បន្ថយផ្ទៃដីផ្ទះចំនួន៣ម៉ែត្រ ទៅឱ្យបុគ្គលឯកជនម្នាក់នោះ ខណៈដែលពួកគេម្នាក់មិនយល់ព្រម និងបានសុំឱ្យប្រជាសហគមន៍ជួយគាត់។ ប្រជាពលរដ្ឋបានឮពាក្យចចាមអារ៉ាមថា ពលរដ្ឋទាំង ៣៨គ្រួសារនឹងត្រូវបណ្តេញចេញតាមដីការបស់តុលាការ ប៉ុន្តែពួកគេមិនបានទទួលដីកាពីតុលាការរហូតមកដល់ពេលនេះ"*

ប្រជាពលរដ្ឋនៅសហគមន៍កៅពីរគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីទេ គឺមានតែបង្កាន់ដៃដីដែលសាលាសង្កាត់បានយល់ព្រមចេញឱ្យ។ ប្រជាពលរដ្ឋមិនអាចទទួលបានប្រាក់កម្ចីដោយសារមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី និងមិនអាចកែលម្អផ្ទះរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ ដោយសារការរីកចម្រើននៃការអភិវឌ្ឍនៅក្នុងសង្កាត់របស់ពួកគេ ពួកគេត្រូវបានហ៊ុំព័ទ្ធដោយបរិយាកាសល្អ និងមានលទ្ធភាពទទួលបានសេវាសំខាន់ៗខ្លះ។

សហគមន៍ផ្សេងទៀត ដែលបានចូលរួមក្នុងការស្រាវជ្រាវនេះដូចជា សហគមន៍ស្ត្រីក្លាហាន មិនមានឯកសារដីធ្លីនោះទេ ដូច្នេះហើយពួកគេបានជួបប្រទះនូវអសុវត្ថិភាពខ្ពស់ជាងនេះ។ ប្រជាសហគមន៍ស្ត្រីក្លាហាន មិនបានទទួលការជូនដំណឹងអំពីការបណ្តេញចេញជាផ្លូវការនោះទេ ប៉ុន្តែអាជ្ញាធរមូលដ្ឋានបានប្រាប់ពួកគេថា ពួកគេរស់នៅលើដីសាធារណៈរបស់រដ្ឋ ដូច្នេះហើយអនាគតរបស់ពួកគេគឺមិនច្បាស់លាស់។ អ្នកចូលរួមនៅក្នុងកិច្ចពិភាក្សាក្រុមស្នូល បាននិយាយថា៖

*"ប្រជាសហគមន៍មិនមានប័ណ្ណកម្មសិទ្ធិដីធ្លីនោះទេ ហើយអាជ្ញាធរមូលដ្ឋានបានប្រាប់ពួកគេថា ដីនៅក្បែរមាត់ទន្លេដែលមានផ្ទះប្រជាពលរដ្ឋជាដីសាធារណៈរបស់រដ្ឋ។ ប្រជាជនអាចបន្តរស់នៅបានជាធម្មតា ប៉ុន្តែពួកគេមិនដឹងថាពេលណាពួកគេត្រូវបានតម្រូវឱ្យចាកចេញពីសហគមន៍។ រហូតមកដល់ពេលនេះ មិនមានការគំរាមកំហែងនៃការបណ្តេញចេញនោះទេ។"*

ប្រជាពលរដ្ឋក្នុងសហគមន៍ស្ត្រីក្លាហាន មានជីវភាពក្រីក្រខ្លាំង ហើយរស់នៅក្នុងបរិយាកាសក្រីក្រ អសន្តិសុខ និងអន់ថយ។ ឧទាហរណ៍៖ ចំពោះស្ថានភាពផ្លូវ រថយន្តពន្លត់អគ្គិភ័យ និងរថយន្តប្រមូលសំរាម មិនអាចចូលទៅដល់តំបន់សហគមន៍នោះបានទេ។ ពេលមានភ្លើងឆេះក្នុងសហគមន៍កប៉ាល់មកពីទន្លេចតុមុខ បានជួយសហគមន៍ ដោយបាញ់ទឹកពីទន្លេមកពន្លត់អគ្គិភ័យ។ ប្រជាសហគមន៍ក៏ត្រូវខ្ចប់សំរាមយកទៅតាមផ្លូវធំដើម្បីឱ្យឡានដឹកសំរាមប្រមូល។ ស្ថានីយទូរទស្សន៍ស៊ីធីអិនបានឧបត្ថម្ភថវិកាដល់ប្រព័ន្ធលូទឹកស្អុយតាមដងផ្លូវសហគមន៍ និងបានបញ្ចេញសំណល់រាវទៅកាន់តំបន់សហគមន៍ជាកន្លែង ដែលក្មេងៗលេងនៅជុំវិញទីនោះនិងបង្កើតក្លិនស្អុយយ៉ាងខ្លាំងនៅក្នុងតំបន់នោះ។ ពួកគេក៏បង្កើតអង្គការសមូហភាពតូចមួយផងដែរ ហើយសមាជិកទាំងនោះធ្វើសកម្មភាពរៀងៗខ្លួនដើម្បីរកប្រាក់ចំណូល។ ប្រជាពលរដ្ឋជាច្រើន បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ ឬអ្នកផ្តល់ប្រាក់កម្ចីឯកជនដើម្បីជួសជុលផ្ទះរបស់ពួកគេជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ ហើយសូម្បីតែនៅពេលដែលពួកគេមានទឹក និងភ្លើងប្រើប្រាស់ក៏ដោយ ក៏គ្រួសារ

ខ្លះពិបាកបង់ថ្លៃសេវាទឹកភ្លើងនោះផងដែរ។ ប្រជាពលរដ្ឋនៅសហគមន៍ស្រ្តីក្លាហានចង់បានការអភិវឌ្ឍនៅកន្លែងក៏ប៉ុន្តែពួកគេក៏សុខចិត្តផ្លាស់ប្តូរទីលំនៅផងដែរ ប្រសិនបើអាជ្ញាធរមូលដ្ឋានផ្តល់ដល់ពួកគេនូវប័ណ្ណកម្មសិទ្ធិដីធ្លីជំនួយលំនៅឋាន និងការទទួលបានសេវានានា។

ដូចគ្នានេះដែរ ប្រជាពលរដ្ឋសហគមន៍រស្មីសាមគ្គីមិនមានឯកសារដីធ្លីហើយបច្ចុប្បន្នរស់នៅតាមព្រែកចាត់ទុកជាដីសាធារណៈរបស់រដ្ឋ។ ប្រឡាយនេះនឹងត្រូវបានអភិវឌ្ឍន៍តាមរយៈគម្រោងដែលផ្តល់មូលនិធិដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិជប៉ុន ហៅកាត់ថា ចៃកា (JICA) នៅពាក់កណ្តាលឆ្នាំ២០២៤។ ប្រជាពលរដ្ឋបានចូលរួមកិច្ចប្រជុំជាមួយចៃកា(JICA) និងអាជ្ញាធររាជរដ្ឋាភិបាលដែលពួកគេត្រូវបានផ្តល់សំណងសម្រាប់ការរើចេញពីដីរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាសហគមន៍មិនទទួលដូនដំណឹងអំពីផែនការផ្លាស់ប្តូរទៅកាន់ទីកន្លែងដែលអាចរស់នៅបាន និងតួលេខសំណងផ្លូវការ ឬការគាំទ្រនានានោះទេ។ ប្រជាសហគមន៍ចង់បន្តរស់នៅលើទីតាំងចាស់ព្រោះពួកគេអាចទទួលបានការងារ និងសេវាកម្មប៉ុន្តែពួកគេសុខចិត្តផ្លាស់ប្តូរទីលំនៅក្រោមលក្ខខណ្ឌដែលទីតាំងថ្មីមានចម្ងាយមិនលើសពី៥គីឡូម៉ែត្រពីទីតាំងចាស់។ ប្រជាសហគមន៍ចង់ឱ្យអនុវត្តន៍សារាចរណ៍លេខ០៣ ដើម្បីរកដំណោះស្រាយសមស្របសម្រាប់អនាគតរបស់ពួកគេ។

ប្រជាពលរដ្ឋនៅសហគមន៍បឹងឈូកមានជ័យថ្មី២ បានដាក់ពាក្យសុំការចុះបញ្ជីដីធ្លីជាប្រព័ន្ធទៅក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ប៉ុន្តែមិនមានការឆ្លើយតបណាមួយឡើយ។ ពួកគេកាន់កាប់តំបន់ដីសើមដែលចាត់ទុកថាជាដីសាធារណៈរបស់រដ្ឋ។ប្រជាសហគមន៍មិនបានជួបការគំរាមកំហែងពីការបណ្តេញចេញនោះទេ ក៏ប៉ុន្តែមានអារម្មណ៍ថាគ្មានសុវត្ថិភាពដោយសារមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី។ ប្រជាសហគមន៍ រៀបចំការប្រជុំសហគមន៍ក្នុងគោលបំណងធ្វើផែនការសកម្មភាពអំពីរបៀបទាក់ទងជាមួយរាជរដ្ឋាភិបាល។ ការមិនមានកម្មសិទ្ធិដីធ្លី ធ្វើឱ្យសហគមន៍បែកខ្ញែកគ្នាដោយសារប្រជាសហគមន៍មួយចំនួនបានចាប់ផ្តើមស្នើសុំចុះបញ្ជីដីធ្លីជាបន្តបន្ទាប់ ប៉ុន្តែអ្នកខ្លះទៀតមិនអាចធ្វើបាន។ ប្រជាសហគមន៍ចង់បានការគាំទ្រដើម្បីឱ្យមានភាពប្រាកដប្រជាលើដីធ្លី និងអនាគតរបស់ពួកគាត់។

ប្រជាសហគមន៍ពង្រសែនជ័យរស់នៅលើដីចំណីផ្លូវ ហើយពុំមានលទ្ធភាពទទួលបានឯកសារដីធ្លី ព្រមទាំងឯកសារសាធារណៈផ្សេងៗដូចជាសៀវភៅគ្រួសារជាដើម។ អាជ្ញាធរមូលដ្ឋានបានចាត់ទុកសហគមន៍នេះ ថាជាការតាំងទីលំនៅបណ្តោះអាសន្ន ហើយបានប្រាប់សហគមន៍ថាមិនយូរមិនឆាប់ពួកគេនឹងត្រូវរើចេញ។ ប្រជាជនចង់បន្តរស់នៅក្នុងទីតាំងនេះ និងទទួលបានអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនត្រឹមត្រូវ។ សហគមន៍នេះងាយរងគ្រោះពីទឹកជំនន់ និងត្រូវបានហ៊ុំព័ទ្ធដោយបរិស្ថានមិនល្អ។ ប្រជាសហគមន៍ជាច្រើនទទួលបានប្រាក់កម្ចីពីអ្នកផ្តល់កម្ចីឯកជនដើម្បីកែលម្អផ្ទះរបស់ពួកគេ និងសម្រាប់បញ្ហាសង្គ្រោះបន្ទាន់នានា និងមានជាប់បំណុលយ៉ាងច្រើន។ សមាជិកសហគមន៍មិនបានទទួលព័ត៌មានច្បាស់លាស់ណាមួយអំពីការអភិវឌ្ឍផ្លូវនោះទេ ដូច្នេះហើយពួកគេមិនអាចធ្វើផែនការ ឬសំណើជូនរាជរដ្ឋាភិបាលបានច្បាស់លាស់នោះទេ។ តំណាងសហគមន៍គិតថា ប្រសិនបើប្រជាពលរដ្ឋនឹងត្រូវផ្លាស់ប្តូរទីលំនៅ ផែនការដ៏ល្អមួយគួរតែត្រូវបានបង្កើតឡើង ដែលប្រជាពលរដ្ឋត្រូវបានធានាឱ្យមានលទ្ធភាពទទួលបានដីធ្លីលំនៅឋាន និងអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន។ប្រជាសហគមន៍ទាំងនោះមិនគួរទទួលសំណងជាសាច់ប្រាក់នោះទេ ព្រោះពួកគេនឹងប្រើប្រាស់វាដើម្បីសងបំណុលរបស់ពួកគេ ហើយ



*រូបភាពទី៦៖ ទិដ្ឋភាពខាងក្រោយសហគមន៍សំរោងត្បូង ឆ្នាំ២០២៤*



ពួកគេអាចក្លាយជាប្រជាពលរដ្ឋគ្មានដី។សាលារាជធានីភ្នំពេញនិងខណ្ឌស្នើឱ្យប្រជាពលរដ្ឋក្នុងសហគមន៍ទំនប់តាថ្លាង ដោះដូរដីមួយកន្លែងក្នុងការតាំងទីលំនៅថ្មីនៅភូមិចំពុះក្អែក១ដោយសាររាជរដ្ឋាភិបាលមានគម្រោងអភិវឌ្ឍន៍ផ្លូវ ៦០ម៉ែត្រក្នុងសហគមន៍នោះ។ ប្រជាសហគមន៍បានទៅមើលទីតាំងទីលំនៅថ្មីហើយយល់ព្រមផ្លាស់ប្តូរដោយលក្ខខណ្ឌថា រាជរដ្ឋាភិបាលត្រូវផ្តល់បង្កាន់ដៃដីផ្លូវការ និងប័ណ្ណកម្មសិទ្ធិដីធ្លីជូនពួកគាត់ បង់ថ្លៃរុះរើលំនៅឋានព្រមទាំងធានាបាននូវហេដ្ឋារចនាសម្ព័ន្ធត្រឹមត្រូវ(ឧទាហរណ៍អគ្គិសនីរដ្ឋ ប្រព័ន្ធលូ និងប្រព័ន្ធតភ្ជាប់ទឹកស្អាតជាដើម)។ សាលារាជធានីភ្នំពេញ និងខណ្ឌមិនបានឆ្លើយតបនឹងសំណើរបស់ប្រជាពលរដ្ឋនោះទេ។ អាជ្ញាធរមូលដ្ឋានមិនដឹងអំពីគម្រោងផ្លាស់ទីលំនៅនេះនោះទេ ហើយមិនអាចជួយសហគមន៍បានទេ។បើទោះជាយ៉ាងនេះក្តីចំណូលចិត្តរបស់ប្រជាសហគមន៍គឺស្នាក់នៅលើដីរបស់ពួកគេ និងធ្វើការកែលម្អនៅលើទីតាំងចាស់នោះវិញ។

នៅក្នុងសហគមន៍ស្ទឹងកំបុតក្នុងឆ្នាំ២០១៩ អាជ្ញាធមូលដ្ឋានបានប្រាប់ប្រជាពលរដ្ឋឱ្យផ្លាស់ទៅកន្លែងតាំងទីលំនៅថ្មីនៅ សេវិន អិន ជី (7GN) វិហារសួគ៌។ ប្រជាពលរដ្ឋមិនយល់ស្របទេ ប៉ុន្តែពួកគេស្នើសុំទីតាំងលំនៅថ្មីនៅក្នុងភូមិសំរោងត្បូង។ ក្រោយមកអាជ្ញាធរមូលដ្ឋានបានស្នើសុំទីតាំងថ្មីគឺសង្កាត់ក្រោលគោក្បែរប្រឡាយសំរាម និងនៅលើចំណីដីប្រឡាយ ហើយបាននិយាយទៅកាន់ប្រជាសហគមន៍ថា ក្នុងរយៈពេល១០ឆ្នាំខាងមុខគ្រួសារដែលតាំងទីលំនៅថ្មីនឹងទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី។ទោះជាយ៉ាងនេះក្តី ប្រជាសហគមន៍ចង់ឱ្យមានការកែលម្អ និងអភិវឌ្ឍន៍នៅលើទីតាំងចាស់ដោយសារពួកគេ រស់នៅទីនោះនៅជិតកន្លែងធ្វើការ សាលារៀន មណ្ឌលសុខភាព ផ្សារ និងកន្លែងល្អៗផ្សេងទៀត។ ប្រជាសហគមន៍ស្ទឹងកំបុតបានជួបប្រជុំផ្សេងគ្នាជាមួយខណ្ឌដើម្បីពិភាក្សាពីស្ថានភាពដីធ្លីរបស់ពួកគាត់ ប៉ុន្តែមិនទាន់មានដំណោះស្រាយណាមួយត្រូវបានគេយល់ស្របទេ ហើយប្រជាពលរដ្ឋនៅតែរង់ចាំផែនការច្បាស់លាស់ និងយុត្តិធម៌ពីរាជរដ្ឋាភិបាល។ អ្នករស់នៅសហគមន៍មួយចំនួនដូចជាសហគមន៍ទំនប់តាថ្លាង និងសាមគ្គីរុងរឿងចាត់ទុកការចងក្រងសហគមន៍ និងសាមគ្គីភាពក្នុងចំណោមអ្នករស់នៅទីនោះ គឺជាទ្រព្យសម្បត្តិដ៏អស្ចារ្យរបស់ពួកគេក្នុងការធានាបានសិទ្ធិដីធ្លីនិងលំនៅឋាន។ ការចងក្រងជាសហគមន៍រួមគ្នាមួយបានអនុញ្ញាតឱ្យប្រជាសហគមន៍ធ្វើការរួមគ្នា និងទទួលបានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន។ដោយសារការគាំទ្រ និងការទទួលស្គាល់ ប្រជាសហគមន៍បានយល់ដឹងពីស្ថានភាពផ្លូវច្បាប់របស់ពួកគេ និងសកម្មភាពដែលពួកគេអាចធ្វើបានដើម្បីទទួលបានសន្តិសុខដីធ្លី និងលំនៅឋាន។ សហគមន៍មានទំនុកចិត្តក្នុងការចូលរួមកិច្ចប្រជុំជាមួយមន្ត្រីមូលដ្ឋាន និងចរចាអំពីអនាគតរបស់ពួកគេ។ ដូចគ្នានេះដែរ គឺសហគមន៍ឆ្មាអើត ដោយសារតែសាមគ្គីភាពសហគមន៍ និងសកម្មភាពប្រជាសហគមន៍អាចទប់ទល់នឹងការគំរាមកំហែងបណ្តេញចេញ។ការចងក្រងជាសហគមន៍រួមមួយ និងការមានសំឡេង "តែមួយ"ក៏មានសារៈសំខាន់ផងដែរក្នុងការអភិវឌ្ឍផែនការកែលម្អរួមមួយ និងឯកភាពលើលក្ខខណ្ឌសំខាន់ៗសម្រាប់ជម្រើសផ្លាស់ប្តូរទីតាំង ប្រសិនបើវាមានលក្ខណៈសមរម្យសម្រាប់សមាជិកទាំងអស់។មិនមែនសហគមន៍ទាំងអស់មានអារម្មណ៍ថាមានសុវត្ថិភាព និងមានទំនុកចិត្តនៅពេលចូលរួមជាមួយអាជ្ញាធរមូលដ្ឋាននោះទេ។ សមាជិកសហគមន៍ស្ទឹងកំបុតត្រូវបានអាជ្ញាធររាជរដ្ឋាភិបាលគំរាមកំហែង។ ក្នុងពេលជួបជាមួយអភិបាលខណ្ឌពួកគេត្រូវបានគំរាមកំហែង "ប្រសិនបើសមាជិកសហគមន៍បកស្រាយទិដ្ឋភាពផ្លូវច្បាប់ខុសពួក

គេនឹងត្រូវទទួលរងការចោទប្រកាន់"។ ដូចគ្នានេះផងដែរ សកម្មជន ២នាក់ត្រូវបានដកចេញពីជំនួបជាមួយខាងខណ្ឌ នៅពេលដែលពួកគេព្យាយាមសួរដេញដោលពីការបកស្រាយមួយចំនួន។ ដូច្នេះហើយទើបសកម្មជនសហគមន៍ខ្លាចមិនហ៊ាននិយាយក្នុងជំនួបជាមួយសាលារាជធានីភ្នំពេញ និងសាលាខណ្ឌ។ គ្រួសារទាំងអស់ទៅប្រជុំនៅសាលារាជធានីភ្នំពេញ ប៉ុន្តែមានតែសមាជិកសកម្ម៣នាក់ប៉ុណ្ណោះដែលបានសួរសំណួរលើកសំណើទៅសាលាក្រុងភ្នំពេញ។

បច្ចុប្បន្ន សហគមន៍មិននិយាយថា នរណាម្នាក់ជាតំណាងសហគមន៍នោះទេ ដើម្បីបញ្ចៀសស្ថានការណ៍គ្រោះថ្នាក់សម្រាប់ពួកគេ។ ដូច្នេះពួកគេនិយាយក្នុងនាមជាប្រជាពលរដ្ឋរងគ្រោះប៉ុណ្ណោះ។ ប្រជាសហគមន៍បានសម្រេចចិត្តថាមិនមាន រចនាសម្ព័ន្ធ ឬអ្នកដឹកនាំសហគមន៍ទេ ព្រោះប្រសិនបើអាជ្ញាធរមូលដ្ឋានដឹងអំពីតួនាទីពួកគេ នោះនឹងត្រូវចោទប្រកាន់ ឬរងបណ្តឹង ព្រោះពួកគេត្រូវបានអាជ្ញាធរចាត់ទុកថា ជាអ្នកញុះញង់ឱ្យប្រជាសហគមន៍ចេះតវ៉ា។ ប៉ុន្តែពួកគេមានអ្នកដឹកនាំសម្រាប់គម្រោងអភិវឌ្ឍន៍ ហើយពួកគេប្រើប្រាស់ការជួបជុំជាឱកាសដើម្បីពិភាក្សាផងដែរ អំពីសកម្មភាពតស៊ូមតិសម្រាប់សិទ្ធិលំនៅឋាន និងដីធ្លី។ ស្រដៀងគ្នានេះដែរ អាជ្ញាធរមូលដ្ឋានសហគមន៍ស្ត្រីក្លាហានបានប្រាប់តំណាងសហគមន៍ថា "កុំធ្វើសកម្មភាពលើបញ្ហាដីធ្លី បើមិនដូច្នេះទេអ្នកនឹងត្រូវចាប់ដាក់គុក"។ ជាមួយគ្នានេះ ប្រជាសហគមន៍ប្រឈមមុខនឹងការរើសអើងពីអាជ្ញាធរមូលដ្ឋាន បន្ទាប់ពីបានតស៊ូមតិដើម្បីសន្តិសុខដីធ្លី ដោយនៅពេលនោះក្នុងអំឡុងពេលទឹកជំនន់ ប្រជាពលរដ្ឋមួយចំនួនមិនបានទទួលជំនួយស្បៀង ខណៈដែលសហគមន៍ផ្សេងទៀតនៅក្នុងភូមិជាមួយគ្នាទទួលបានជំនួយពេញលេញ។ ដូចគ្នាដែរនៅសហគមន៍សំរោងត្បូងសកម្មជនស្ថិតក្រោមការឃ្លាំមើលរបស់រាជរដ្ឋាភិបាល ហើយសកម្មជន ១៦នាក់បានទទួលដីកាពីតុលាការ ដោយសារសកម្មភាពតស៊ូមតិរបស់ពួកគេ។ ជាងនេះទៅទៀត ប្រជាពលរដ្ឋត្រូវបានអាជ្ញាធរគំរាមកាត់ទឹក និងសេវាផ្សេងៗ ដោយសារជាប់ពាក់ព័ន្ធនឹងសកម្មភាពតស៊ូមតិ។ ដោយសារតែបញ្ហានេះ ប្រជាសហគមន៍មានការភ័យខ្លាចក្នុងការធ្វើសកម្មភាពតស៊ូមតិ។ ដូចគ្នាដែរ ប្រជាពលរដ្ឋក្នុងសហគមន៍កៅពីរបានរងការគំរាមកំហែងក្នុងការធ្វើសកម្មភាពតស៊ូមតិ ទោះបីជាប្រជាសហគមន៍ទាំងនោះប្រើប្រាស់ការតស៊ូមតិបែបទន់ភ្លន់ និងអហិង្សាជាគោលការណ៍ក៏ដោយ។

សហគមន៍មួយចំនួនដូចជា កៅពីរ និងអណ្តូងតាអៀងបានជួបប្រទះបញ្ហាមួយចំនួន ដូចជាកង្វះសាមគ្គីភាពរវាងប្រជាជនក្នុងសហគមន៍ដែលធ្វើឱ្យសហគមន៍ជួបប្រទះបញ្ហាសង្គម និងអសន្តិសុខកាន់តែច្រើន ទោះបីជាសមាជិកនៃសហគមន៍ក្រីក្រដូចជាកៅពីរមានឆន្ទៈបន្តធ្វើការរួមគ្នា និងតស៊ូមតិដើម្បីដីធ្លី និងអនាគតរបស់កូនៗរបស់ពួកគេក៏ដោយ។

សហគមន៍ ក៏បានពង្រឹងសមត្ថភាពដើម្បីស្វែងរកវិធានការដោះស្រាយបញ្ហាដីធ្លី ដើម្បីបញ្ចៀសពីការបណ្តេញចេញ។ ប្រជាសហគមន៍ស្ទឹងកំបុតបានរួមគ្នាបដិសេធការជូនដំណឹងពីការបណ្តេញចេញ ដែលអាជ្ញាធរមូលដ្ឋានបានបិទនៅលើជញ្ជាំងផ្ទះរបស់ពួកគេ។ សេចក្តីជូនដំណឹងបញ្ជាក់ថា អាជ្ញាធរមូលដ្ឋានមិនអនុញ្ញាតឱ្យប្រជាសហគមន៍ជួលបន្ទប់ឱ្យអ្នកដទៃឡើយ។ ជាមួយគ្នានេះ ប្រជាសហគមន៍បានទទួលការជូនដំណឹងពីការបណ្តេញចេញដោយបញ្ជាក់ថា ពួកគេមានពេលត្រឹមតែមួយសប្តាហ៍ប៉ុណ្ណោះក្នុងការរើចេញ ប៉ុន្តែប្រជាសហគមន៍បានរួមគ្នាមិនទទួលយកសេចក្តីជូនដំណឹងនោះទេ។ រហូតមកដល់ពេលនេះ ព័ត៌មានអំពីការបណ្តេញចេញ

ត្រូវបានសួប់ស្ងាត់ទៅវិញ ហើយសហគមន៍ក៏មិនដឹងថា ការជូនដំណឹងថ្មីនឹងមាននៅពេលណានោះដែរ។ ក្នុងករណីដែលសហគមន៍មានកម្រិតភាពក្រីក្រ ទាបដូចជានៅក្នុងសហគមន៍ស្ត្រីក្លាហានជាដើម អ្នករស់នៅទីនោះជាសហគមន៍តូច និងមាន ពេលវេលាតិចតួច ក្នុងការចូលរួមក្នុងសកម្មភាព សហគមន៍ ហេតុដូច្នេះពួកគេងាយរងគ្រោះជាង គេ។ ករណីដូចគ្នានឹងសហគមន៍ស្នេហាសាមគ្គីដែរ ដែលប្រជាពលរដ្ឋលែងចាប់អារម្មណ៍ ឬមិនមាន ពេលចូលរួមប្រជុំសហគមន៍ និងបង្កើតផែនការ តស៊ូមតិ។ មនុស្សភាគច្រើនចូលរួមកិច្ចប្រជុំនៅ ពេលមានមន្ត្រីរដ្ឋាភិបាលចូលរួម។ អ្នកចូលរួមក្នុង កិច្ចពិភាក្សាក្រុមស្នូលមកពី សហគមន៍ស្នេហាសាមគ្គី បានលើកឡើងថា៖

*“ប្រជាជនក្នុងសហគមន៍មានការមមាញឹក ដូច្នេះ ពួកគេមិនអាចចូលរួមក្នុងសកម្មភាពតស៊ូមតិ និងមិនបានយកចិត្តទុកដាក់ចូលរួមប្រជុំ និងវគ្គ បណ្តុះបណ្តាល។ ប្រជាសហគមន៍មួយចំនួន មិនគិតពីផែនការអនាគតរបស់ពួកគេ ហើយមិន ផ្តល់តម្លៃដល់ការងាររបស់សហគមន៍។ ពួកគេ មិនយល់អំពីផលប្រយោជន៍របស់សហគមន៍ នោះទេ។”*

# លទ្ធផលពីការស្ទង់មតិគ្រួសារ

## ព័ត៌មានប្រជាសាស្ត្រ និងសាវតា

ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ចំនួន២៧៤ នាក់ដែលរស់នៅក្នុងសហគមន៍ក្រីក្រក្នុងសហគមន៍ ទាំង ១១ មាន ៧៧% ជាស្ត្រី និង ៥២,៥៥% ជា មេគ្រួសារ (៤១,៦១% ជាប្រពន្ធ)។ អ្នកផ្តល់ បទសម្ភាសន៍ទាំងអស់ជាជនជាតិខ្មែរ (១០០%) គ្រួសារនីមួយៗមានសមាជិកច្រើនរស់នៅជា មួយគ្នា។ ទិន្នន័យបានបង្ហាញថាគ្រួសារដែលមាន សមាជិកពី ៥-៧នាក់ ក្នុងមួយគ្រួសារមាន (៤០,៥១%), ២-៤ នាក់មាន (២៤,៨២%) រហូតដល់ ៧-១០ នាក់មាន (២០,៤៤%) និង សមាជិកលើសពី ១០ នាក់ (៧,៦៦%)។



រូបភាពទី៧៖ ទិដ្ឋភាពនៃសហគមន៍ពង្រសែនជ័យ

## តារាងទី៧៖ ចំនួនអ្នកផ្តល់បទសម្ភាសន៍ក្នុងមួយសហគមន៍

| ឈ្មោះទីតាំង | ភូមិ | សង្កាត់ | ខណ្ឌ | ភាគរយ | សំណាក |
|---|---|---|---|---|---|
| អណ្តូងតាអៀង | ព្រែកថ្មី | ព្រែកថ្មី | ច្បារអំពៅ | ៥,៨ | ១៦,០ |
| បឹងឈូកមានជ័យថ្មី២ | បឹងឈូក | និរោធន៍ | ច្បារអំពៅ | ៣,៦ | ១០,០ |
| ឆ្មាអើត | ចំពុះក្អែក | ព្រែកថ្មី | ច្បារអំពៅ | ៤,៤ | ១២,០ |
| កៅពីរ | ត្រពាំងស្វាយ | គោកឃ្លាង | សែនសុខ | ១២,០ | ៣៣,០ |
| ពង្រសែនជ័យ | ទួលពង្រ | ចោមចៅទី១ | ពោធិ៍សែនជ័យ | ១៤,២ | ៣៩,០ |
| ស្មើសាមគ្គី | ឫស្សីទីពីរ និង ឫស្សីទបី | ស្ទឹងមានជ័យ៣ | មានជ័យ | ៨,៤ | ២៣,០ |
| សាមគ្គីរុងរឿង | ភូមិ៥ | ផ្សារដើមថ្កូវ | ចំការមន | ៩,៥ | ២៦,០ |
| សំពោងត្បូង | សំពោងត្បូង | សំពោង | ព្រែកព្នៅ | ១០,៩ | ៣០,០ |
| ស្ត្រីក្លាហាន | ក្រោលគោ | គីឡូម៉ែត្រ៦ | ឫស្សីកែវ | ៤,៤ | ១២,០ |
| ស្ទឹងកំបុត | ឡកំបោរ | ស្វាយប៉ាក | ឫស្សីកែវ | ២៣,០ | ៦៣,០ |
| ទំនប់តាថ្វាង | ចំពុះក្អែក | ព្រែកថ្មី | ច្បារអំពៅ | ៣,៦ | ១០,០ |
| សរុប | ១១ | ៩ | ៦ | ១០០,០ | ២៧៤,០ |

## ព័ត៌មានអំពីជីវភាព និងប្រាក់ចំណូល

មេគ្រួសារដែលប្រកបមុខរបរសេដ្ឋកិច្ចក្នុងប្រព័ន្ធ (២៧,០៧%) សេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមានដូចជា កម្មករសំណង់ អ្នកបើកបរ អ្នករើសអេតចាយ អ្នកលក់ដូរតាមដងផ្លូវ អ្នកលក់អីវ៉ាន់តាមផ្ទះ (៦៨,៤៧%) និងអ្នកគ្មានការងារធ្វើ (៤,៤៦%)។ ប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមរបស់គ្រួសារគឺ ១-១០ ដុល្លារ (៧១,៥៣%) ១០-២០ ដុល្លារ (១៤,២៣%) និង ២០-៣០ ដុល្លារ (៣,២៨%) ខណៈ១០,២២%នៃមេផ្ទះមិនមានប្រាក់ចំណូលសោះ។ កន្លែងធ្វើការរបស់មេគ្រួសារភាគច្រើនស្ថិតនៅក្រៅខណ្ឌនៃរាជធានីភ្នំពេញ (៦១,៦៨%) និងនៅក្នុងខណ្ឌ (៣៦,៨៦%) ហើយមិនខុសពីកន្លែងធ្វើការរបស់សមាជិកគ្រួសាររបស់ពួកគេទេ ទាំងអ្នកធ្វើការខាងក្រៅខណ្ឌ (៦១,៦៨%) និងខណ្ឌខាងក្នុង[២១] (៣៦,៨៦%)។ គ្រួសារទទួលបានការគាំទ្រផ្នែកសុខុមាលភាព និងសុខភាពពីកម្មវិធីផ្សេងៗគ្នាដូចជាប័ណ្ណក្រីក្រ (៤៦,០៣%) មូលនិធិសមធម៌សុខភាព (១២,២៥%) ក្រុមសន្សំសហគមន៍ (១០,២៦%) បេឡាជាតិរបបសន្តិសុខសង្គម (៩,៩៣%)។

២១ ខណ្ឌខាងក្នុង៖ ខណ្ឌចំការមន ខណ្ឌដូនពេញ ខណ្ឌ ៧មករា ខណ្ឌមានជ័យ ខណ្ឌសែនសុខ និងខណ្ឌបឹងកេងកង។

### តារាងទី៨៖ ប្រាក់ចំណូលប្រចាំថ្ងៃក្នុងមួយសហគមន៍

| ឈ្មោះសហគមន៍ និងទំហំប្រាក់ចំណូលទៅតាមខ្នងផ្ទះ | អណ្តូងតាអៀង | បឹងឈូកមានជ័យថ្មី២ | ផ្លាអើត | កៅពីរ | ពង្រសែនជ័យ | ស្មើសាមគ្គី | សាមគ្គីរុងរឿង | សំពោងត្បូង | ស្រែក្លាហាន | ស្ទឹងកំបុត | ទំនប់តាថ្លាង | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១-១០ ដុល្លារ | ១៤,0 | ៧,0 | ១០,0 | ២០,0 | ៣៣,0 | ៩,0 | ១៨,0 | ២៤,0 | ១០,0 | ៤១,0 | ១០,0 | ១៩៦,0 | ៧១,៦ |
| ១០-២០ ដុល្លារ | ១,0 | ១,0 | 0,0 | ១០,0 | ២,0 | ១៣,0 | ៤,0 | ៤,0 | 0,0 | ៤,0 | 0,0 | ៣៩,0 | ១៤,២ |
| ២០-៣០ ដុល្លារ | 0,0 | ១,0 | ១,0 | ២,0 | 0,0 | ១,0 | ៣,0 | 0,0 | ១,0 | 0,0 | 0,0 | ៩,0 | ៣,៣ |
| ៣០-៤០ដុល្លារ | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | ១,0 | ១,0 | 0,0 | 0,0 | 0,0 | ២,0 | 0,៧ |
| ៤០-៥០ ដុល្លារ | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 |
| ច្រើនជាង ៥០ ដុល្លារ | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 | 0,0 |
| គ្មានប្រាក់ចំណូល | ១,0 | ១,0 | ១,0 | ១,0 | 4,0 | 0,0 | 0,0 | ១,0 | ១,0 | ១៨,0 | 0,0 | ២៨,0 | ១០,២ |
| សរុប | ១៦,0 | ១០,0 | ១២,0 | ៣៣,0 | ៣៩,0 | ២៣,0 | ២៦,0 | ៣០,0 | ១២,0 | ៦៣,0 | ១០,0 | ២៧៤,0 | ១០០,0 |

## ព័ត៌មានអំពីដីធ្លី និងលំនៅឋាន

ដូចដែលបានពន្យល់នៅក្នុងការពិភាក្សាជាក្រុម សហគមន៍ទាំងអស់ដែលបានស្ទង់មតិក្នុងការសិក្សានេះកាន់កាប់ប្រភេទដីសាធារណៈរបស់រដ្ឋដែលបានកំណត់មួយចំនួន។ ដោយសារតែបញ្ហានេះ សហគមន៍ទាំងនេះប្រឈមនឹងអសុវត្ថិភាពដីធ្លី និងលំនៅឋានខ្ពស់។

ភាគច្រើននៃអ្នកផ្តល់បទសម្ភាសន៍រស់នៅលើដីដែលមានផ្ទះប៉ុណ្ណោះ (៩៦,៣៥%) និងដីដែលមានផ្ទះ និងសួនច្បារ (៣,៦៥%)។ ក្នុងចំណោមគ្រួសារទាំងនេះ (៤០,១៥% )ដំបូងពួកគេបានផ្លាស់ទៅរស់នៅក្នុងសហគមន៍បច្ចុប្បន្នរបស់ពួកគេចន្លោះឆ្នាំ ១៩៩០-២០០០ ខណៈពេលដែលអ្នកផ្សេងទៀត (៣០,៦៦%) បានផ្លាស់ចេញរវាងឆ្នាំ ២០០១-២០១០ និង (១៦,៧៩%) បានផ្លាស់ចេញថ្មីៗនេះក្នុងឆ្នាំ ២០១១-២០២៣ និង (១២,៤១%) នៃគ្រួសារបានផ្លាស់ចេញរវាងឆ្នាំ ១៩៧៩-១៩៨៩។ ទំហំដីពួកគាត់ (៧,៥-៥០ ម²) (៤៧,៤៥%), ៥១-១០០ ម² (៣១,៧៥%), ១០១-២០០ ម² (៨,០៣%) មានតែ ៦,២០% នៃគ្រួសាររស់នៅលើដីទំហំ ៥០១-៨០០ម២ គ្រួសារភាគច្រើន (៨១,៣៩%) បានទិញដីដែលពួកគេកំពុងរស់នៅ គ្រួសារផ្សេងទៀត (១០,៥៨%) បានឈូសឆាយដីដោយខ្លួនឯង ហើយ (៤,៧៤% ) បានទទួលដីពីប្រភពផ្សេងៗគ្នា ឧទាហរណ៍មរតកគ្រួសារ។ល។ មានតែ (១,៤៦%) នៃគ្រួសារដែលនិយាយថាដីរបស់ពួកគេត្រូវបានផ្តល់ឱ្យដោយអាជ្ញាធរ។ មានប្រជាពលរដ្ឋសរុបចំនួន (៥៦.២០%) ដែលបានទិញដីបាននិយាយថា ពួកគេមានកិច្ចសន្យាទិញលក់ និង (៥០,៣៦%) នៃកិច្ចសន្យាទិញលក់មានសាក្សី (មានហត្ថលេខា) ដោយមន្ត្រីភូមិ ឃុំ។ អ្នកផ្តល់បទសម្ភាសន៍ក៏បានលើកឡើងផងដែរថា ពួកគេជាប់បំណុលទិញដី (១៧,៥២%) ដូចជាកម្ចីធនាគារ (៩,៦៤%) កម្ចីមីក្រូហិរញ្ញវត្ថុ (៨,០៣%) និងកម្ចីក្រៅផ្លូវការ (៤,០២%)។ ប្រជាពលរដ្ឋសរុបចំនួន (៧៦,៣១%) បានប្រើប្រាស់ប្រាក់សន្សំរបស់គ្រួសារពួកគេដើម្បីទិញដី។

*តារាងទី៩៖ ប្រភេទនៃហិរញ្ញវត្ថុសម្រាប់លំនៅឋាន*

| ប្រភេទថវិកានៃការសាងសង់ផ្ទះ | អណ្តូងតាអៀង | បឹងឈូកមានជ័យថ្មី២ | ផ្លាអើត | កៅពីរ | ពង្រសែនជ័យ | រស្មីសាមគ្គី | សាមគ្គីរុងរឿង | សំរោងត្បូង | ស្រ្តីក្លាហាន | ស្ទឹងកំបុត | ទំនប់តាថ្លាង | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការសន្សំលក្ខណៈគ្រួសារ ឬ បុគ្គល | ៤,០ | ៧,០ | ៨,០ | ២៩,០ | ៣៦,០ | ២០,០ | ១៦,០ | ២១,០ | ៥,០ | ៤៥,០ | ១,០ | ១៩០,០ | ៧៦,៣ |
| ប្រាក់កម្ចីធនាគា | ០,០ | ១,០ | ២,០ | ០,០ | ០,០ | ៣,០ | ២,០ | ២,០ | ១,០ | ១០,០ | ៣,០ | ២៤,០ | ៩,៦ |
| មីក្រូហិរញ្ញវត្ថុ | ០,០ | ១,០ | ១,០ | ២,០ | ៥,០ | ០,០ | ០,០ | ៣,០ | ០,០ | ៧,០ | ១,០ | ២០,០ | ៨,០ |
| ប្រាក់កម្ចីមិនផ្លូវការ | ០,០ | ០,០ | ១,០ | ០,០ | ០,០ | ០,០ | ២,០ | ៣,០ | ១,០ | ៣,០ | ០,០ | ១០,០ | ៤,០ |
| ផ្សេងៗ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ១,០ | ៣,០ | ១,០ | ០,០ | ៥,០ | ២,០ |
| សរុប | ៤,០ | ៩,០ | ១២,០ | ៣១,០ | ៤០,០ | ២៣,០ | ១៩,០ | ៣០,០ | ១០,០ | ៦៦.០ | ៥,០ | ២៤៩,០ | ១០០,០ |

ដីប្រជាពលរដ្ឋសរុបចំនួន ៩០,៥១% មិនទាន់បានចុះបញ្ជី។មានគ្រួសារតែ(១,៤៦%)ប៉ុណ្ណោះដែលបានដាក់ពាក្យសុំចុះបញ្ជីដីធ្លីទទួលបានប័ណ្ណកម្មសិទ្ធដីធ្លី ចំណែកគ្រួសារចំនួន (២,៩២%) បានដាក់ពាក្យសុំចុះបញ្ជីដីធ្លី (ប៉ុន្តែមិនទាន់បានអនុវត្ត)ឬកំពុងស្ថិតក្នុងដំណើរការស្វែងមតិដីធ្លី។ រយៈពេលចុះឈ្មោះគឺនៅឆ្នាំ២០០៦(០,៣៦%), ២០១៩ (២,៥៥%), និង២០២៣ (១,០៩%)។ អ្នកឆ្លើយសំណួរផ្សេងទៀត (១២,២៧%) បាននិយាយថា ពួកគេមានលិខិតបញ្ជាក់សិទ្ធិកាន់កាប់បង្កាន់ដៃពាក្យស្នើសុំ (៩,៥១%) កិច្ចសន្យាលក់ (៤២,៦៤%) និងដីចែកឱ្យ ឬសម្បទានដីពីអាជ្ញាធរមូលដ្ឋាន (០,៩២%)។ អ្នកផ្សេងទៀតបានបង្ហាញពីសិទ្ធិកាន់កាប់ឬកម្មសិទ្ធិនៃទីកន្លែងដែលពួកគេកំពុងរស់នៅថា ពួកគេស្គាល់គ្នាទៅវិញទៅមក និងឬស្គាល់តំណាងសហគមន៍ និងអ្នកជិតខាងអ្នកផ្សេងទៀតនិយាយថាពួកគេបានផ្ទេរកិច្ចព្រមព្រៀង ដែលទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន និងសៀវភៅស្នាក់នៅ។



*រូបភាពទី៨៖ សហគមន៍ផ្លាអើត*

## តារាងទី១០៖ ចំនួនគ្រួសារដែលមានការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។

| តើដីរបស់អ្នកបានចុះបញ្ជីដីធ្លីជាប្រព័ន្ធដែរឬទេ? | អណ្ដូងតាអៀង | បឹងឈូកមានជ័យថ្មី២ | ផ្ទាអើត | កៅពីរ | ពង្រសែនជ័យ | ស្មើសាមគ្គី | សាមគ្គីរុងរឿង | សំរោងត្បូង | ស្ត្រីភ្លាហាន | ស្ទឹងកំបុត | ទំនប់តាថ្លាង | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទេ | ១៤ | ៩ | ១២ | ៣៣ | ៣៩ | ១៤ | ២០ | ២៩ | ១២ | ៦៣ | ៣ | ២៤៨ | ៩០,៥ |
| អត់ដឹង | ២ | ១ | ០ | ០ | ០ | ៨ | ៣ | ០ | ០ | ០ | ០ | ១៤ | ៥,១ |
| បាទ/ចាស | ០ | ០ | ០ | ០ | ០ | ១ | ៣ | ១ | ០ | ០ | ៧ | ១២ | ៤,៤ |
| សរុប | ១៦ | ១០ | ១២ | ៣៣ | ៣៩ | ២៣ | ២៦ | ៣០ | ១២ | ១៣ | ១០ | ២៧៤ | ១០០ |

## ការបណ្ដេញចេញ និងព័ត៌មានអំពីបញ្ហាសន្តិសុខ

មានអ្នកឆ្លើយសំណួរសរុបចំនួន (៦០,២២%) បានជួបប្រទះ ឬត្រូវបានគំរាមកំហែងជាមួយនឹងការបណ្ដេញចេញពីដីឬផ្ទះរបស់ពួកគេ ហើយ (៦០,៩៥%) បាននិយាយថាការតាំងទីលំនៅរបស់ពួកគេកំពុងប្រឈមនឹងការបណ្ដេញចេញ និងឬទទួលរងសម្ពាធឱ្យផ្លាស់ទីលំនៅ។ ប្រជាសហគមន៍បានទទួលការជូនដំណឹងអំពីការបណ្ដេញចេញដោយពាក្យសំដី (៤៦,០៧%) តាមរយៈពាក្យចចាមអារ៉ាម ការនិយាយតៗគ្នា (២៨,៣៧%) និងការប្រជុំផ្លូវការ (១៣,៧៦%)។ ប្រជាសហគមន៍បានទទួលព័ត៌មានពីការបណ្ដេញចេញតាមរយៈសង្កាត់ (៣២,២២%) ខណ្ឌ (២៦,៤៤%) ភូមិ និងឬប្រធានសហគមន៍ (១១,៧៣%)។ ខណៈអ្នកឆ្លើយសំណួរផ្សេងទៀតបាននិយាយថា ពួកគេបានទទួលព័ត៌មានពីសាលាក្រុងភ្នំពេញ (៣,២៨%)។ ប្រជាសហគមន៍សរុបចំនួន (៥០,៣៦%) មិនប្រាកដ ឬមិនដឹងអំពីហេតុផលនៃការបណ្ដេញចេញ ខណៈពេលដែលអ្នកឆ្លើយផ្សេងទៀតបាននិយាយថា ដោយសារតែការអភិវឌ្ឍសាធារណៈ (៤០,៨៨%) ឬគម្រោងអភិវឌ្ឍន៍ឯកជន (៨,៧៦%)។ ការបណ្ដេញចេញភាគច្រើនទាក់ទងនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធដូចជាការពង្រីកបើកទទឹងផ្លូវដែលមានស្រាប់ឱ្យធំ (២៧,០១%), ការកែលម្អប្រឡាយ (៨,៣៩%), ការស្ថាបនាស្ពាន/ផ្លូវថ្មី (៥,១១%) និងសំណង់អគារ (៤,៣៨%)។

## *ក្រាហ្វិកទី២៖ គ្រួសារប្រឈមនឹងការបណ្ដេញចេញ (គិតជាភាគរយ)*




## *តារាងទី១១៖ តើការតាំងទីលំនៅប្រឈមមុខនឹងការបណ្ដេញចេញ ឬមានសម្ពាធក្នុងការផ្លាស់ទីលំនៅដែរឬទេ?*

| សហគមន៍ | អណ្ដូងតាអៀង | បឹងឈូកមានជ័យថ្មី២ | ផ្ទាអើត | កៅពរី | ពង្រសែនជ័យ | រស្មីសាមគ្គី | សាមគ្គីរុងរឿង | សំពោងត្បូង | ស្ត្រីក្លាហាន | ស្ទឹងកំបុត | ទំនប់តាថ្លាង | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បាទ | ៤ | ៧ | ៧ | ៣៣ | ២៣ | ៥ | ៨ | ២៩ | ៤ | ៤៣ | ៤ | ១៦៧ | ៦៩ |
| ចាស | ៨ | ៣ | ៤ | ០ | ១៤ | ១៧ | ១៥ | ១ | ៧ | ៧ | ៤ | ៨០ | ២៩,២ |
| គ្មានបញ្ហាអ្វីនោះទេ | ៤ | ០ | ១ | ០ | ២ | ១ | ៣ | ០ | ១ | ១៣ | ២ | ២៧ | ៩,៩ |

## *តារាងទី១២៖ មូលហេតុនៃការបណ្តេញចេញ ឬការផ្លាស់ទីលំនៅ*

តើអ្វីជាហេតុផលសម្រាប់ការបណ្តេញចេញ ឬផ្លាស់ប្តូរទីលំនៅ?

| | ការសាងសង់អគារ | ការកែលម្អប្រឡាយ | សោភ័ណភាពទីក្រុង | ការពង្រីកផ្លូវ និងពង្រីកផ្លូវដែលមានស្រាប់ | បឹងដែលគេបោះបង់ (មិនដឹងមូលហេតុ) | កែលម្អកន្លែងបៃតង | ការសាងសង់ស្ពាន និងផ្លូវថ្មីៗ | ការកែលម្អច្រាំងទន្លេ | មិនដឹង ឬ មិនច្បាស់ | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| អណ្តូងតាអៀង | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១៥ | ០ | ១៦ |
| បឹងឈូកមានជ័យថ្មី២ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៥ | ៤ | ១០ |
| ធ្នាអើត | ០ | ០ | ០ | ១ | ០ | ០ | ១ | ០ | ១០ | ០ | ១២ |
| កៅពីរ | ០ | ០ | ០ | ២៤ | ០ | ០ | ០ | ០ | ៩ | ០ | ៣៣ |
| ពង្រសែនជ័យ | ០ | ០ | ០ | ៦ | ០ | ០ | ០ | ០ | ៣៣ | ០ | ៣៩ |
| រស្មីសាមគ្គី | ០ | ១៧ | ០ | ៣ | ០ | ០ | ០ | ០ | ២ | ១ | ២៣ |
| សាមគ្គីរុងរឿង | ១ | ៤ | ១ | ១ | ០ | ១ | ១៣ | ០ | ៦ | ០ | ២៦ |
| សំពោងត្បូង | ៩ | ០ | ០ | ៩ | ០ | ០ | ០ | ០ | ១២ | ០ | ៣០ |
| ស្រ្តីក្លាហាន | ០ | ០ | ១ | ០ | ០ | ០ | ០ | ០ | ១១ | ០ | ១២ |
| ស្ទឹងកំបុត | ០ | ០ | ០ | ៣១ | ០ | ០ | ០ | ០ | ៣២ | ០ | ៦៣ |
| ទំនប់តាថ្លាង | ០ | ២ | ០ | ០ | ០ | ០ | ០ | ០ | ៨ | ០ | ១០ |
| សរុប | ១២ | ២៣ | ២ | ៧៤ | ០ | ១ | ១៤ | ០ | ១៤៣ | ៥ | ២៧៤ |
| ភាគរយ | ៤,៤ | ៨,៤ | ០,៧ | ២៧ | ០ | ០,៤ | ៥,១ | ០ | ៥២,២ | ១,៨ | ១០០ |

សមាជិកសហគមន៍មួយចំនួនត្រូវបានផ្តល់សំណង (១៤,៦០%) រួមទាំងដីមួយឡូតិ៍ដែលមានថវិកាមួយចំនួនតាមទំហំដីដែលរងផលប៉ះពាល់(៤,៣៨%)ខ្លះស្តាប់ឮថាត្រូវរើទៅកន្លែងផ្លាស់ប្តូរទីលំនៅថ្មី (១,៤៦%) និងសំណងសម្រាប់ដីរបស់ពួកគេ (៨,៧៦%)។ ដោយសារតែការគំរាមបណ្តេញចេញ អាជ្ញាធរមូលដ្ឋានមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋសង់ផ្ទះរឹងមាំ (១៣,៥០%) ប្រជាពលរដ្ឋរស់នៅដោយភាពភ័យខ្លាច និងមានអារម្មណ៍មិនមានសុវត្ថិភាព និងអសន្តិសុខ (១១,៦៨%) អាជ្ញាធរមូលដ្ឋានមិនចេញប័ណ្ណកម្មសិទ្ធិដីធ្លី ដោយសារកង្វះខាតឯកសារគាំទ្រ (៤,០១%) ដីមិនមានសុវត្ថិភាព និងគ្មានសុវត្ថិភាពពេលរស់នៅលើលំនៅឋានមិនសមរម្យ (១,៨២%)។ អ្នកផ្តល់បទសម្ភាសន៍មួយចំនួនបានលើកឡើងថា "ការបណ្តេញចេញពីផ្ទះរបស់យើងមានន័យថាគ្មានជីវិត" ហើយ (៧០,៤៤%) នៃអ្នកផ្តល់បទសម្ភាសន៍មានអារម្មណ៍ថាអសុវត្ថិភាពរស់នៅក្នុងដីរបស់ពួកគេពីការមិនប្រឈមមុខនឹងការបណ្តេញចេញ (៧០,៤៤%)។

## *តារាងទី១៣៖ ប្រភពព័ត៌មានអំពីការបណ្តេញចេញ*

| តើអ្វីជាប្រភពនៃព័ត៌មាននេះ? | អណ្តូងតាអៀង | បឹងឈូកមានជ័យថ្មី២ | ធ្នាអើត | កោពីរ | ពង្រសែនជ័យ | ស្មើសាមគ្គី | សាមគ្គីរុងរឿង | សំពោងត្បូង | ស្ត្រីក្លាហាន | ស្ទឹងកំបុត | ទំនប់តាថ្លាង | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ក្រុមហ៊ុន | ០ | ០ | ០ | ០ | ០ | ០ | ០ | ២ | ០ | ១៩ | ០ | ៦១ | ១១,៤ |
| កម្រិតខណ្ឌ | ០ | ១ | ០ | ៣៣ | ១៧ | ១ | ៧ | ២៩ | ០ | ៥៤ | ០ | ១៤២ | ២៦,៤ |
| ម្ចាស់ផ្ទះ | ០ | ០ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ០,២ |
| អ្នកជិតខាង ឬមិត្តភក្តិ | ៩ | ៤ | ០ | ០ | ១៨ | ០ | ៤ | ០ | ១០ | ១៥ | ២០ | ៦២ | ១១,៥ |
| កម្រិតសង្កាត់ | ៣ | ២ | ៦ | ៣៣ | ១៧ | ១៣ | ១៦ | ២៥ | ០ | ៥៥ | ៣ | ១០៣ | ៣២,០ |
| មេភូមិ ឬ មេឃុំ | ៣ | ០ | ៨ | ០ | ៣ | ៤ | ៥ | ១ | ០ | ៣៥ | ៤ | ១៦៣ | ១១,៧ |
| ផ្សេងៗ | ២ | ៥ | ២ | ០ | ៥ | ៦ | ២ | ១ | ២ | ៩ | ១ | ៣៥ | ៦,៥ |
| សរុប | ១៧ | ១២ | ១៧ | ៨៩ | ៧៧ | ២៤ | ៣៤ | ៥៨ | ១២ | ១៨៧ | ១០ | ៥៣៧ | ១០០ |

## ការចូលរួមនៅក្នុងសហគមន៍ និងសកម្មភាពតស៊ូមតិ

ភាគច្រើននៃអ្នកផ្តល់បទសម្ភាសន៍(៩៧,០៨%) បាននិយាយថាពួកគេឬសមាជិកគ្រួសាររបស់ពួកគេចូលរួមក្នុងសកម្មភាពសហគមន៍។ អ្នកផ្តល់បទសម្ភាសន៍សរុបចំនួន(៣៨,៦៨%)បាននិយាយថាពួកគេបានចូលរួមក្នុងសកម្មភាពតស៊ូមតិសម្រាប់សុវត្ថិភាពដីធ្លី និងលំនៅឋាន រួមទាំងសកម្មភាពសាងសង់ផ្សេងៗដូចជាផ្លូវថ្នល់ (២១,៦៥%) ជាអ្នកដឹកនាំសហគមន៍ ឬសមាជិកនៃគណៈកម្មការ(១៤,៧១%)ចូលរួមក្នុងការប្រារព្ធពិធីបុណ្យប្រចាំឆ្នាំ និងពិធីជប់លៀងផ្សេងៗ(១៣,២២%) និងជាសមាជិកក្រុមសន្សំសហគមន៍ (១០,៧៤%)។ ប្រជាសហគមន៍យល់ឃើញថាសកម្មភាពសហគមន៍មានប្រយោជន៍ដល់សហគមន៍ (៩៧,៤៥%)។ ឧទាហរណ៍ អ្នកផ្តល់បទសម្ភាសមួយចំនួនបាននិយាយថា (១៩,៦៤%) សហគមន៍អាចធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់ប្រព័ន្ធលូ(១៩,៦៤%)ការយល់ដឹងអំពីសិទ្ធិដីធ្លី និងលំនៅឋាន និងការអប់រំ (៣០,១០%) ការកសាងទំនុកចិត្តក្នុងចំណោមសមាជិកសហគមន៍ (២៣,៦៤%)។ការកសាងទំនាក់ទំនងជាមួយអាជ្ញាធររាជរដ្ឋាភិបាល(១២,៥៣%)។ទោះបីជាយ៉ាងណាក៏ដោយអ្នកផ្តល់បទសម្ភាសន៍ទទួលស្គាល់ទិដ្ឋភាពអវិជ្ជមានដោយសារតែសកម្មភាពសហគមន៍ដូចជាហានិភ័យនៃការបណ្តេញចេញ(៣៦,៨៤%) ទំនាក់ទំនងមិនល្អជាមួយរាជរដ្ឋាភិបាល និងឬអាជ្ញាធរមូលដ្ឋាន(២៨,៩៥%)ការបាត់បង់ធនធានសហគមន៍ (២១,០៥%) ការដឹកនាំមិនបានល្អ (១៣,១៦%)។សមាជិកសហគមន៍ដែលសកម្មបានជួបប្រទះបញ្ហាដោយសារតែការចូលរួមរបស់ពួកគេទទួលរងផលប៉ះពាល់ពីសកម្មភាពតស៊ូមតិរបស់ពួកគេ។ឧទាហរណ៍(៥៤,៣៨%) នៃអ្នកផ្តល់បទសម្ភាសន៍បាននិយាយថា ប្រាក់ចំណូលរបស់ពួកគេបានធ្លាក់ចុះ(៤,៧៤%)និង

បាននិយាយថា ពួកគេត្រូវបានចោទប្រកាន់នៅក្នុងតុលាការ (៣៩,៤២%) និងបានជួបប្រទះបញ្ហាផ្សេងទៀត។ ដូច្នេះ សមាជិកជាច្រើនបានសម្ដែងការមិនពេញចិត្តចំពោះសកម្មភាពសហគមន៍ដែលបានអនុវត្តន៍នៅក្នុងការតាំងទីលំនៅរបស់ពួកគេ។

*តារាងទី១៤៖ ការចូលរួមក្នុងសហគមន៍ និងសកម្មភាពតស៊ូមតិ*

| ការចូលរួមនៅក្នុងសហគមន៍ | អណ្តូងតាអៀង | បឹងឈូកមានជ័យថ្មី២ | ផ្ទាអើត | កៅពីរ | ពង្រសែនជ័យ | រស្មីសាមគ្គី | សាមគ្គីរុងរឿង | សំពោងត្បូង | ស្ត្រីក្លាហាន | ស្ទឹងកំបុត | ទំនប់តាថ្លាង | ផ្សេងៗ | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទេ | ០ | ០ | ០ | ០ | ០ | ០ | ១ | ០ | ០ | ០ | ០ | ១ | ០,៤ |
| អត់ដឹង | ០ | ១ | ០ | ០ | ១ | ២ | ៣ | ០ | ០ | ០ | ០ | ៧ | ២,៦ |
| បាស | ១៦ | ៩ | ១២ | ៣៣ | ៣៨ | ២១ | ២២ | ៣០ | ១២ | ៦៣ | ១០ | ២៦៦ | ៩៧ |
| សរុប | ១៦ | ១០ | ១២ | ៣៣ | ៣៩ | ២៣ | ២៦ | ៣០៩ | ១២ | ៦៣ | ១០ | ២៧៤ | ១០០ |

អ្នកផ្តល់បទសម្ភាសន៍ ដែលមានអាទិភាពខ្ពស់សម្រាប់ការតាំងទីលំនៅ គឺអាចដាក់ស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីជាប្រព័ន្ធ (៦៩,០៥%) ការផ្លាស់ទីលំនៅទៅកន្លែងផ្សេងទៀត (៩,១៨%) ការចងក្រងក្រុមសន្សំប្រាក់ (៨,៨៤%) និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ (៤,៤២%) ។

# តារាងទី១៥៖ អាទិភាពចម្បងសម្រាប់ការតាំងទីលំនៅ

| | ស្នើសុំដំណើរការផ្ដល់ប័ណ្ណ កម្មសិទ្ធិដីធ្លីជាប្រព័ន្ធ | ការកសាងសមត្ថភាពសមាជិក លើសិទ្ធិដីធ្លី និងលំនៅឋាន | ការចងក្រងសហគមន៍ | ការបណ្ដុះបណ្ដាលសហគមន៍ ក្នុងភាពជាអ្នកដឹកនាំ | ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ | ការអភិវឌ្ឍនៅនឹងកន្លែង | ការផ្លាស់ទីលំនៅទៅកន្លែង ផ្សេង | ការរៀបចំផែនការសន្សំ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| អណ្ដូងតាអៀង | ៨ | ០ | ០ | ០ | ០ | ០ | ៣ | ១ | ១២ |
| បឹងឈូកមានជ័យថ្មី២ | ៤ | ១ | ២ | ២ | ១ | ០ | ១ | ៤ | ១៤ |
| ផ្ទាអើត | ៨ | ០ | ១ | ០ | ២ | ០ | ៣ | ៤ | ១៨ |
| កៅពីរ | ៣០ | ០ | ០ | ០ | ០ | ៥ | ០ | ០ | ៣៥ |
| ពង្រសែនជ័យ | ២៧ | ១ | ១ | ១ | ០ | ០ | ៦ | ៤ | ៤០ |
| ស្នើសាមគ្គី | ១៨ | ១ | ០ | ០ | ៤ | ០ | ០ | ០ | ២៣ |
| សាមគ្គីរុងរឿង | ១៧ | ០ | ១ | ១ | ៤ | ០ | ០ | ០ | ២៣ |
| សំពោងត្បូង | ២០ | ០ | ០ | ០ | ០ | ០ | ២ | ៣ | ២៥ |
| ស្ត្រីក្លាហាន | ១០ | ១ | ០ | ១ | ០ | ០ | ២ | ០ | ១៤ |
| ស្ទឹងកំបុត | ៥២ | ១ | ១ | ០ | ១ | ០ | ៩ | ៦ | ៧០ |
| ទំនប់តាថ្លាង | ៨ | ១ | ០ | ០ | ០ | ០ | ០ | ៣ | ១២ |
| ផ្សេងៗ | ២០៣ | ៧ | ៧ | ៥ | ១៣ | ៦ | ២៧ | ២៦ | ២៩៤ |
| ភាគរយ | ៦៩ | ២,៤ | ២,៤ | ១,៧ | ៤,៤ | ២ | ៩,២ | ៨,៨ | ១០០ |

# សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋាននៃរបាយការណ៍នេះត្រូវបានបង្ហាញដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវនីមួយៗដែលបានស្នើឡើងសម្រាប់ការសិក្សានេះ។

## *១. តើសហគមន៍មានបញ្ហាអ្វីខ្លះទាក់ទងនឹងសិទ្ធិដីធ្លី និងលំនៅឋាន?*

ការស្រាវជ្រាវនេះបង្ហាញថា សហគមន៍ទាំង១១ ជួបប្រទះនឹងបញ្ហាអសុវត្ថិភាពដីធ្លី និងលំនៅឋាន អាចដោយសារការកាន់កាប់ដីសាធារណៈរបស់រដ្ឋ។ ពួកគេងាយរងការបណ្តេញចេញ ដោយសារគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅលើដីរបស់ពួកគេ។ ព័ត៌មានច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋានអំពីផែនការសម្រាប់សហគមន៍ទាំងនេះពុំមាននៅឡើយ រួមជាមួយនឹងការទំនាក់ទំនងទៀងទាត់ពីអាជ្ញាធររាជរដ្ឋាភិបាល។ សហគមន៍ភាគច្រើនមានឆន្ទៈក្នុងការសហការជាមួយអាជ្ញាធរដើម្បីស្វែងរកដំណោះស្រាយ ប៉ុន្តែត្រូវការប្តេជ្ញាចិត្តក្នុងការធានាបាននូវដីធ្លី និងលំនៅឋានសម្រាប់ប្រជាពលរដ្ឋ។ ជម្រើសដែលពេញចិត្តគឺការអភិវឌ្ឍនៅនឹងកន្លែង ប៉ុន្តែការផ្លាស់ប្តូរទីតាំងត្រូវបានពិចារណាប្រសិនបើលក្ខខណ្ឌពេញចិត្ត។

កង្វល់សំខាន់ៗ ដែលបានលើកឡើងដោយគ្រួសារនីមួយៗរួមមាន ការភ័យខ្លាចនៃការបណ្តេញចេញ កង្វះសំណង់សមរម្យ ការរស់នៅក្នុងបរិស្ថានកខ្វក់ អសុវត្ថិភាពចំណីអាហារ មិនមានសមត្ថភាពក្នុងការទទួលបានការអប់រំរបស់កុមារ គ្មានផ្ទះសម្បែង ពិបាកក្នុងការទទួលបានការងារ សេវាកម្មប្រសិនបើត្រូវផ្លាស់ប្តូរទីលំនៅ មានអារម្មណ៍អសុវត្ថិភាពដោយសារគ្មានកម្មសិទ្ធិដីធ្លី និងមិនមានសមត្ថភាពក្នុងការកែលម្អផ្ទះរបស់ពួកគេ ដោយសារតែអសុវត្ថិភាពដីធ្លី។ បញ្ហាជាក់លាក់ដែលសហគមន៍នីមួយៗប្រឈមត្រូវបានសង្ខេបដូចខាងក្រោម៖

- សហគមន៍អណ្តូងតាអៀង ទោះបីដីដែលនៅជុំវិញមានប័ណ្ណកម្មសិទ្ធិក៏ដោយ ក៏ពួកគេមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដែរ។ នៅឆ្នាំ ២០២៣ សហគមន៍អណ្តូងតាអៀងបានទទួលវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ទាក់ទងនឹងសិទ្ធិដីធ្លី និងលំនៅឋាន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការស្វែងរកដំណោះស្រាយបញ្ហាដីធ្លីរបស់ពួកគេ តាមរយៈអង្គការមិនមែនរដ្ឋាភិបាល។ ឥឡូវនេះសហគមន៍កំពុងប្រមូលព័ត៌មានសម្រាប់ការដាក់ស្នើសុំចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងពិចារណាលើការអភិវឌ្ឍនៅនឹងកន្លែង និងការកែប្រែការតាំងទីលំនៅរបស់ពួកគេដែលមានសក្តានុពល។
- សហគមន៍បឹងឈូកមានជ័យថ្មី២ មិនមានប័ណ្ណកម្មសិទ្ធិដីធ្លី បើទោះជាមានការស្នើសុំចុះបញ្ជីដីធ្លីជាប្រព័ន្ធក៏ដោយ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនទាន់បានឆ្លើយតបទៅនឹងពាក្យសុំរបស់ពួកគេទេ។ សហគមន៍មានការទំនាក់ទំនងដោយផ្ទាល់ជាមួយខណ្ឌ ដែលបានសន្យាថានឹងរៀបចំឯកសារ និងពិភាក្សាអំពីពាក្យស្នើសុំជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បច្ចុប្បន្ន មិនមានការគំរាមកំហែងការបណ្តេញចេញនោះទេ ប៉ុន្តែប្រជាសហគមន៍មានការព្រួយបារម្ភអំពីការពន្យាពេលក្នុងការ ចុះបញ្ជីដីធ្លីជាប្រព័ន្ធ បើធៀបនឹងអ្នកជិតខាងរបស់ពួកគេ។ ការតស៊ូមតិដោយអហិង្សាកំពុងបន្ត ហើយកិច្ចប្រជុំទៀងទាត់ជាមួយមន្ត្រីខណ្ឌត្រូវបានគ្រោងទុក។
- សហគមន៍ផ្សារអើតត្រូវបានផាត់ចេញពីការ

ចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅឆ្នាំ២០២៣ ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទោះបីជាការរស់នៅលើដីនេះ ត្រូវបានចាត់ថ្នាក់ជាសម្បត្តិរដ្ឋក៏ដោយ ប៉ុន្តែមានគ្រួសារមួយចំនួនបានទទួលបង្កាន់ដៃចុះបញ្ជីដីធ្លីខណៈដែលសហគមន៍ទាំងមូលកំពុងរង់ចាំការឆ្លើយតប។ សហគមន៍យល់ថា ពួកគេមិនសូវមានតម្លៃ ហើយបារម្ភថាដីរបស់ពួកគេអាចនឹងត្រូវបានប្រើប្រាស់សម្រាប់ការអភិវឌ្ឍ។ ពួកគេបានដាក់លិខិតទៅសាលាសង្កាត់ស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លី និងមានផែនការស្នើទៅសាលារាជធានីភ្នំពេញ ដើម្បីសុំប័ណ្ណកម្មសិទ្ធិដីធ្លី និងសាកសួរទីតាំងដែលមានសក្តានុពលសម្រាប់ដោះដូរទីលំនៅ។

- សហគមន៍កៅពីរបានប្រឈមនឹងជម្លោះដីធ្លីជាមួយក្រុមហ៊ុនចំនួនបីចាប់តាំងពីឆ្នាំ២០១៦មក។ នៅឆ្នាំ២០១៦ ក្រុមហ៊ុនឧស្ម័នមួយបានប្រគល់ដីជូនសហគមន៍វិញបន្ទាប់ពីមានជម្លោះប៉ុន្តែនៅឆ្នាំ២០២២ក្រុមហ៊ុនចិនបានទាមទារដីចំនួន ១៨ប្លង់ជាមួយសំណងចំនួន ៥០០០-១០០០០ដុល្លារ ក្នុងមួយគ្រួសារ។ បច្ចុប្បន្នក្រុមហ៊ុនមួយឈ្មោះ ចាំងហ្សប ខមផានី (Junk Shop Company) កំពុងទាមទារយកដីរបស់ប្រជាពលរដ្ឋចំនួន ៣៣គ្រួសារ។ សហគមន៍បានដាក់ពាក្យបណ្តឹងទៅសង្កាត់ និងខណ្ឌ ប៉ុន្តែមិនបានទទួលការឆ្លើយតបទេ។
- សហគមន៍ពង្រសែនជ័យ ដែលបានបង្កើតឡើងតាំងពីទស្សវត្សរ៍ឆ្នាំ២០០០ ប្រឈមនឹងអសុវត្ថិភាពដីធ្លីដោយសារការកាន់កាប់ដីសាធារណៈរបស់រដ្ឋលើផ្លូវតូចមួយខ្សែ។ ខណៈដែលពួកគេមិនត្រូវបានបណ្តេញចេញជាផ្លូវការ អាជ្ញាធរមូលដ្ឋានបានគំរាមបណ្តេញចេញរួចទៅហើយសម្រាប់ការអភិវឌ្ឍផ្លូវ។ សហគមន៍មិនមានសៀវភៅគ្រួសារ និងសំបុត្រកំណើតទេ។ ពួកគេបានស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លី និងជម្រើសធ្វើផ្លូវឡើងវិញ ប៉ុន្តែសំណើទាំងនេះត្រូវបានច្រានចោល។ សហគមន៍មានការព្រួយបារម្ភអំពីផលប៉ះពាល់នៃការអភិវឌ្ឍផ្លូវទៅលើផ្ទះសម្បែង និងជីវភាពរស់នៅរបស់ពួកគេ។
- សហគមន៍ស្មើសាមគ្គី ដែលបានរស់នៅលើប្រឡាយតាំងពីឆ្នាំ១៩៩៨ ប្រឈមនឹងការផ្លាស់ទីលំនៅជាបន្ទាន់ ដោយសារគម្រោងអភិវឌ្ឍន៍នាពេលខាងមុខ ដែលផ្តល់មូលនិធិដោយចៃកា (JICA)។ គម្រោងនេះគ្រោងនឹងចាប់ផ្តើមនៅខែមិថុនា ឬកក្កដា ឆ្នាំ២០២៤។ សហគមន៍បានចូលរួមក្នុងកិច្ចប្រជុំជាច្រើនជាមួយចៃកា(JICA)ដែលពួកគេត្រូវបានប្រាប់ថាសំណាងនឹងត្រូវបានផ្តល់ជូន ប៉ុន្តែមិនត្រូវបានផ្តល់ព័ត៌មានលម្អិតជាក់លាក់នោះទេ។ សហគមន៍ចង់ទទួលបានការអភិវឌ្ឍនៅនឹងកន្លែង និងជាតំបន់ដែលមានសក្តានុពលក៏ប៉ុន្តែពួកគេក៏បើកចិត្តទទួលយកការផ្លាស់ប្តូរទីលំនៅថ្មីដែរ ប្រសិនបើសំណាងសមរម្យ វិធានការកាត់បន្ថយភាពងាយរងគ្រោះ និងទីតាំងមួយក្នុងចម្ងាយ ៥គីឡូម៉ែត្រពីទីតាំងបច្ចុប្បន្នរបស់ពួកគេត្រូវបានធានា។ ពួកគេបានស្នើសុំចៃកា (JICA) និងសាលាក្រុងអនុវត្តន៍តាមសារាចរលេខ ០៣ និងផ្តល់ប័ណ្ណកម្មសិទ្ធិ និងសេវាសាធារណៈនៅទីតាំងថ្មី។ រហូតមកដល់ពេលនេះ ចៃកា (JICA) មិនទាន់បានជូនដំណឹងអំពីជម្រើសផ្លាស់ប្តូរទីតាំងជាមួយសហគមន៍ទេ។សហគមន៍កំពុងស្វែងរកការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល មេធាវី និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីជួយសម្រួលដល់សិក្ខាសាលាពិគ្រោះយោបល់ និងបង្កើត

ផែនការអភិវឌ្ឍន៍នៅនឹងកន្លែង ឬផ្លាស់ប្តូរទីលំនៅ។

- សហគមន៍សំរោងត្បូង៖ សហគមន៍រស់នៅក្នុងតំបន់ដីសើមដែលបានចាក់បំពេញក្នុងរយៈពេលជាច្រើនឆ្នាំ និងអភិវឌ្ឍន៍ដោយបុរីបន្ទាប់ពីគម្រោងសម្បទានដី។ អ្នករស់នៅក្នុងបុរីមានប័ណ្ណកម្មសិទ្ធិដី ប៉ុន្តែប្រជាសហគមន៍មិនមានទេ។ នៅឆ្នាំ២០២២-២០២៣ គម្រោងដីកប្រឡាយមួយបានប៉ះពាល់ដល់ដីសហគមន៍ និងបញ្ចេញសំណល់រាវចូលទៅក្នុងសហគមន៍ ធ្វើឱ្យផ្ទះសម្បែងបានចាប់ផ្តើមជន់លិច។ ការសាងសង់បានឈានដល់ដីសហគមន៍ ហើយសាលារាជធានីបានស្នើឱ្យធ្វើការកែលម្អនៅនឹងកន្លែង។ ទោះជាយ៉ាងណា នៅខែតុលា ឆ្នាំ២០២៣ សាលាសង្កាត់បានស្នើឱ្យសហគមន៍ពិចារណាលើសំណងដីរបស់ពួកគាត់ជំនួសវិញ។ គ្រួសារខ្លះបានស្នើសុំការអភិវឌ្ឍនៅនឹងកន្លែង ប៉ុន្តែអាជ្ញាធរមូលដ្ឋានមិនទាន់ឆ្លើយតបនៅឡើយទេ។ សហគមន៍បានស្វែងរកកិច្ចអន្តរាគមន៍នានា ដូចជាការទាក់ទងអ្នកសារព័ត៌មាន ការចរចាជាមួយអាជ្ញាធរ ការធ្វើលិខិតទៅស្ថាប័នពាក់ព័ន្ធ និងធ្វើសកម្មភាពផ្សេងៗដើម្បីការពារដីរបស់ពួកគេ។

- សហគមន៍ស្ត្រីក្លាហាន ដែលរស់នៅលើដីសាធារណៈរបស់រដ្ឋតាមមាត់ទន្លេ មិនមានប័ណ្ណកម្មសិទ្ធិដីធ្លីទេ។ខណៈដែលពួកគេមិនមានបញ្ហាប្រឈមនឹងការគំរាមកំហែងពីការបណ្តេញចេញដោយផ្ទាល់ សហគមន៍មិនមានភាពច្បាស់លាស់អំពីសុវត្ថិភាពរយៈពេលវែងរបស់ពួកគេទេ។ ពួកគេចង់បានការអភិវឌ្ឍនៅនឹងកន្លែង ប៉ុន្តែប្រសិនបើតម្រូវឱ្យផ្លាស់ប្តូរទីតាំង ពួកគេចង់បានសំណងសមរម្យ និងមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។សហគមន៍កំពុងសកម្ម ក្នុងការប្រមូលឯកសារដីធ្លី និងចងក្រងប្រវត្តិសហគមន៍ដើម្បីតស៊ូមតិទាមទារសិទ្ធិរបស់ខ្លួននៅសង្កាត់ ខណ្ឌ និងសាលារាជធានីភ្នំពេញ។

- សហគមន៍ស្ទឹងកំបុត៖ រស់នៅលើអតីតព្រែកដែលបានចាក់បំពេញនៅឆ្នាំ២០០០។ អាជ្ញាធរមូលដ្ឋានអះអាងថា ដីនេះជាដីសាធារណៈ និងមិនអាចទិញ-លក់បានទេ ប៉ុន្តែមានបុរីដែលអាចទិញ-លក់បាន។ នៅឆ្នាំ២០១៩ អាជ្ញាធរបានស្នើសុំឱ្យផ្លាស់ទីលំនៅថ្មី ប៉ុន្តែសហគមន៍បដិសេធ។ ឥឡូវនេះពួកគេស្នើសុំការអភិវឌ្ឍនៅនឹងកន្លែង ហើយអាជ្ញាធរបានជំទាស់នឹងសំណើមួយនេះ។ សហគមន៍ចង់បានការអភិវឌ្ឍនៅនឹងកន្លែង និងប័ណ្ណកម្មសិទ្ធិដីធ្លី។ ពួកគេបានស្នើសុំជាច្រើនដងចាប់តាំងពីឆ្នាំ២០១៧ ប៉ុន្តែមិនមានការឆ្លើយតបជាវិជ្ជមានទេ។

- សហគមន៍ទំនប់តាថ្លាង រស់នៅលើអតីតផ្លូវប្រឡាយ (ប្រឡាយតាថ្លាង)។បច្ចុប្បន្នមានទំហំដីស្មើៗគ្នា (៥ម x ៨មលំនៅឋាន) ប៉ុន្តែមិនមានប្លង់កម្មសិទ្ធិទេ។ នៅឆ្នាំ២០១៩ ក្រុមការងារគម្រោងចុះបញ្ជីដីធ្លីជាប្រព័ន្ធបានចុះវាស់វែងដីរបស់ពួកគេ និងផ្តល់បង្កាន់ដៃ ប៉ុន្តែមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិនៅឡើយទេ។ សង្កាត់ចង់ឱ្យពួកគេដោះដូរដីកន្លែងតាំងទីលំនៅវិញ ដោយសារគម្រោងប្រព័ន្ធលូ ប៉ុន្តែប្រព័ន្ធលូត្រូវបានសាងសង់នៅកន្លែងផ្សេង។ បង្កាន់ដៃរបស់ពួកគេត្រូវបានដកហូត ហើយពួកគេកំពុងរង់ចាំបង្កាន់ដៃថ្មី។ អាជ្ញាធរខណ្ឌ និងសាលាក្រុងស្នើសុំការផ្លាស់ប្តូរទៅដីតូចមួយនៅកន្លែងតាំងទីលំនៅថ្មី។ សហគមន៍ចង់បានបង្កាន់ដៃផ្លូវការប្លង់កម្មសិទ្ធិដីធ្លីនិងហេដ្ឋារចនាសម្ព័ន្ធនៅកន្លែងថ្មី និងអ្នកតស៊ូមតិសម្រាប់ការ

អភិវឌ្ឍនៅនឹងកន្លែង។ ស្ថានភាពបច្ចុប្បន្នពាក់ព័ន្ធនឹងភាពមិនច្បាស់លាស់ និងការចរចាកំពុងតែបន្ត។

- សហគមន៍សាមគ្គីរុងរឿង៖ រស់នៅលើដីសាធារណៈរបស់រដ្ឋតាមបណ្តោយប្រឡាយ។ នៅឆ្នាំ២០២៣ អាជ្ញាធរមូលដ្ឋានបានប្រកាសគម្រោងការអភិវឌ្ឍ ប៉ុន្តែមិនបានផ្តល់ព័ត៌មានលម្អិតទេ។ សាលារាជធានីភ្នំពេញ និងមន្ទីរសុរិយោដីបានធ្វើការស្ទង់មតិ ប៉ុន្តែសហគមន៍មិនត្រូវបានអនុញ្ញាតឱ្យជួសជុល ឬសាងសង់ផ្ទះថ្មីឡើយ។ តំបន់នេះមានជន់លិចក្នុងរដូវវស្សា ហើយការប្រជុំជាមួយអង្គការក្រៅរាជរដ្ឋាភិបាលត្រូវបានហាមឃាត់។ អាជ្ញាធរបានអញ្ជើញក្រុមគ្រួសារមកចូលរួមការប្រជុំ និងបានលើកទឹកចិត្តឱ្យរក្សាការសម្ងាត់។ ចៅសង្កាត់បានណែនាំ អំពីការផ្លាស់ប្តូរទីតាំងទៅដីសេរិន អិន ជី (7NG) ប៉ុន្តែសហគមន៍ចង់បានការអភិវឌ្ឍនៅនឹងកន្លែងតាមរយៈ សារាចរលេខ០៣ ដូចដែលបានអនុវត្តន៍ជាមួយនឹងគម្រោងប្រឡាយស្ទឹងមានជ័យដែរ។

## ២. *តើមានឯកសារច្បាប់ ឬការវិភាគផ្លូវច្បាប់ណាខ្លះដែលគាំទ្រការកាន់កាប់ដីធ្លី និងលំនៅឋានរបស់សហគមន៍ទាំង ១១ ដែរឬទេ?*

តាមរយៈការពិភាក្សាជាក្រុម និងការស្ទង់មតិតាមគ្រួសារ សមាជិកនៃសហគមន៍ទាំង ១១ យល់ដឹងអំពីឯកសារដែលពួកគេត្រូវការ ដើម្បីបញ្ជាក់ពីកម្មសិទ្ធិលើដីរបស់ពួកគេ។ ឯកសារដែលមានជាមួយនឹងសមាជិកសហគមន៍ មានកម្រិតអាស្រ័យលើសហគមន៍ និងគ្រួសារនីមួយៗ។ គ្រួសារខ្លះមានឯកសារស្របច្បាប់ដែល ទទួលស្គាល់ដោយសង្កាត់ ឬមេភូមិ ចំណែកខ្លះទៀតមានទម្រង់ឯកសារក្រៅផ្លូវការ ឬមិនមានអ្វីទាំងអស់។ អង្គការក្រៅរាជរដ្ឋាភិបាលផ្សេងៗគ្នានៅទូទាំងរាជធានីភ្នំពេញបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលផ្នែកច្បាប់ និងការយល់ដឹងអំពីដីធ្លីដល់សហគមន៍ ហើយដោយសារមានវគ្គបណ្តុះបណ្តាល និងវគ្គចែកព័ត៌មានរបស់ពួកគេ សហគមន៍ទាំង១១ បានទទួលជោគជ័យក្នុងការធ្វើការរួមគ្នាដើម្បីប្រមូលឯកសារចាំបាច់ដើម្បីទាមទារ និងបញ្ជាក់កម្មសិទ្ធិដីធ្លី។ បើទោះជាយ៉ាងនេះក្តី សហគមន៍ទាំង១១ ភាគច្រើនមិនបានទទួល ឬមិនត្រូវបានរាប់បញ្ចូលក្នុងការចុះបញ្ជីដីធ្លីជាប្រព័ន្ធទេ។ ក្នុងករណីដែលរាជរដ្ឋាភិបាលបានលុបចោលដំណើរការចុះបញ្ជីដីធ្លីជាប្រព័ន្ធរបស់សហគមន៍ទាំងនេះ ដោយសារតែតម្រូវការអភិវឌ្ឍ។

- សហគមន៍អណ្តូងតាអៀង៖ មានសៀវភៅស្នាក់នៅ សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ ប័ណ្ណបោះឆ្នោត ប៉ុន្តែគ្មានសៀវភៅគ្រួសារ និងគ្មានបង្កាន់ដៃដី។
- សហគមន៍បឹងឈូកមានជ័យថ្មី២៖ ប្រជាសហគមន៍នេះមានឯកសារគ្រប់គ្រាន់ទាំងអស់ដែលចាំបាច់ដើម្បីដាក់ពាក្យសុំចុះបញ្ជីដីធ្លីជាប្រព័ន្ធ។
- សហគមន៍ឆ្មាអើត៖ ប្រជាជនក្នុងសហគមន៍នេះមានឯកសារគ្រប់គ្រាន់ទាំងអស់ដែលចាំបាច់ដើម្បីដាក់ពាក្យសុំចុះបញ្ជីដីធ្លីជាប្រព័ន្ធ។
- សហគមន៍កោពីរ៖ មិនមានសៀវភៅគ្រួសារទេ។ គ្រួសារទាំងអស់មានបង្កាន់ដៃដីពីសង្កាត់ ប៉ុន្តែគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីទេ។
- សហគមន៍ពង្រសែនជ័យ៖ គ្មានបង្កាន់ដៃកាន់កាប់ដីធ្លី គ្មានសៀវភៅគ្រួសារ ឬសំបុត្រកំណើតសម្រាប់ទារកទើបកើតនោះទេ។
- សហគមន៍រស្មីសាមគ្គី៖ ប្រជាសហគមន៍គ្មានប័ណ្ណកម្មសិទ្ធិដី ប៉ុន្តែប្រជាពលរដ្ឋមាន



*រូបភាពទី៩៖ ប្រឡាយនៅខាងក្រោយសហគមន៍ស្មើសាមគ្គី*

កិច្ចសន្យាទិញដីដោយបញ្ជាក់ដោយមេភូមិ។ ក្រៅពីនោះ មានសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រកំណើត។

- សហគមន៍សំរោងត្បូង៖ មានឯកសារអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន។
- សហគមន៍ស្រ្តីក្លាហាន៖ ប្រជាពលរដ្ឋក្នុងសហគមន៍មានសៀវភៅគ្រួសារ សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ ប័ណ្ណសមធម៌ និងប័ណ្ណគ្រួសារងាយរងហានិភ័យ ប៉ុន្តែគ្មានឯកសារកាន់កាប់ដីធ្លី។
- សហគមន៍ស្ទឹងកំបុត៖ មានឯកសារអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន។
- សហគមន៍ទំនប់តាថ្លាង៖ សៀវភៅគ្រួសារ សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ ប័ណ្ណបោះឆ្នោត និងបង្កាន់ដៃចុះបញ្ជីដីធ្លី (ត្រូវបានដកហូត)។
- សហគមន៍សាមគ្គីរុងរឿង៖ គ្រួសារភាគច្រើនមាន ប័ណ្ណសមធម៌ និងប័ណ្ណគ្រួសារងាយរងហានិភ័យ។

### ៣. តើសហគមន៍ប្រឈមនឹងបញ្ហាអ្វីខ្លះក្នុងដំណើរការតស៊ូមតិដើម្បីទាមទារដីរបស់ខ្លួន?

ការចងក្រងសហគមន៍និងការតស៊ូមតិត្រូវបានគំរាមកំហែងដោយអាជ្ញាធរមូលដ្ឋាន។ សមាជិកសហគមន៍ និងតំណាងសហគមន៍មួយចំនួនភ័យខ្លាចក្នុងការចូលរួមការតស៊ូមតិ និងការចងក្រងសហគមន៍ ដោយសារពួកគេភ័យខ្លាចអាជ្ញាធរធ្វើទុក្ខបុកម្នេញ ប៉ះពាល់ដល់អាយុជីវិត និងគ្រួសាររបស់ពួកគេ។ ប្រជាសហគមន៍ទាំងអស់ដែលត្រូវបានសម្ភាសន៍មកពីសហគមន៍ទាំង១១ បានសម្តែងការភ័យខ្លាច និងការបំភិតបំភ័យពីសំណាក់អាជ្ញាធរសង្កាត់ និងភូមិ ដោយសារតែការចូលរួមក្នុងសកម្មភាពតស៊ូមតិ។ ប្រជាសហគមន៍បានទទួលការគំរាមកំហែងដោយផ្ទាល់ដល់សន្តិសុខបុគ្គល និងគ្រួសាររបស់ពួកគេ ដោយសារតែការចូលរួមក្នុងសកម្មភាពតស៊ូមតិ ឬមានការភ័យខ្លាចដោយសារតែឃើញតំណាងសហគមន៍រងឥទ្ធិពលអវិជ្ជមានពីអាជ្ញាធរមូលដ្ឋានដោយសារការរៀបចំសកម្មភាពតស៊ូមតិ។ ការបំភិតបំភ័យ និងអសុវត្ថិភាពនេះជាការរំលោភសិទ្ធិមនុស្ស និងជាការរំលោភច្បាប់ជាតិ និងអន្តរជាតិ ដូចជារដ្ឋធម្មនុញ្ញកម្ពុជាក្រមរដ្ឋប្បវេណី និងសេរីភាពនៃការបញ្ចេញមតិ។

### ៤. តើសមាជិកសហគមន៍ចូលរួមក្នុងសកម្មភាពការពារដីធ្លី និងផ្ទះសម្បែងរបស់ខ្លួនដែរឬទេ? ហេតុអ្វីចូលរួមឬហេតុអ្វីមិនចូលរួម?

សហគមន៍ភាគច្រើនបានចូលរួម និងមានបទពិសោធន៍ក្នុងការចងក្រងសហគមន៍។កម្រិតនៃការយល់ដឹងអំពីការចងក្រងសហគមន៍ប្រែប្រួលតាមសហគមន៍ ហើយបានផ្លាស់ប្តូរតាមពេលវេលា។ សកម្មភាពសហគមន៍ រួមទាំងការតស៊ូមតិ និងការបង្កើតរចនាសម្ព័ន្ធសហគមន៍ និងក្រុមសន្សំប្រាក់ បានរួមចំណែកយ៉ាងសំខាន់ក្នុងការជួយប្រជាសហគមន៍ទប់ស្កាត់ការបណ្តេញចេញ ប្រមូលឯកសារចាំបាច់ដើម្បីទាមទារដីធ្លី កែលម្អស្ថានភាពរស់នៅដើម្បីជីវភាពរបស់ពួកគេកាន់តែល្អប្រសើរ។

ក្នុងករណី សមាជិកសហគមន៍អណ្តូងតាអៀងមិនបានចូលរួមច្រើនក្នុងដំណើរការសហគមន៍។ សហគមន៍ជួបប្រទះបញ្ហាដូចជាគ្រឿងញៀននិងបទល្មើស។ នៅសហគមន៍បឹងឈូកមានជ័យថ្មី ២ប្រជាពលរដ្ឋសកម្មក្នុងសហគមន៍មានការនឿយហត់ក្នុងការចំណាយពេលវេលា និងកម្លាំងក្នុងសកម្មភាពសហគមន៍ដោយមិនទទួលបានលទ្ធផលជាក់ស្តែងទាក់ទងនឹងការទទួលបានកម្មសិទ្ធិដីធ្លី។ ប្រជាជនបានឈប់សន្សំប្រាក់ និងឈប់ចូលរួមចំណែកក្នុងសកម្មភាពសហគមន៍

ដូចជាការកែលម្អផ្លូវថ្នល់ សួនលេងកម្សាន្តរបស់កុមារជាដើម។ សហគមន៍ដូចជា សហគមន៍សាមគ្គីរុងរឿងប្រឈមនឹងការបំភិតបំភ័យ និងការតាមដានដោយអាជ្ញាធរ ហើយមិនអាចរៀបចំនិងធ្វើសកម្មភាពប្រមូលផ្តុំបានទេ។

### *៥. តើអ្វីជាបញ្ហាប្រឈមចម្បងក្នុងការចូលរួម?*

បញ្ហាប្រឈមសំខាន់ៗនៃការចូលរួមនៅទូទាំងសហគមន៍គឺការបំភិតបំភ័យ និងការត្រួតត្រាដោយអាជ្ញាធរមូលដ្ឋាន ក៏ដូចជាការភ័យខ្លាចដែលប្រជាសហគមន៍ត្រូវចូលរួមក្នុងសកម្មភាពតស៊ូមតិ និងលើកឡើងពីកង្វល់របស់ពួកគេ។ម៉្យាងទៀត ប្រជាជនមានការនឿយហត់ និងមិនមានពេលវេលាដើម្បីចូលរួមការប្រជុំសហគមន៍ ហើយក្នុងករណីខ្លះពួកគេធ្លាប់មានបទពិសោធន៍មិនល្អជាមួយតំណាងសហគមន៍។ ការស្ទង់មតិគ្រួសារក៏បានបង្ហាញដែរថា នៅតែមានប្រជាសហគមន៍ជាច្រើននាក់ ដែលមិនបានដឹងពីភាពងាយរងគ្រោះរបស់ពួកគេទាក់ទងនឹងអសុវត្ថិភាពដីធ្លីនិង លំនៅឋាន។ ដូចគ្នានេះផងដែរ អ្នកភូមិជាច្រើនមិនបានដឹងពីការចងក្រងសហគមន៍ និងរចនាសម្ព័ន្ធសមូហភាព និងការគាំទ្រនៅក្នុងសហគមន៍របស់ពួកគេ។ នេះជារឿងធម្មតាទេដែលមានប្រជាពលរដ្ឋធ្វើចំណាកស្រុកមកទីក្រុងភ្នំពេញ និងរស់នៅជាលក្ខណៈបណ្តោះអាសន្នក្នុងទីតាំងមិនស្របច្បាប់។ ទោះយ៉ាងណាក៏ដោយ វាបង្ហាញពីបញ្ហាដែលត្រូវការការយកចិត្តទុកដាក់។

### *៦. តើមានអនុសាសន៍ជាក់លាក់អ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាសហគមន៍ទាំង ១១នេះ?*

ជាទូទៅ សមាជិកសហគមន៍ត្រូវការការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលសម្រាប់ការតស៊ូមតិនាពេលអនាគតលើស្ថានភាពអសន្តិសុខនៃដីធ្លី និងលំនៅឋានរបស់ពួកគេ ហើយបន្តចូលរួមកិច្ចប្រជុំនិងពិភាក្សាអំពីជម្រើសនាពេលអនាគតរបស់ពួកគេជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់មូលនិធិអភិវឌ្ឍន៍ដូចជាចៃកា(JICA)ជាដើម។ អង្គការមិនមែនរដ្ឋាភិបាលអាចគាំទ្រសហគមន៍ដើម្បីបង្កើតផែនការបច្ចេកទេសរបស់ពួកគេសម្រាប់ការកែលម្អនៅលើទីតាំងចាស់ ឬផ្លាស់ប្តូរទៅទីតាំងថ្មី ហើយធានាថាគោលនយោបាយពាក់ព័ន្ធ (សារាចរលេខ០៣)ត្រូវបានអនុវត្តន៍យ៉ាង ត្រឹមត្រូវ។ អង្គការមិនមែនរដ្ឋាភិបាលអាចជួយក្នុងការនាំយកសំឡេងរបស់សហគមន៍ (ការផ្តល់យោបល់សម្រាប់ការកែលម្អនៅលើទីតាំងចាស់) ទៅកាន់អាជ្ញាធរមូលដ្ឋាន។ ម៉្យាងទៀត អង្គការមិនមែនរដ្ឋាភិបាល អាចគាំទ្រសហគមន៍ជាមួយនឹងការកសាងសមត្ថភាពលើច្បាប់ដីធ្លី ការប្រមូលឯកសារអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនការធ្វើផែនទីសហគមន៍ និងជំនួយផ្នែកច្បាប់សម្រាប់ប្រជាសហគមន៍ ជាពិសេសអ្នកដែលមិនទាន់ដឹងពីតម្រូវការទាំងនេះ។ ម៉្យាងទៀត អង្គការមិនមែនរដ្ឋាភិបាលអាចគាំទ្រសហគមន៍ដើម្បីកែលម្អបរិស្ថានក្នុងមូលដ្ឋានរបស់ពួកគេ ដោយគាំទ្រទិវាធ្វើអនាម័យ និងកត់ត្រាការបំពុលបរិស្ថាននៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង។ ជាងនេះទៅទៀត សហគមន៍ក្រីក្រនៅតាមទីក្រុងគិតថា អង្គការមិនមែនរដ្ឋាភិបាអាចជួយបានតាមរយៈការធ្វើឱ្យមើលឃើញពីការតស៊ូរបស់ពួកគេនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។



រូបភាពទី១០៖ លំនៅឋាននៅក្នុងសហគមន៍ស្រ្តីក្លាហាន

# អនុសាសន៍

ដោយផ្អែកលើលទ្ធផលនៃការសិក្សានេះ អនុសាសន៍ជាក់លាក់ខាងក្រោមត្រូវបានស្នើឡើង ដើម្បីដោះស្រាយបញ្ហាដីធ្លី និងសិទ្ធិលំនៅឋាន នៅក្នុងសហគមន៍ទាំងនេះ៖

១. ស្របតាមគោលនយោបាយ "សារាចរលេខ ០៣" អង្គការមិនមែនរដ្ឋាភិបាល គួរតែគាំទ្រសហគមន៍ទាំង១១ ដើម្បីធ្វើការស្នើសុំការចុះបញ្ជីដីធ្លី តាមរយៈការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគមន៍ដូចជា ព័ត៌មានប្រជាសាស្ត្រ និងឯកសារគាំទ្រការកាន់កាប់ដីធ្លីដែលមានសម្រាប់គ្រួសារនីមួយៗ និងបង្កើតផែនការកែលម្អលំនៅឋានសម្រាប់ជម្រើសទាំងនៅនឹងកន្លែង និងជម្រើសផ្លាស់ប្តូរទីលំនៅ។ សកម្មភាពទាំងនេះនឹងជួយសហគមន៍ឱ្យមានផែនការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដែលពួកគេអាចប្រើបានដើម្បីបង្កើតទំនាក់ទំនងជាមួយអាជ្ញាធររដ្ឋាភិបាល និងមានគំនិតច្បាស់លាស់អំពីតម្រូវការរបស់ពួកគេសម្រាប់ពេលអនាគត។

២. អង្គការមិនមែនរដ្ឋាភិបាលអាចប្រើប្រាស់ "សារាចរលេខ០៣"ជាមធ្យោបាយ ដើម្បីស្វែងរកដំណោះស្រាយដីធ្លីសម្រាប់សហគមន៍ទាំង ១១ នេះ ជាមួយសាលារាជធានីភ្នំពេញ និងអគ្គនាយកដ្ឋានលំនៅឋាន។ ប្រើប្រាស់ឧទាហរណ៍នៃសហគមន៍ស្ទឹងមានជ័យក្នុងរាជធានីភ្នំពេញ ដើម្បីបង្ហាញពីអត្ថប្រយោជន៍នៃការអនុវត្ត "សារាចរលេខ ០៣" ដល់គ្រប់ភាគីពាក់ព័ន្ធ។ សកម្មភាពតស៊ូមតិអាចរាប់បញ្ចូលទាំងការរៀបចំវេទិកាជាមួយអាជ្ញាធរមូលដ្ឋាន ដែលសហគមន៍អាចបង្ហាញផែនការ និងព័ត៌មានថ្មីៗ របស់ពួកគេក៏ដូចជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្សព្វផ្សាយព័ត៌មានជាដើម។ ឧទាហរណ៍ករណីសិក្សាអន្តរជាតិអំពីកម្មវិធីជោគជ័យក្នុងការដោះស្រាយបញ្ហាដីធ្លី និងលំនៅឋានរបស់សហគមន៍ក្រីក្រ ដូចដែលបានបង្ហាញនៅក្នុងឯកសារនេះ ក៏អាចត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃសកម្មភាពតស៊ូមតិនេះផងដែរ។

៣. អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលនឹងជួយសហគមន៍ទាំង១១ ធ្វើការស្ទង់មតិដីធ្លីនៅទូទាំងរាជធានីភ្នំពេញ ដើម្បីកំណត់ទីតាំងសមរម្យសម្រាប់សហគមន៍នីមួយៗទៅតាំងទីលំនៅនៅកន្លែងថ្មី។ ការស្ទង់មតិទាំងនេះមានសិទ្ធិប្រើប្រាស់ទិន្នន័យទាក់ទងភូមិសាស្ត្រ និងការស្ទង់មតិនៅសហគមន៍ដើម្បី កំណត់ទីតាំងដីដែលមាននៅក្នុងសង្កាត់នីមួយៗ ដែលអាចសមរម្យសម្រាប់ការផ្លាស់ទីលំនៅ។ ព័ត៌មានទាក់ទងនឹងដីដូចជាម្ចាស់ដី តម្លៃដី និងតំបន់ដីគួរតែត្រូវបានកត់ត្រានៅក្នុងការស្ទង់មតិ។ តំណាងសហគមន៍ និងសមាជិកគួរតែដឹកនាំការស្ទង់មតិទាំងនេះ និងកំណត់អត្តសញ្ញាណដីដែលសមរម្យសម្រាប់ការផ្លាស់ទីលំនៅសម្រាប់សមាជិកនៃសហគមន៍របស់ពួកគេ។

៤. អង្គការសង្គមស៊ីវិលគួរតែបន្តពង្រឹង និងគាំទ្រដល់ការចងក្រងសហគមន៍នៅក្នុងសហគមន៍ក្រីក្រទាំង១១នេះ។ ការជួយគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលជាប់លាប់គឺត្រូវការជាចាំបាច់ដើម្បីបន្តពង្រឹងសមត្ថភាពសហគមន៍ក្នុងការធ្វើការរួមគ្នា ជឿជាក់គ្នាទៅវិញទៅមកនិងដើម្បីមើលឃើញលទ្ធផល

ដាក់ស្តែង និងការផ្លាស់ប្តូរជីវភាពរស់នៅដែលអាចសម្រេចបានពីការធ្វើការងាររួមគ្នានេះ។ ដូចគ្នានេះផងដែរ វាមានសារៈសំខាន់ណាស់ក្នុងការធានាថា អ្នកដឹកនាំសហគមន៍មានទំនួលខុសត្រូវ ចំពោះសមាជិកសហគមន៍ ហើយត្រូវបានគាំទ្រជាមួយនឹងការបណ្តុះបណ្តាល ដើម្បីចែករំលែកចំណេះដឹង និងធ្វើការសម្របសម្រួលដំណើរការសហគមន៍។ ការផ្លាស់ប្តូរព័ត៌មានរវាងសហគមន៍នៅក្នុងរាជធានីភ្នំពេញ និងទីក្រុងនានាក្នុងប្រទេសកម្ពុជា និងរវាងប្រទេសកម្ពុជា និងប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ដើម្បីគាំទ្រ និងការរៀនសូត្រពីគ្នាទៅវិញទៅមក ការធ្វើសកម្មភាព និងការគៀងគរការគាំទ្រត្រូវបានលើកទឹកចិត្ត។

## អនុសាសន៍សម្រាប់ស្ថាប័នរាជរដ្ឋាភិបាលក្នុងរាជធានីភ្នំពេញ

១. ការលើកឡើងថាសហគមន៍រស់នៅលើដីរដ្ឋ ខណៈដីរដ្ឋមិនទាន់បានចុះបញ្ជីដីរដ្ឋនៅឡើយបានធ្វើឱ្យប៉ះពាល់សិទ្ធិ និងផលប្រយោជន៍ដល់ប្រជាសហគមន៍ក្រីក្រ និងអយុត្តិធម៌សង្គម។ ដូច្នេះរដ្ឋាភិបាលត្រូវចុះបញ្ជីដីឱ្យបានរួចរាល់មុននឹងអះអាងថាប្រពលរដ្ឋក្រីក្ររស់នៅលើដីរដ្ឋ និងត្រូវមានតម្លាភាពក្នុងការកំណត់ដីសាធារណៈរបស់រដ្ឋ ដោយមានការចូលរួមពិគ្រោះយោបល់ និងពាក្យពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ។

២. សារាចរលេខ០៣ និងសារាចរលេខ ០៦ គឺជាមូលដ្ឋានដ៏សំខាន់ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ដល់ជនក្រីក្រ ជាពិសេស អ្នកដែលរស់នៅតំបន់មិនទាន់រៀបរយ ក៏ប៉ុន្តែការអនុវត្តគឺបានតិចតួចនៅឡើយ។ សាលារាជធានីភ្នំពេញ និងអគ្គនាយដ្ឋានលំនៅឋាន គួរយកគោលនយោបាយទាំងនេះដោយសហការណ៍ជាមួយស្ថាប័នដែលពាក់ព័ន្ធ រួមមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីលើកកម្ពស់សិទ្ធិមានលំនៅឋាន និងជីវភាពដល់ប្រជាហគមន៍ក្រីក្រកាន់តែប្រសើ តាមរយៈការសាងសង់លំនៅឋានសមរម្យ ឬផ្តល់មូលនិធិលំនៅឋានសមរម្យសម្រាប់សហគមន៍ក្រីក្រ។

## អនុសាសន៍សម្រាប់ទីភ្នាក់ងារអន្តរជាតិ

ការផ្លាស់ប្តូរក្របខណ្ឌគោលនយោបាយលំនៅឋានស្របតាមសេរីភាវូបនីយកម្ម និង "វិធីសាស្រ្តដែលមានលក្ខណៈអំណោយផល" បានបណ្តាលឱ្យម្ចាស់ជំនួយអន្តរជាតិបង្វែរការយកចិត្តទុកដាក់ចេញឆ្ងាយពីរបៀបវារៈ "លំនៅឋាន" ដោយសារតែនេះត្រូវបានគេមើលឃើញថា វាជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលជាតិ។ សូម្បីតែនៅពេលដែលបញ្ហាលំនៅឋានក្លាយជាផ្នែកមួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ហើយច្បាប់អន្តរជាតិនានាគូសបញ្ជាក់អំពីតម្រូវការសម្រាប់ "សិទ្ធិទទួល

បានលំនៅឋាន" ក៏នៅតែមិនមានរបៀបវារៈច្បាស់លាស់ ស្តីពីការជួយគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់គោលបំណងនេះពីអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិផ្សេងទៀតដែរ។ វាជាកត្តាចាំបាច់ដែលម្ចាស់ជំនួយអន្តរជាតិមានការប្តេជ្ញាក្នុងការផ្តល់មូលនិធិដល់កម្មវិធីលំនៅឋាន និងសិទ្ធិដីធ្លីគ្រប់គ្រាន់នៅកម្ពុជា ដោយចាប់ភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល និងសហគមន៍ក្រីក្រនៅរាជធានី។



(+855) 23 431 555

sttcambodia

https://teangtnaut.org/